សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit et Des Sciences Économiques

Royal University Of Law and Economics

សារណាបញ្ចប់ការសិក្សា

អត្ថានុភូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហ៊ិន ចន្ថី**

ជុច គា

សាស្ត្រាចារ្យណែនាំ

លោកគ្រូ **គា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី១៤ សរសេរសារណា ២០២១

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ហ៊ុន ចន្នី** និង **ជុន តា** ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញរដ្ឋបាលសាធារណៈ

សូមធ្វើការគោរព និងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ

ដំបូងសូមអរគុណចំពោះ លោកឪពុក អ្នកម្តាយ ទាំងបួនដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាស្រឡាញ់ថ្នាក់ថ្នមដោយយកចិត្តទុកដាក់បានល្អប្រកបដោយព្រហ្មវិហារធម៌មេត្តាអាណិត និងអប់រំនិងផ្តល់ដំបូន្មានប្រៀនប្រដៅ លើកទឹកចិត្ត អោយកូនបានរៀនសូត្រ រហូតមកដល់ឆ្នាំចុងក្រោយនៃថ្នាក់បរិញ្ញាបត្រ ហើយមានការទំនុកបំរុង ទាំងថវិកា នឹងផ្នែកសម្ភារៈសិក្សាជាច្រើនរហូតដល់កូនរៀនចប់។

មួយផ្នែកទៀតសូមអរគុណចំពោះ ឯកឧត្តម **បណ្ឌិត លុយ ចន្ថា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតអោយខ្ញុំទាំងពីរបានចូលរៀន និងយកចិត្តទុកដាក់ និងបង្ករភាពងាយស្រួលក្នុងការរៀនសូត្រ ទោះបីជាមានការរីករាលដាលនៃជម្ងឺកូវីដ-១៩ យ៉ាងណាក៏ដោយ។

ម្យ៉ាងទៀតសូមអរគុណចំពោះ សាស្ត្រាចារ្យណែនាំ **តា សុទ្ធា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹក ក្នុងការបង្ហាត់បង្ហាញផ្លូវក្នុងកិច្ចការស្រាវជ្រាវមួយនេះ នឹងមានការផ្តល់យោបល់ណែនាំដើម្បីឲ្យសារណាមួយនេះបញ្ចប់បានយ៉ាងល្អ។

ម្យ៉ាងវិញទៀតសូមអរគុណចំពោះ **សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ** ដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀនកន្លងមកដល់យើងខ្ញុំ តាំងតែពីការចាប់ផ្តើមសិក្សារហូតមកដល់បច្ចុប្បន្ន។

ជាពិសេសសូមអរគុណយ៉ាងជ្រាវជ្រៅបំផុតចំពោះ អ្នកប្រាជ្ញ បណ្ឌិតបញ្ញាវន្ត ការីនិពន្ធ ទស្សនវិទូនៅលើសកលលោកទាំងអស់ដែលបានបន្សល់ទុកស្នាដៃ និងជាឯកសារដល់យើងខ្ញុំទាំងពីរបានសិក្សាស្រាវជ្រាវ និងដើម្បីជាប្រយោជន៍ក្នុងការបញ្ចប់សារណាមួយនេះ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរសូមប្រសិទ្ធិពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការ ចូរកើតមានដល់ លោកអ្នកដ៏មានគុណ ទ្រង់ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងអ្នកស្រាវជ្រាវទាំងអស់សូមបានជោគជ័យគ្រប់ភារៈកិច្ច សូមជួបប្រទះនូវពុទ្ធពររបស់ព្រះសម្មាសម្ពុទ្ធបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ នឹងសម្បត្តិ៣ សម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ។

អារម្ភកថា

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ការចុះបញ្ជីអត្រានុកូលដ្ឋាននៅមានភាពខ្វះចន្លោះ នឹងត្រូវកែតម្រូវនៅចំណុចខ្វះខាតជាច្រើនដែលកើតមានកន្លងមក ដោយសារតែប្រទេសកម្ពុជាយើងជួបផលវិបាក បញ្ហាសង្គ្រាម ទើបបានបាត់បង់ឯកសារជាច្រើនទៀត។ ប៉ុន្តែប្រទេសជាតិកំពុងតែអភិវឌ្ឍ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន កំណើត និងមរណភាពមានបញ្ហាប្រឈមមួយចំនួន ទើបធ្វើឲ្យការចុះបញ្ជីអត្រានុកូលដ្ឋានមានការយឺតយ៉ាវ។ ដូច្នេះហើយទើបយើងខ្ញុំទាំងពីរនាក់ សម្រេចចិត្តជ្រើសរើសយកប្រធានបទ **អត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន** ដើម្បីសិក្សាស្រាវជ្រាវបន្ថែម រាល់ចំណុចខ្វះចន្លោះទាំងឡាយ យកមកពិភាក្សារកដំណោះស្រាយ និងកែតម្រូវផលវិបាកដែលប្រជាពលរដ្ឋកំពុងជួបប្រទះ និងជួយជំរុញឲ្យពួកគាត់យកចិត្តទុកដាក់ក្នុងការចុះបញ្ជីសៀវភៅអត្រានុកូលដ្ឋាន និងដាស់តឿនដល់មន្ត្រីមូលដ្ឋានឲ្យយល់បន្ថែមអំពីនីតិវិធី នៃការចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋឲ្យទាន់ពេលវេលា។ មួយផ្នែកទៀតសូមឲ្យថ្នាក់លើមានក្រសួងមហាផ្ទៃ និងក្រសួងដែលពាក់ព័ន្ធយកចិត្តទុកដាក់លើការណែនាំឲ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ អំពីការចុះបញ្ជីសៀវភៅអត្រានុកុលដ្ឋាននេះពិតជាមានផលប្រយោជន៍អ្វីខ្លះដល់ពួកគាត់។ ជាពិសេសប្រជាពលរដ្ឋខ្លួនឯងត្រូវយកចិត្តទុកដាក់ចំពោះរឿងនេះឲ្យមែនទែន ពីព្រោះការចុះបញ្ជីអត្រានុកូលដ្ឋានមានសារៈប្រយោជន៍ណាស់ ដើម្បីបញ្ជាក់ពីអត្តសញ្ញាណ និងស្ថិតិអត្រានុកុលដ្ឋាន អំពីកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ណាមួយជាការបំពេញកាតព្វកិច្ចជាពលរដ្ឋល្អជូនប្រទេសជាតិ ដើម្បីងាយស្រួលដល់សមត្ថកិច្ចក្នុងការស្រាវជ្រាវ ប្រសិនបើមានបាត់ខ្លួនដោយប្រការណាមួយ។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាការសិក្សាស្រាវជ្រាវនេះនឹងបានជាឯកសារមួយសម្រាប់មិត្តនិស្សិតជំនាន់ក្រោយដើម្បីសិក្សាយល់ដឹងបន្ថែមពីអត្ថប្រយោជន៍ពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងបញ្ហាដែលប្រទេសកម្ពុជាកំពុងជួបប្រទះ ហើយជួយរកដំណោះស្រាយដើម្បីកែតម្រូវរាល់កន្លែងខ្វះខាតទាំងប៉ុន្មាននោះឲ្យបានប្រសើរជាងមុន និងបានជាចំណេះដឹងមួយចំណែក។

ម្យ៉ាងវិញទៀត សារណានេះនៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារតែចំណេះដឹងនៅមានកម្រិតបទពិសោធន៍នៅខ្ចី ឯកសារមិនគ្រប់គ្រាន់។ ជាពិសេសនោះគឺបញ្ហាកូវីដ-១៩ ដែលធ្វើឲ្យពិបាកស្វែងរកឯកសារមកសិក្សាស្រាវជ្រាវបន្ថែម ដូច្នេះហើយកំហុសខុសឆ្គងនៅតែមានចៀសមិនផុតនោះឡើយ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមខន្តីអភ័យទោសរាល់កំហុសខុសឆ្គងត្រង់ណាមួយកើតឡើងដោយអចេតនា សូមសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតទាំងអស់អធ្យាស្រ័យអនុគ្រោះដោយក្តីមេត្តា ហើយយើងខ្ញុំរីករាយទទួលយករាល់ពាក្យរិះគន់ យកមកកែតម្រូវ ដើម្បីជាប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវលើកក្រោយឲ្យប្រសើរជាងមុន។

មាតិកា

ទំព័រ

សេចក្តីផ្តើម ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ២
៣. គោលបំណងនៃការស្រាវជ្រាវ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី ១

ទិដ្ឋភាពប្រវត្តិ និងទិដ្ឋភាពច្បាប់នៃអត្រានុកូលដ្ឋាន

១.១.ការវិវត្តទៅតាមសង្គម ៤
១.១.១.មុនការដួលរលំនៃរបបរាជានិយមទី១ ..... ៤
១.១.២.ក្រោយសម័យរាជានិយមទី១ និងមុនរាជានិយមទី២ ..... ៤
១.១.៣.ក្រោយការកកើតរាជានិយមកម្ពុជាបច្ចុប្បន្ន ៥
១.២.ទិដ្ឋភាពច្បាប់ ៥
១.២.១.ការវិវត្តនៃច្បាប់ ៥
១.២.២.និយមន័យអត្រានុកូលដ្ឋាន ៧
១.២.៣ ធាតុផ្សំអត្តសញ្ញាណកម្មនៃរូបវន្តបុគ្គល ៨
១.៣.សៀវភៅអត្រានុកូលដ្ឋាន ១១
១.៣.១.ក្រដាសអត្រានុកូលដ្ឋាន ១២
១.៣.២.សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន ១៣
១.៤.ការសរសេរបំពេញសន្លឹកនៃសៀវភៅអត្រានុកូលដ្ឋាន មុននឹងបញ្ជូនទៅឃុំ សង្កាត់ ១៣
១.៤.១.ការសរសេរបំពេញក្របមុខ ១៤
១.៤.២.ការសរសេរចុះលេខរៀងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន ១៤

១.៥.ការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន ១៤
១.៥.១.ថ្នាក់ជាតិ ១៥
១.៥.២.ថ្នាក់ក្រោមជាតិ ១៦

ជំពូកទី ២
នីតិវិធីនៃការលេចឡើងនូវអត្រានុកូលដ្ឋានទាំង ៣ប្រភេទ

២.១.ដំណាក់កាលនៃការកកើតនូវអត្រានុកូលដ្ឋានទាំង ៣ប្រភេទ ២៤
២.១.១.អត្រានុកូលដ្ឋានកំណើត ២៤
២.១.២.អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ៣០
២.១.២.អត្រានុកូលដ្ឋានមរណភាព ៤០
២.២.សារៈប្រយោជន៍នៃលិខិតអត្រានុកូលដ្ឋាន ៤៦
២.២.១.សារៈប្រយោជន៍ចំពោះសង្គមជាតិ ៤៦
២.២.២. សារៈប្រយោជន៍ចំពោះខ្លួនឯង ៤៦

ជំពូកទី ៣
បញ្ហាចោទឡើងផ្សេងៗ និងវិធីដោះស្រាយ

៣.១.កំណែតម្រូវ និងការសុំមោឃភាពទិន្នន័យ ៤៨
៣.១.១.អំពីទិន្នន័យដែលអាចកែតម្រូវបាន ៤៩
៣.១.២.អំពីសមត្ថកិច្ច ៤៩
៣.១.៣.អំពីនីតិវិធី ៥០
៣.២.កំណែតម្រូវ និងការធ្វើមោឃភាព ៥១
៣.២.១.បញ្ហាប្រឈមដែលប្រជាពលរដ្ឋជួបប្រទះញឹកញាប់ ៥៣
៣.២.២.ដំណោះស្រាយចំពោះបញ្ហា ៥៤
សេចក្តីសន្និដ្ឋាន ៥៦
អនុសាសន៍ ៥៧
ឯកសារយោង
ឧបសម្ព័ន្ធ

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានឆ្លងកាត់ការផ្លាស់ប្តូររបបនយោបាយ ក៏ដូចជាសង្គ្រាមផ្ទៃក្នុង និងសង្គ្រាមជាមួយប្រទេសជិតខាងជាច្រើនលើកច្រើនសារ។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត បានធ្វើឲ្យប្រទេសជាតិទទួលរងវិនាសកម្មយ៉ាងធំធេងបំផុតពោលគឺ របបនោះត្រូវបានគេហៅថារបបប្រល័យពូជសាសន៍។ ជាភ័ព្វសំណាង ការតស៊ូរបស់វីរជននៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរំដោះកម្ពុជាឲ្យរួចផុតពីរបបដ៏ខ្មៅងងឹតនេះ ដោយជោគជ័យនៅថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៧៩។ ក្រោយមកការខិតខំប្រឹងប្រែងបានធ្វើឡើងឥតឈប់ឈររបស់ថ្នាក់ដឹកនាំប្រទេសកម្ពុជា បានធ្វើឲ្យការរៀបចំប្រទេសពីបាតដៃទទេ រហូតក្លាយទៅជាប្រទេសមួយដែលមានអធិបតេយ្យ និងមានការទទួលស្គាល់ពីមជ្ឈដ្ឋានអន្តរជាតិ។

ការផ្តល់សេវាអត្រានុកូលដ្ឋាន គឺជាការផ្តល់ឯកសារគតិយុត្តិដល់ប្រជាពលរដ្ឋដើម្បីប្រើប្រាស់បញ្ជាក់ពីភស្តុតាងនៃហេតុការណ៍ដែលកើតឡើងជុំវិញព្រឹត្តិការណ៍អត្រានុកូលដ្ឋាន។ សេវាសាធារណៈមួយនេះត្រូវបានប្រើប្រាស់ និងអនុវត្តន៍ក្នុងប្រទេសរបស់យើងជាច្រើនឆ្នាំកន្លងមកហើយ គឺវាបានផ្សារភ្ជាប់ទៅនឹងសកម្មភាពជាច្រើននៃការបម្រើប្រយោជន៍ទូទៅ ទាំងនេះគឺជាទ្រព្យសម្បត្តិសាធារណៈដែលចាំបាច់ និងជាផលប្រយោជន៍សម្រាប់បុគ្គលម្នាក់ៗ និងសង្គមជាតិ។ ហើយសកម្មភាពទាំងនេះភាគច្រើនត្រូវបានបំពេញដោយរដ្ឋផ្ទាល់តែម្តងក្រោយមកទើបគេឃើញមានក្រសួងដែលពាក់ព័ន្ធត្រូវបានចេញសេចក្តីណែនាំបន្ថែម ដើម្បីកែតម្រូវកន្លែងខ្វះខាតក្នុងការបំពេញសេវាទាំងនេះហើយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ។ ពេលខ្លះវាអាចប្រែប្រួលទៅតាមតម្រូវការ និងការរីវត្តរបស់សង្គម ហើយរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ជូនប្រជាពលរដ្ឋរបស់ខ្លួន។

រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្នបានដាក់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានរួចមកហើយក្នុងគោលបំណងបង្កើតឲ្យមានការវាយតម្លៃទូលំទូលាយពីប្រព័ន្ធស្ថិតិ នៃការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ប្រទេសកម្ពុជា ដូចជា៖ ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។ ហើយប្រព័ន្ធនេះត្រូវបានប្រើប្រាស់ក្នុងប្រទេសដែលកំពុងអភិវឌ្ឍ ដែលកំណើត និងមរណភាពទាំងអស់ត្រូវបានចុះបញ្ជី និងបញ្ជាក់ជាប្រចាំ គឺត្រូវធ្វើការត្រួតពិនិត្យឡើងវិញពីស្ថានភាពបច្ចុប្បន្ន ជាមួយការកំណត់ពីផ្នែកដែលទាមទារធ្វើឲ្យប្រសើរឡើងនូវសកម្មភាពជាអាទិភាព។ ដូច្នេះវាងាយស្រួលដល់រដ្ឋាភិបាលដែលប្រើប្រាស់សម្រាប់រៀបចំផែនការសង្គម និងសេដ្ឋកិច្ចរួមមានវិស័យសុខាភិបាល អប់រំ ការងារ និងអចលនទ្រព្យ។ ការវាយតម្លៃនេះផ្តោតសំខាន់លើកំណើត មរណភាព និងមូលហេតុនៃការស្លាប់ រួមបញ្ចូលក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន ការចុះបញ្ជី លិខិតបញ្ជាក់ និងការអនុវត្ត

ការចុះលេខកូដ ព្រមទាំងការចងក្រងរៀបចំ និងប្រើប្រាស់លទ្ធផលទិន្នន័យ ពីព្រោះនេះ ជាមូលដ្ឋានក្នុងការណែនាំកម្មវិធីសុខុមាលភាពសាធារណៈការត្រួតពិនិត្យលើប្រជាសាស្ត្រ និងស្ថិតិការរស់នៅរបស់ប្រជាពលរដ្ឋ។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមប្រធានបទខាងលើ **ស្តីពីអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន** ក្រុមយើងខ្ញុំយល់ឃើញថា ការចុះបញ្ជីអត្រានុកូលដ្ឋានបច្ចុប្បន្នប្រជាពលរដ្ឋមួយចំនួននៅមិនទាន់មានការយល់ដឹងច្រៅច្រះនោះទេ ជាពិសេសជនអន្តោប្រវេសន៍ និងជនបរទេស។ ដូច្នេះ ដោយឃើញកត្តាទាំងនេះកើតមានឡើង ទើបក្រុមយើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ ហើយបានដាក់ចំណោទបញ្ហាខ្លះៗសម្រាប់ឲ្យរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវដោះស្រាយ មានដូចជា៖

១.តើការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវបំពេញលក្ខខណ្ឌដូចម្តេចខ្លះ?

២.តើការផ្តល់ជូនអត្រានុកូលដ្ឋានដល់ប្រជាពលរដ្ឋរបស់ខ្លួន និងជនអន្តោប្រវេសន៍ និងជនបរទេសមានសារៈប្រយោជន៍អ្វីខ្លះ?

៣.តើការចុះបញ្ជីអត្រានុកូលដ្ឋានពីមុនមក និងបច្ចុប្បន្នប្រជាពលរដ្ឋ និងរដ្ឋាភិបាលបានអនុវត្តដល់កម្រិតណាហើយ ?

៤.តើបទដ្ឋានគតិយុត្តដែលទាក់ទងនឹងអត្រានុកូលដ្ឋានមានអ្វីខ្លះ?

៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវ នូវប្រធានបទមួយនេះ គឺមានគោលបំណងដូចជា៖

- ដើម្បីទទួលបានចំណេះដឹងថ្មី ដែលពាក់ព័ន្ធទៅនឹងអត្រានុកូលដ្ឋាន និងបានស្វែងយល់ពីរលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។
- ដើម្បីរកបទពិសោធន៍បន្ថែម និងជួយពង្រីកសមត្ថភាពរបស់ខ្លួនផងដែរ។
- ដើម្បីរកឲ្យឃើញអំពីគុណភាពនៃការផ្តល់សេវា អត្រានុកូលដ្ឋាន ភាពខ្វះចន្លោះ តម្រូវការបន្ថែមរបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមមួយចំនួនដែលកើតមានឡើង ក្នុងការអនុវត្តន៍ការងារ។

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណា **អំពីអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន** មួយនេះឡើងដើម្បីឈ្វេងយល់អំពីការផ្តល់សេវាអត្រានុកូលដ្ឋាននៅក្នុងប្រទេសរបស់យើង។ ទំហំនៃការស្រាវជ្រាវប្រធានបទមួយនេះ គឺផ្អែកតាមគោលការណ៍លិខិតគតិយុត្តដែលពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន រួមមានជាគោល

អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ និងសេចក្តីណែនាំផ្សេងៗរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានអនុវត្តន៍កន្លងមកហើយ និងស្វែងរកបណ្តាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗតាមប្រព័ន្ធអ៊ីនធឺណេត (internet) ជាដើម។ ចំពោះវិសាលភាពនៃការស្រាវជ្រាវនូវសារណាមួយនេះ គឺផ្តោតទៅលើការចុះបញ្ជីអត្រានុកូលដ្ឋានទាំងបី និងនីតិវិធីក្នុងការចុះបញ្ជី។

៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ ក្រុមយើងខ្ញុំផ្ទាល់ យល់ឃើញថា ពិតជាមានសារៈសំខាន់ណាស់ សម្រាប់ចូលរួមបំពេញសេចក្តីត្រូវការរបស់អ្នកសិក្សាស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះកង្វះខាតនាពេលបច្ចុប្បន្ននេះ។ មួយចំណែកទៀត ដើម្បីឈ្វេងយល់អំពីការគ្រប់គ្រងស្ថិតិរបស់ប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានឲ្យកាន់តែមានភាពច្បាស់លាស់ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ ឬជួយពន្យល់ទៅប្រជាពលរដ្ឋដើម្បីឲ្យមានការចូលរួមបន្ថែមទាក់ទងអត្រានុកូលដ្ឋាននេះ តាមរយៈឯកសារសារណាមួយនេះ។

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីបានសមិទ្ធផលនៃស្នាដៃមួយនេះឡើងបានមកពីការដកស្រង់ចេញពីសៀវភៅផ្សេងៗដែលទាក់ទងទៅនឹងប្រធានបទ និងប្រមូលបានពីលិខិតគតិយុត្តដែលមានដូចជាៈច្បាប់, អនុក្រឹត្យ, សេចក្តីប្រកាស, សេចក្តីណែនាំ, របាយការណ៍, ព្រមទាំងឯកសារដែលចេញពីក្រសួង រដ្ឋាភិបាល និងសារណាសិស្សច្បងនៅតាមបណ្ណាល័យនានា ព្រមទាំងតាមរយៈគេហទំព័រ ។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយការសិក្សាស្រាវជ្រាវប្រធាននេះ ក្រុមយើងខ្ញុំបានពិភាក្សាគ្នាចប់សព្វគ្រប់ហើយ យើងខ្ញុំបែងចែករចនាសម្ព័ន្ធជាបីជំពូកធំៗ ដែលមានដូចខាងក្រោម៖

សេចក្តីផ្តើម

ជំពូកទី ១ ទិដ្ឋភាពប្រវត្តិ និងទិដ្ឋភាពច្បាប់នៃអត្រានុកូលដ្ឋាន

ជំពូកទី ២ នីតិវិធីនៃការលេចឡើងនូវអត្រានុកូលដ្ឋាន ៣ប្រភេទ

ជំពូកទី ៣ បញ្ហាចោទឡើងផ្សេងៗ និងវិធីដោះស្រាយ

សេចក្តីសន្និដ្ឋាន

អនុសាសន៍

ឯកសារយោង

ឧបសម្ព័ន្ធ

ជំពូកទី ១
ទិដ្ឋភាពប្រវត្តិ និងទិដ្ឋភាពច្បាប់នៃអត្រានុកូលដ្ឋាន

១.១.ការវិវត្តទៅតាមសង្គម

ដោយសារតែការវិវត្តនៃសង្គម និងមានការផ្លាស់ប្តូររបបអ្នកដឹកនាំនីមួយៗ ដោយជួបបញ្ហាវិបត្តិសង្គ្រាមជាបន្តបន្ទាប់ ទើបធ្វើឲ្យប្រជាជនកម្ពុជា បាត់បង់ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត។ ទាំងនេះហើយដែលបង្កឲ្យប្រទេសកម្ពុជាបានជួបការលំបាកជាច្រើនដូចជា កុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ ព្រៃត់ប្រាស់គ្រួសារជាពិសេសនោះ ធ្វើឲ្យបាត់បង់ឯកសារ សម្គាល់ខ្លួន នាំឲ្យមានការភាន់ច្រឡំ និងបង្កឲ្យមានភាពរញ៉េរញ៉ៃនៅក្នុងសង្គម ហើយមានការធ្លាក់ចុះ ទើបធ្វើឲ្យឯកសារអត្រានុកូលដ្ឋានមួយចំនួនត្រូវបានបាត់បង់។ បន្ទាប់មកប្រទេសកម្ពុជាមានការវិវត្តខ្លួនបន្តិចម្តងៗ នៅពេលដែលមានការផ្លាស់ប្តូររបបដឹកនាំ នាសម័យបច្ចុប្បន្នរាជរដ្ឋាភិបាលក៏បានរៀបចំអត្រានុកូលដ្ឋានបានល្អប្រសើរជាងមុនដោយមានការកែតម្រូវនូវចំណុចខ្វះខាតដែលជាបញ្ហារាំងស្ទះសម្រាប់ប្រជាពលរដ្ឋក្នុងការសុំចុះអត្រានុកូលដ្ឋាន។

១.១.១.មុនការដួលរលំនៃរបបរាជានិយមទី១

នៅក្នុងការកកើតឡើងនៃអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មុនសង្គ្រាមស៊ីវិលប្រទេសកម្ពុជាធ្លាប់មានក្នុងមូលដ្ឋានច្បាប់ (ក្រមរដ្ឋប្បវេណីចាស់) ចាប់តាំងពីឆ្នាំ ១៩២០ មកម្ល៉េះ ចាប់ពីមាត្រា ២៨-៧០ នៃជំពូកទី២។ ឃើញដូចនេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានដាក់ចេញសេចក្តីណែនាំរួមមួយសម្រាប់ទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។ នៅពេលនោះ ការអនុវត្តន៍ដំណើរការបានល្អ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការអនុវត្តនេះមិនបានទូលំទូលាយទូទាំងប្រទេសទេចំពោះប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាលនៅតែមិនមានសំបុត្រអត្រានុកូលដ្ឋានប្រើប្រាស់ឡើយ។[1]

១.១.២.ក្រោយសម័យរាជានិយមទី១ និងមុនរាជានិយមទី២

បន្ទាប់ពីសង្គ្រាមស៊ីវិលនៅកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩។ សង្គ្រាមបានចាប់ផ្តើមនៅវៀតណាមនៅឆ្នាំ១៩៥៥ ហើយទីបំផុតបានរីកសាយភាយដល់កម្ពុជា និងឡាវ ជាពិសេសនៅតាមតំបន់ព្រំដែនរបស់ប្រទេសទាំងពីរនេះជាប់នឹងវៀតណាម ដែលអាមេរិកបានទម្លាក់គ្រាប់បែកមកលើយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីមានទំនាស់ផ្ទៃក្នុងជាច្រើនដំណាក់កាល ជាពិសេសដំណាក់កាលបដិវត្តន៍របស់ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបណ្តាលឲ្យទ្រព្យសម្បត្តិឯកជននានាត្រូវបានបំផ្លាញនៅក្នុងប្រទេសទាំងមូលអស្ថិរភាពនយោបាយកើតឡើង និងការអនុវត្តន៍ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅមានកម្រិត បន្ទាប់មកនៅក្នុងអំឡុងពេលរបបដឹកនាំ

[1] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩២០

របស់ខ្មែរក្រហមការងារអត្រានុកូលដ្ឋាន ត្រូវបានលុបបំបាត់ចោលទាំងស្រុង ហើយឯកសារទាំងអស់ដែលពាក់ព័ន្ធ នឹងការងារអត្រានុកូលដ្ឋានត្រូវបានយកទៅបំផ្លាញចោលទាំងអស់ ឯកសាររដ្ឋបាលដែលទាក់ទងនឹងអត្រានុកូលដ្ឋានជាច្រើនត្រូវបានបាត់បង់ និងការបាត់បង់ឯកសារគតិយុត្តិផ្សេងៗទៀត ដែលកើតមានក្នុងរបបខ្មែរក្រហម។ នៅឆ្នាំ១៩៩០ គ្រប់ភាគីជម្លោះនៅកម្ពុជាបានចុះកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។[2]

១.១.៣.ក្រោយការកើតរាជានិយមកម្ពុជាបច្ចុប្បន្ន

បន្ទាប់ពីបានបញ្ចប់សង្គ្រាមស៊ីវិល រហូតមកដល់ឆ្នាំ២០០២ ការងារអត្រានុកូលដ្ឋានត្រូវបានចាប់ដំណើរការឡើងវិញនៅទូទាំងប្រទេស។ ទោះបីជាយ៉ាងនេះក៏ដោយ ការចុះបញ្ជី និងទម្រង់បែបបទនៃការអនុវត្តមិនមានការឯកភាពគ្នា ហើយការអនុវត្តចុះបញ្ជីនៅក្នុងប្រទេសមានភាពផ្សេងៗគ្នា ពីខេត្តមួយទៅខេត្តមួយ ទោះបីក្នុងពេលនេះ មានការធ្វើឡើងវិញនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានក៏ដោយ ក៏ប្រជាជនខ្លះនៅតែមិនបានចុះបញ្ជីអត្រានុកូលដ្ឋាន ទើបរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតក្របខណ្ឌច្បាប់ សម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រទេស តាមរយៈអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ហើយបានដាក់ឲ្យអនុវត្តន៍នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២។ ដូច្នេះហើយ ទើបធ្វើឲ្យក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានអត្រានុកូលដ្ឋានបានរៀបចំឲ្យមន្ត្រីជំនាញ ទៅធ្វើការបណ្តុះបណ្តាល ឬចេញសេចក្តីណែនាំ និងមានការចងក្រងជាសៀវភៅដែលទាក់ទងនឹងការងារអត្រានុកូលដ្ឋាន ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈឲ្យមានការយល់ដឹង ក្នុងគោលបំណងផ្តល់ឲ្យប្រជាពលរដ្ឋទាំងអស់មានលទ្ធភាពចុះសំបុត្រអត្រានុកូលដ្ឋានគ្រប់ៗគ្នា។[3]

១.២.ទិដ្ឋភាពច្បាប់

១.២.១.ការវិវត្តនៃច្បាប់

ប្រទេសកម្ពុជាយើង នាពេលបច្ចុប្បន្ននេះពុំទាន់មានច្បាប់ស្តីពីអត្រានុកូលដ្ឋាននៅឡើយទេ ដូច្នេះក្រសួងមហាផ្ទៃ ព្រមទាំងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងនាយកដ្ឋានអត្រានុកូលដ្ឋានដែលមានតួនាទីធ្វើសេនាធិការ លើការងារអត្រានុកូលដ្ឋានសព្វថ្ងៃកំពុងតែធ្វើសេចក្តីព្រាងច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ស្តីពីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម មាន១២ជំពូក និង១៦៩មាត្រា។ ច្បាប់នេះមានគោលបំណងដូចជា៖

១-ធានាឲ្យមានការចុះបញ្ជីអត្រានុកូលដ្ឋាន ជាកាតព្វកិច្ចជាសកលដោយជាប់លាប់ និងជាអចិន្ត្រៃយ៍។

[2] របាយការណ៍ប្រចាំថ្ងៃប្រទេសរបស់ធនាគារពិភពលោក (តើប្រជាពលរដ្ឋក្រីក្រទៅទីណាអស់ហើយ?ការវាយតម្លៃភាពក្រីក្រឆ្នាំ២០១៣)

[3] សៀវភៅ ការវាយតម្លៃលើគុណភាព និងការប្រើប្រាស់ព័ត៌មានកំណើត និងមរណភាព និងមូលហេតុនៃការស្លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-ធានាឲ្យមានការចុះបញ្ជីអត្តសញ្ញាណបុគ្គល ជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍។

៣-ធានាថា ការចុះបញ្ជីស្នាក់នៅ ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍។

៤-ធានាឲ្យមនុស្សគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់ តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះបញ្ជីអត្តសញ្ញាណ ដោយផ្តល់ចំពោះបុគ្គលម្នាក់ៗ នូវលេខសម្គាល់អត្តសញ្ញាណបុគ្គល។

៥-ធានាការគោរពសិទ្ធិមនុស្ស ការទទួលបានសេវាគ្រប់ប្រភេទ ហើយជាមូលដ្ឋាន សម្រាប់រៀបចំផែនការអភិវឌ្ឍ និងការតាមដានភាពរីកចម្រើននៃសង្គម។

ជាងនេះទៅទៀត ច្បាប់នេះមានវិសាលភាព អនុវត្តន៍ចំពោះជនគ្រប់រូបដែលនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ដែលរស់នៅឯបរទេស។ ប៉ុន្តែនៅមិនទាន់មានការអនុម័តពីសភានៅឡើយទេ។ នៅពេលដែលពុំទាន់មានច្បាប់ស្តីពីអត្រានុកូលដ្ឋានក៏ដោយ ក៏មានលិខិតបទដ្ឋានគតិយុត្ត ឬអនុក្រឹត្យដែលជាមូលដ្ឋានច្បាប់សម្រាប់អនុវត្តន៍ការងារអត្រានុកូលដ្ឋាននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ មានដូចជា៖

- ច្បាប់ស្តីពីសញ្ជាតិ
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- ច្បាប់ស្តីពីអន្តោប្រវេសន៍
- ច្បាប់ស្តីពីការស្នុំកូន
- អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០
- អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការកែសំរួលមាត្រា៨ និងមាត្រា២៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អនុក្រឹត្យអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រឹ៍សារពើពន្ធ
- អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ស្តួនថ្មីនៃ អនុក្រឹត្យលេខ១៧ អនក្រ.បក

- អនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្នូននៃ អនក្រ.បក លេខ១០៦
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពី ការកែសំរួលមាត្រា៩ និង មាត្រា៥២ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អនុក្រឹត្យ អត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សេចក្តីណែនាំអន្តរក្រសួងលេខ០១០ សណន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការកែតម្រូវ និងបំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ
- សេចក្តីណែនាំលេខ០០៨ សណន ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋាន ឲ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត
- សេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់អនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សេចក្តីណែនាំលេខ០១៥ សណន ចុះថ្ងៃ សណន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការចេញលិខិតរដ្ឋបាល និង លិខិតអត្រានុកូលដ្ឋានឲ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍
- សេចក្តីណែនាំលេខ០៣៥ សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន
- សេចក្តីណែនាំលេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៩ ស្តីពីការបន្តដំណើរការកែតម្រូវ និងធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន
- ប្រកាសលេខ១០៨៦ ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះការិយាល័យកិច្ចការទូទៅ ជាការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋានចំណុះ សាលាខេត្ត ក្រុង។

១.២.២.និយមន័យអត្រានុកូលដ្ឋាន

ពាក្យថាអត្រានុកូលដ្ឋាន គឺជាពាក្យផ្សំពីបាលីសំស្ក្រឹតដែលបានពីពាក្យថា៖

អត្រ < អត្តៈ មានន័យថាខ្លួន

អនុកូលៈ មានន័យថាអនុឡោមតាម

ឋានៈ មានន័យថាទីតាំង ទីកន្លែង ទីតាំងនៅ

នាំឲ្យយើងអាចទាញរកអត្ថន័យនៃពាក្យផ្សំនេះបានថា (អត្រ+អនុកូល+ដ្ឋាន) គឺជាការចុះនូវស្ថានភាពនៃភាពស៊ីវិលរបស់ពលរដ្ឋនីមួយៗ អំពីការចាប់កំណើត ការរៀបអាពាហ៍ពិពាហ៍ និងការទទួលមរណភាព។[4] ពាក្យនេះក៏ត្រូវបានឲ្យនិយមន័យ ដែលមានចែងក្នុងអនុក្រឹត្យលេខ ១០៣ អនក្រ. បក ស្តីពី អត្រានុកូលដ្ឋានចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ គឺ **ជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលជននោះមាននៅក្នុងក្រកូលគ្រួសារខ្លួនក្នុងសង្គមជាតិ និងបានបង្កើតឲ្យជននោះមានសិទ្ធិ និងកាតព្វកិច្ច**។ ដូចនេះ ការចុះសំបុត្រអត្រានុកូលដ្ឋាន គឺជាការផ្តល់នូវឯកសារគតិយុត្តដ៏សំខាន់ចាំបាច់ ជូនប្រជាពលរដ្ឋខ្មែរគ្រប់រូប និងជនបរទេសដែលរស់នៅស្របច្បាប់ក្នុងដែនសមត្ថកិច្ចដែលកំណត់ដោយច្បាប់ព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។[5] ដើម្បីជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរស់នៅរបស់មនុស្សម្នាក់ៗ ឬទុកជាលិខិតតូបករណ៍ដែលអាចយកមកប្រើប្រាស់ក្នុងពេលចាំបាច់ នឹងជាសក្ខីភាពមួយដែលសម្រាប់បញ្ជាក់ពីអត្តសញ្ញាណពិតប្រាកដ។ សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ ពាក្យថាអត្រានុកូលដ្ឋាន គឺក្តៅបរួមទាំង ការចុះសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍និងសំបុត្រមរណភាព គឺមានន័យស្មើនឹងពាក្យការ ចុះ **អត្តាស៊ីវិល** ឬ **សៀវភៅអត្រានុកូលដ្ឋាន។**ទាំងអស់នេះ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវអនុវត្តន៍។

ចំណាំ ៖ ការកត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ និងមរណភាពត្រូវបានរដ្ឋរៀបចំជាប្រព័ន្ធកត់ត្រាផ្លូវការមានលក្ខណៈឯកភាពទូទាំងប្រទេស ដែលហៅថា **ការចុះបញ្ជីអត្រានុកូលដ្ឋាន**។

១.២.៣ ធាតុផ្សំអត្តសញ្ញាណភាពនៃរូបវន្តបុគ្គល

ក.ឈ្មោះ

មនុស្សគ្រប់រូបកើតមកត្រូវតែមានឈ្មោះ។ ឈ្មោះមានលក្ខណៈមិនប្រែប្រួល មានលក្ខណៈជាប់លាប់ និងគ្មានអាជ្ញាយុកាល។ មនុស្សកើតមកត្រូវគេដាក់ឈ្មោះដោយកំណត់តាមពីររបៀបគឺ៖

- តាមបុត្តភាព៖ ទារកកើតមកត្រូវដាក់ឈ្មោះឲ្យទារកនោះជាចាំបាច់ ដោយយកនាមត្រកូលតាមលក្ខខណ្ឌដូចខាងក្រោម៖

[4] វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត បោះពុម្ពលើកទី៥

[5] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន មាត្រា២-៣

- កូនមានខាន់ស្លា ៖ នាមត្រកូលអាចយកត្រកូលដែលក្រុមគ្រួសារបានកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬយកឈ្មោះជីតាខាងឪពុក។
- កូនឥតខាន់ស្លា ៖ បើឪពុកម្តាយទទួលស្គាល់ទាំងពីរ គឺយកនាមត្រកូលខាងឪពុក។ បើមានតែឪពុក ឬម្តាយទទួលស្គាល់តែម្នាក់ឯង នាមត្រកូលត្រូវយកនាមត្រកូលអ្នកដែលទទួលស្គាល់ថាជាកូន។
- កូនសុំពេញលេញ ៖ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន។

➢ តាមរយៈអាពាហ៍ពិពាហ៍ ៖ នៅពេលរៀបអាពាហ៍ពិពាហ៍ ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធអាចប្រើនាមត្រកូលដើមរៀងខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។

ខ.លំនៅឋាន

អត្ថន័យនៃលំនៅឋាន៖ កន្លែងដែលជាទីតាំងជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន

ទីសំណាក់៖ ក្នុងករណីកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន។

ករណីដែលគ្មានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅ។ ប៉ុន្តែប្បញ្ញតិនេះ មិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់លំនៅឋានត្រូវបានយកមកអនុវត្តន៍។

លំនៅឋានរបស់មនុស្សម្នាក់ គឺជាកន្លែងដែលអ្នកនោះបានកំណត់ការស្នាក់នៅរបស់ខ្លួនជាទម្លាប់របស់គេ ហើយជាទីតាំងដ៏សំខាន់នៃកិច្ចការ និងជីវភាពរស់នៅរបស់គេជាប្រចាំ។ លំនៅឋានត្រូវកំណត់យកមួយគត់ ព្រោះជាកន្លែងដែលភ្ជាប់បុគ្គលិកលក្ខណៈគតិយុត្តនៃរូបវន្តបុគ្គលទៅលំនៅឋាននោះ។

ការកំណត់លំនៅឋានច្បាស់លាស់របស់បុគ្គលម្នាក់ៗ គឺផ្តល់ភាពងាយស្រួលក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ហើយទាំងនេះ គឺមានច្បាប់ការពារផងដែរ។

គ.សញ្ជាតិ

សញ្ជាតិ គឺជាចំណងគតិយុត្តនិងនយោបាយដែលផ្សារភ្ជាប់រូបវន្តបុគ្គល ឬនីតិបុគ្គលទៅនឹងរដ្ឋអធិបតេយ្យមួយ។ សញ្ជាតិខ្មែរ គឺជាចំណងខាងផ្លូវចិត្ត ខាងផ្លូវច្បាប់ និងខាងផ្លូវនយោបាយ ដែលភ្ជាប់រូបវន្តបុគ្គល ឬនីតិបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា។[6] ភាពដែលអាចទទួលបានសញ្ជាតិខ្មែរ តាមរយ ៖

គ.១ សញ្ជាតិពីកំណើត

- **ត្រូវបានសញ្ជាតិខ្មែរ ទោះកើតនៅទីណាក៍ដោយ៖**
  - កូនមានខាន់ស្លាដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ
  - កូនឥតខាន់ស្លាដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់ ឬ
  - កូនដែលឪពុក ឬម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ។[7]
- **ត្រូវបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖**
  - កូនដែលកើតពីឪពុក និងម្តាយជាជនបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា។
  - កូនដែលកើត ម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ។
  - ត្រូវបានសញ្ជាតិខ្មែរដោយរៀបអាពាហ៍ពិពាហ៍ ៖ ស្ត្រី ឬបុរសជាជនបរទេសដែលយកប្តី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះត្រាណាតែស្ត្រី ឬបុរសនោះរស់នៅជាមួយគ្នារយៈពេល (បីឆ្នាំ) ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍។ បែបបទ នីងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយ អនុក្រឹត្យ។ ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិត្រូវសម្រេចដោយព្រះរាជាក្រឹត្យ។

គ.២ សញ្ជាតិខ្មែរដោយការស្នុំកូនពេញលេញ

កូនជនបរទេសអាចទទួលបានសញ្ជាតិខ្មែរបានតាមរយៈការស្នុំកូនពេញលេញអំពីសហព័ទ្ធដែលជាពលរដ្ឋខ្មែរស្របទៅតាមច្បាប់ជាធរមាន។[8]

គ.៣ ការទទួលបានសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍

[6] ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ជំពូកទី១ មាត្រា៣
[7] ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ជំពូកទី៥ មាត្រា៩
[8] ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ជំពូកទី៤ មាត្រា១០

ការទទួលបានសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ គឺបុរស ឬស្ត្រីដែលជាជនបរទេសបានរៀបអាពាហ៍ពិពាហ៍ជាមួយ បុរស ឬស្ត្រីជាជនជាតិខ្មែរបានលុះត្រាតែបានរស់នៅជាមួយគ្នាអស់រយៈពេលបីឆ្នាំ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍រួច។ ហើយម្យ៉ាងទៀត បុរស ឬស្ត្រីនោះលុះត្រាតែបានស្នាក់នៅមួយឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជានឹងបានបំពេញទៅតាមលក្ខន្តិកៈច្បាប់ដែលមានចែងក្នុងមាត្រាច្បាប់ ស្តីពីសញ្ជាតិ របស់ប្រទេសកម្ពុជាទៀតផង។[9]

គ.៤ សញ្ជាតូបនីយកម្ម

ជនបរទេស ដែលអាចចូលសញ្ជាតិខ្មែតាមរយៈ សញ្ជាតូបនីយកម្មនេះ គឺមិនមែនសិទ្ធអ្នកស្នើសុំឡើយ។ ការចូលសញ្ជាតិខ្មែរតាមរយៈ សញ្ជាតូបនីយកម្មបានលុះត្រាតែមានការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជា ហើយប្រទេសកម្ពុជាអាចបដិសេធពាក្យស្នើសុំបានផងដែរ។ ម្យ៉ាងទៀតការចូលសញ្ជាតិខ្មែរតាមរយៈ សញ្ជាតូបនីយកម្មបាន លុះត្រាតែជនបរទេសបានបំពេញទៅតាមលក្ខន្តិកៈច្បាប់របស់ប្រទេសកម្ពុជាផងដែរ។[10]

១.៣.សៀវភៅអត្រានុកូលដ្ឋាន

ក.ប្រភេទសៀវភៅអត្រានុកូលដ្ឋាន រួមមាន៖

- សៀវភៅអត្រានុកូលដ្ឋានកំណើត
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្តក្នុងអំឡុងឆ្នាំ២០០២-២០០៧)
- សៀវភៅអត្រានុកូលដ្ឋានមរណភាព
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព (បានអនុវត្តក្នុងអំឡុងឆ្នាំ២០០២-២០០៧)
- សៀវភៅអត្រានុកូលដ្ឋានកំណើតជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានមរណភាពជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់។

សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវសរសេរជា ២ក្បាល ឬ (ហៅថាសៀវភៅភ្លោះ) ដែលមានខ្លឹមសារស្របគ្នាទាំងក្រសួងតាមប្រភេទសៀវភៅនីមួយៗ។

[9] ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ជំពូកទី៥ មាត្រា១១-១៧

[10] ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ជំពូកទី៦ មាត្រា១៨-២៧

ខ.ចំពោះករណីបាត់បង់ និងការខូចខាតសៀវភៅអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវស្តីពីការបាត់បង់ ឬខូតខាតនេះ ផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ជាបន្ទាន់ដោយបញ្ជូនតាមរយៈសាលាក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តសាមី។ ចំពោះសាមីខ្លួនវិញប្រសិនបើមានករណីបាត់សំបុត្រអត្រានុកូលដ្ឋានណាមួយ ខ្លួនផ្ទាល់ត្រូវទៅរាយការណ៍ជាលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់ នៅសាលាឃុំ សង្កាត់ដែលខ្លួនរស់នៅ អំពីមូលហេតុនៃការបាត់បង់នេះ និងមានបញ្ជាក់ពីឈ្មោះ ឃុំ ឬសង្កាត់ លេខរៀងសៀវភៅ លេខបញ្ជី និងថ្ងៃ ខែ ឆ្នាំ ដែលបានចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន គឺដើម្បីជាព័ត៌មានឲ្យមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រួលក្នុងការស្វែងរកឲ្យ។

១.៣.១.ក្រដាសអត្រានុកូលដ្ឋាន

ដើម្បីធ្វើការទប់ស្កាត់ ចំពោះការក្លែងបន្លំទាំងឡាយ សមត្ថកិច្ចដែលពាក់ព័ន្ធ គ្រប់រាជធានីខេត្តត្រូវទទួលក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទពីក្រសួងមហាផ្ទៃដែលបានផ្តល់ឲ្យ ដើម្បីចាត់ចែងទៅឲ្យក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ប្រើប្រាស់។ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទពុំអនុញ្ញាតឲ្យបោះពុម្ព ឬស្តេន ឬថតចម្លងផ្សេងទៀតនោះឡើយ ក្រៅពីក្រសួងមហាផ្ទៃដែលជាអ្នកផ្គត់ផ្គង់ជូនឲ្យ និងរាល់ការថតចម្លង និងស្តេន មិនមានតម្លៃជាផ្លូវការនោះទេ។

❖ **ក្រដាសអត្រានុកូលដ្ឋានរួមមាន៖**

- សំបុត្រកំណើត
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ)
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ)
- សំបុត្រអាពាហ៍ពិពាហ៍
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្ត២០០២-២០០៧ បច្ចុប្បន្នមិនអនុញ្ញាតឲ្យអនុវត្តន៍ឡើយ)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់ នៅក្រុង ស្រុក ខណ្ឌ)

- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព (បានអនុវត្ត២០០២-២០០៧ បច្ចុប្បន្នមិនអនុញ្ញាតឲ្យអនុវត្តន៍ឡើយ)
- សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់ នៅក្រុង ស្រុក ខណ្ឌ)។

១.៣.២.សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន

❖ **សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន រួមមាន៖**

- សៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត
- សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
- សៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព

❖ **សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវ៖**

- អនុវត្តន៍តែមួយក្បាល (មិនធ្វើពីរក្បាល ឬជាភ្លោះ) ដូចសៀវភៅអត្រានុកូលដ្ឋានឡើយ។
- ចុះលេខរៀងតាមប្រភេទនីមួយៗ និងតាមឆ្នាំនីមួយៗ ដោយផ្តើមពីលេខរៀង០១ ពេលអនុវត្តន៍ដំបូងគេបំផុត (នៅដើមឆ្នាំ) ហើយចុះលេខរៀងបន្តបន្ទាប់ រហូតដល់ថ្ងៃទី៣១ ខែធ្នូ។
- សរសេរបិទឆ្នាំអនុវត្ត នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ (មិនមែនសរសេរបិទ នៅពេលប្រើប្រាស់អស់សន្លឹកនោះទេ)។
- សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្រោយពីសរសេរបិទឆ្នាំអនុវត្តហើយ បើសិនជានៅមានសល់សន្លឹក ត្រូវប្រើប្រាស់បន្ត ដោយចាប់ផ្តើមពីលេខរៀង០១ឡើងវិញ។
- សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានប្រើប្រាស់ ត្រូវរក្សាទុកនៅឃុំសង្កាត់ បើប្រើប្រាស់នៅឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ បើប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ។

១.៤.ការសរសេរបំពេញសន្លឹកនៃសៀវភៅអត្រានុកូលដ្ឋាន មុននឹងបញ្ជូនទៅឃុំ សង្កាត់

សៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ មុននឹងបញ្ជូនទៅឃុំ សង្កាត់ ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ក្រុង ស្រុក ខណ្ឌ និងអភិបាល ក្រុង ស្រុក ខណ្ឌ ត្រូវបំពេញកិច្ចការមួយចំនួនដូចខាងក្រោម៖

របៀបបំពេញសន្លឹកដើមដំបូងនៃសៀវភៅអត្រានុកូលដ្ឋានដូចជា

១.ចំនួនសន្លឹកជាលេខខ្មែរ និងជាអក្សរខ្មែរ។

២.ថ្ងៃ ខែ ឆ្នាំ នៃការចុះហត្ថលេខារបស់អភិបាល ក្រុង ស្រុក ខណ្ឌ ជាក់ស្តែង។

៣.ឈ្មោះក្រុង ឬស្រុក ឬខណ្ឌសាមី។

បញ្ជាក់៖ ការចុះលេខរៀងសន្លឹក ការចុះហត្ថលេខាសង្ខេប ឬការចុះហត្ថលេខាពេញ និងការបោះត្រាសាលាក្រុង ស្រុក ខណ្ឌ ត្រូវធ្វើនៅផ្នែកកណ្តាលខាងលើបង្អស់នៃសន្លឹក។ ដើម្បីសម្រួលដល់ការសរសេរលេខសន្លឹក សាលាក្រុង ស្រុក ខណ្ឌអាចធ្វើត្រាជ្រុងមួយសម្រាប់បោះដែលមានខ្លឹមសារ។

១.៤.១.ការសរសេរបំពេញក្របមុខ

នៅពេលប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរបំពេញក្របមុខរបស់សៀវភៅអត្រានុកូលដ្ឋាន ពីចំណុចទី១ ដល់ទី៥ លើកលែងតែចំណុចទី៦ ដែលត្រូវបំពេញបិទបញ្ជីសៀវភៅអត្រានុកូលដ្ឋានរួចភ្លាម។

- **របៀបសរសេរក្របមុខនៃសៀវភៅអត្រានុកូលដ្ឋាន**
  - ខេត្ត ក្រុង ត្រូវសរសេរឈ្មោះ រាជធានី ឬខេត្តសាមី។
  - ស្រុក ខណ្ឌ ត្រូវសរសេរឈ្មោះក្រុង ឬ ស្រុក ឬខេត្តសាមី។
  - ឃុំ សង្កាត់ ត្រូវសរសេរឈ្មោះ ឃុំ ឬសង្កាត់សាមី។

១.៤.២.ការសរសេរចុះលេខរៀងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន

លេខរៀងបញ្ជីអត្រានុកូលដ្ឋាន ត្រូវចុះតាមប្រភេទនៃសៀវភៅអត្រានុកូលដ្ឋាននីមួយៗ ដោយចាប់ផ្តើមពីលេខ ០១ ជាបន្តបន្ទាប់រហូតដល់បញ្ជីចុងក្រោយ។ ប្រសិនបើមានករណីការចុះបញ្ជីអស់ក្នុងសៀវភៅអត្រានុកូលដ្ឋានភ្លោះទីមួយ ហើយមិនទាន់ដាច់ឆ្នាំ (ក្នុងឆ្នាំដដែល) ត្រូវចុះលេខរៀងបញ្ជីអត្រានុកូលដ្ឋាននៃសៀវភៅអត្រានុកូលដ្ឋានភ្លោះទី២ បន្តលេខរៀងចុះបញ្ជីអត្រានុកូលដ្ឋានចុងក្រោយនៃសៀវភៅអត្រានុកូលដ្ឋានភ្លោះទី១។ លេខរៀងបញ្ជីអត្រានុកូលដ្ឋានត្រូវចុះនៅពេលចាប់ផ្តើមសរសេរចូលបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានមិនត្រូវចុះលេខរៀងទុកជាមុន ឬរំលងនោះទេ ពេលឆ្នាំថ្មីមកដល់ លេខរៀងបញ្ជីអត្រានុកូលដ្ឋាន ត្រូវចាប់ផ្តើមពីលេខ ០១ ឡើងវិញ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរបិទសៀវភៅអត្រានុកូលដ្ឋាន នៅពេលសៀវភៅប្រើប្រាស់អស់បញ្ជី នៅដំណាច់ឆ្នាំនីមួយៗ។

១.៥.ការអនុវត្តន៍ការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន

ការសុំចុះអត្រានុកូលដ្ឋាន ក្នុងសៀវភៅអត្រានុកូលដ្ឋាន គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ព្រមទាំងជនបរទេស ឬជនអន្តោប្រវេសន៍ដែលបានរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា។ ដូច្នេះរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ព្រមទាំងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងនាយកដ្ឋានអត្រានុកូលដ្ឋានបានដាក់រៀបចំយន្តការ ដើម្បីធានាការផ្តល់សេវាអត្រានុកូលដ្ឋាននេះឲ្យមានប្រសិទ្ធភាព និងមានភាពជឿជាក់ទៅកាន់ប្រជា

ពលរដ្ឋ ដោយត្រូវធ្វើការបែងចែកសមត្ថកិច្ច តាមពាក្យបច្ចេកទេសហៅថា (ការធ្វើប្រតិភូកម្មអំណាច ឬប្រតិភូកម្មសមត្ថកិច្ច)។

ចំពោះការបែងចែកថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានដូចខាងក្រោម៖

១.៥.១.ថ្នាក់ជាតិ

ក.សមត្ថកិច្ចក្រៅប្រទេស

រាល់ការអនុវត្តន៍ការងារអត្រានុកូលដ្ឋាននៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន ដូចការងារអត្រានុកូលដ្ឋានដែលអនុវត្តន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវធ្វើសេចក្តីណែនាំបន្ថែមដោយប្រកាសរួមមួយ។

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី០១រូបនៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឲ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ខ.សមត្ថកិច្ចក្នុងប្រទេស

❖ **តួនាទីរបស់ក្រសួង ៖** នាយកដ្ឋានអត្រានុកូលដ្ឋាន និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលមានតួនាទីជាសេនាធិការឲ្យក្រសួងមហាផ្ទៃលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន ដែលត្រូវរៀបចំផែនការផ្សេងៗ ក្នុងកិច្ចការទាក់ទង និងផែនការសកម្មភាព ក្នុងការចុះបញ្ជី និងផ្តល់សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណៈភាព និងមានភារកិច្ចដូចតទៅ៖[11]

- ធានាការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីអត្រានុកូលដ្ឋាន។
- ដាក់ចេញគោលការណ៍ សេចក្តីណែនាំ បែបបទ និងនីតិវិធីនានាស្របតាមការកំណត់នៃច្បាប់។
- បញ្ជា និងណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានលើការអនុវត្តន៍ការងារអត្រានុកូលដ្ឋាន។
- រាយការណ៍ពីការរំលោភបទប្បញ្ញត្តិច្បាប់ដែលប្រព្រឹត្តដោយមន្ត្រីអត្រានុកូលដ្ឋានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីចាត់ចែងវិធានការដាក់វិន័យតាមច្បាប់។

[11] អនុក្រឹត្យលេខ១៣៤ អនក្រ.បក ស្តីពី មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ជំពូកទី២ មាត្រា៤-៥

- ពិនិត្យសម្រេច និងអនុញ្ញាតឲ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ឬអនុញ្ញាតឲ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញស្របតាមបទប្បញ្ញត្តិនៃច្បាប់។
- ពិនិត្យសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តន៍មិនស្របតាមនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។
- ពិនិត្យសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋានក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិមិនអាចសម្រេចបាន។
- ដាក់ឲ្យប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗជាផ្លូវការ។
- ចេញសេចក្តីចម្លងនិងសម្រង់អត្រានុកូលដ្ឋានក្នុងករណីមានការស្នើសុំ។
- សិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន។
- ណែនាំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តន៍ការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ។
- ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងប្រទេសដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ រួចហើយរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។
- រៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន។
- បញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធព័ត៌មានវិទ្យា។
- លើកផែនការស្នើសុំបោះពុម្ពសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ជូនដល់រាជធានី ខេត្តឲ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

ចំណាំ៖ ប្រសិនបើករណីពុំមានសៀវភៅអត្រានុកូលដ្ឋាន ក្រសួងត្រូវឆ្លើយតបជាលាយលក្ខអក្សរទៅរាជធានី ខេត្តវិញ នៅអំឡុងពេល១០ថ្ងៃ នៃថ្ងៃធ្វើការងារ បន្ទាប់ពីទទួលបានសំណើសុំរបស់ខេត្តរាជធានី ខេត្ត។

១.៥.២.ថ្នាក់ក្រោមជាតិ

❖ **តួនាទីរបស់រាជធានី ខេត្ត ៖** អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តន៍ការងាររបស់ការងារស្ថិតិ និងអត្រានុកូលដ្ឋានខេត្ត ក្រុងខ្លួនដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាននៃសាលាខេត្តក្រុងជាសេនាធិការ និងមានភារកិច្ចខាងក្រោម៖

- ត្រួតពិនិត្យ និងបូកសរុបចំនួនប្រជាពលរដ្ឋទូទាំងខេត្ត ក្រុង និងធ្វើរបាយការណ៍មកក្រសួងមហាផ្ទៃតាមការកំណត់។
- ត្រួតពិនិត្យការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ទៅតាមស្រុក ខណ្ឌ ឃុំសង្កាត់។

- ធ្វើការបូកសរុបចំនួនប្រជាពលរដ្ឋ ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែ និងផ្ញើរបាយការណ៍ទៅក្រសួងមហាផ្ទៃ នៅរាល់ថ្ងៃទី១៥ នៃខែបន្ទាប់នីមួយៗ។
- លើកគម្រោងទៅក្រសួងដើម្បីសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់ផ្តល់ឲ្យស្រុកខណ្ឌ និងចែកដល់ឃុំ សង្កាត់ រួចបូកសរុបរបាយការណ៍នៃការប្រើប្រាស់ឲ្យបានទាន់ពេលកំណត់។
- សហការ និងរៀបចំការបណ្តុះបណ្តាលការងារកសាងសមត្ថភាព និងការអប់រំដល់សាធារណៈជនអំពីការងារអត្រានុកូលដ្ឋាន។
- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ ពីការងារអត្រានុកូលដ្ឋានដល់ស្រុកខណ្ឌ ឃុំ សង្កាត់ចំណុះរបស់ខ្លួន។
- វាយតម្លៃលើការអនុវត្តន៍ស្ថិតិ និងអត្រានុកូលដ្ឋានក្នុងខេត្ត ក្រុង ក្រោមការគ្រប់គ្រងរបស់ខ្លួន
- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលពាក់ព័ន្ធ និងអត្រានុកូលដ្ឋាន។

បញ្ហាក់៖ នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានរាជធានី ខេត្តត្រូវធ្វើសំណើសុំទៅក្រសួងមហាផ្ទៃដោយភ្ជាប់នូវរបាយការណ៍ប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន។ ករណីពុំមានសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានរាជធានី ខេត្តត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅក្រុង ស្រុក ខណ្ឌ នៅក្នុងអំឡុងពេល១០ថ្ងៃ ការងារបន្ទាប់ពីទទួលបានសំណើសុំរបស់ក្រុង ស្រុក ខណ្ឌ។

- **តួនាទីក្រុង ស្រុក ខណ្ឌ ៖** អភិបាលក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការត្រួតពិនិត្យអនុវត្តន៍ការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌរបស់ខ្លួន ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃស្រុក ខណ្ឌ ជាសេនាធិការមានភារកិច្ចដូចខាងក្រោម៖
  - ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងក្រុង ស្រុក ខណ្ឌ និងផ្ញើរបាយការណ៍មករាជធានី ខេត្តតាមការកំណត់។
  - បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែនីមួយៗ តាមឃុំសង្កាត់ចំណុះ និងផ្ញើទៅការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាន នៃអត្រានុកូលដ្ឋាននៃទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្តរៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់នីមួយៗ។
  - លើកគម្រោងទៅសាលារាជធានី ខេត្ត ដើម្បីស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់បែងចែកជូនឃុំ សង្កាត់ និងបូកសរុបការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ផ្ញើមករាជធានី ខេត្តតាមការកំណត់។

- **មុននឹងបញ្ជូនសៀវភៅអត្រានុកូលដ្ឋានទៅឲ្យឃុំ សង្កាត់យកទៅប្រើប្រាស់ត្រូវ៖**
  - បំពេញសន្លឹកដើមដំបូងបំផុត។
  - ចុះលេខរៀងសន្លឹកនៃសៀវភៅអត្រានុកូលដ្ឋាន។
  - ដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីចុះហត្ថលេខា (ហត្ថលេខាពេញ និងសង្ខេប) និងបោះត្រា។
  - ត្រួតពិនិត្យជាប្រចាំ អនុវត្តន៍ការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមឃុំ សង្កាត់។
  - ត្រួតពិនិត្យរាល់បញ្ហីក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលឃុំ សង្កាត់ផ្ញើមកក្រុង ស្រុក ខណ្ឌពេលដាច់ឆ្នាំនីមួយៗ ឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងមហាផ្ទៃ។
  - រក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋានឲ្យបានគត់មត់នៅសាលាក្រុង ស្រុក ខណ្ឌមួយច្បាប់ តាមប្រភេទនីមួយៗ និងមួយច្បាប់ទៀតដូចគ្នាផ្ញើទៅរក្សាទុកនៅសាលារាជធានី ខេត្តសាមី។
  - ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជូនដល់ប្រជាពលរដ្ឋដែលមកសុំចម្លងនៅឆ្នាំដែលកន្លងផុត (ឆ្នាំដាច់ទៅ)។
  - ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីការងារអត្រានុកូលដ្ឋានដល់ឃុំ សង្កាត់ចំណុះ។
  - ធ្វើការវាយតម្លៃការអនុវត្តន៍ការងារស្តិតិ និងអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌរបស់ខ្លួន។
  - ត្រូវធ្វើសំណើសុំទៅអភិបាលរាជធានី ខេត្តដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន។
  - អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្តិតិ និងអត្រានុកូលដ្ឋាន។

បញ្ជាក់៖ នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ក្រុង ស្រុក ខណ្ឌត្រូវធ្វើសំណើសុំទៅរាជធានីខេត្តដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន។ ប្រសិនបើមានពុំមានសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅឃុំ សង្កាត់វិញនៅក្នុងអំឡុងពេល ១០ថ្ងៃការងារ បន្ទាប់ពីទទួលបានករណីសុំរបស់ឃុំ សង្កាត់។

- **តួនាទីរបស់ឃុំ សង្កាត់៖** ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង ចំពោះមេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន មានភារកិច្ចដូចខាងក្រោម៖
  - ទាក់ទង ការលើកគម្រោងស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានមកសាលាក្រុង ស្រុក ខណ្ឌសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

- ផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនមានការយល់ដឹងអំពីការចុះសៀវភៅអត្រានុកូលដ្ឋានឲ្យបានគ្រប់ៗគ្នា ការចុះ អាពាហ៍ពិពាហ៍ និងមរណភាពជាដើម។
- ការកែតម្រូវ ឬការបដិសេធសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ គឺត្រូវតាមអំណាចសាលក្រមជាស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់។
- ទទួលពិនិត្យ និងកត់ត្រារឿងហេតុសំខាន់ទាក់ទងទៅនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាពនៃជនទាំងឡាយ ចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន។
- ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ទៅតាមការស្នើសុំរបស់ប្រជាពលរដ្ឋ នៅឆ្នាំដែលមិនទាន់ដាច់។
- អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និងធ្វើបុណ្យសព និងកម្មវិធីផ្សេងៗ នៅក្នុងដែនដីសមត្ថកិច្ចដែលគ្រប់គ្រងនោះ។
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្តន៍។
- ចុះហត្ថលេខា និងបោះត្រាលើបញ្ជី និងសំបុត្រអត្រានុកូលដ្ឋាន។
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋានតាមប្រភេទឲ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង។
- បិទសៀវភៅអត្រានុកូលដ្ឋាន នៅពេលប្រើប្រាស់អស់បញ្ជី និងនៅដំណាច់ឆ្នាំនីមួយៗ ក្រោយពីបានពិនិត្យត្រឹមត្រូវរួចរាល់អស់ហើយ។
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានដែលបិទបញ្ជីរួចទៅសាលាក្រុង ស្រុក ខណ្ឌ នៅដើមខែមករានៃឆ្នាំបន្ទាប់ ដើម្បីយកទៅតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និងនៅសាលារាជធានី ខេត្តសាមីមួយច្បាប់។
- ត្រូវធ្វើរបាយការណ៍អំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ និងចំនួនស្ថិតិប្រជាពលរដ្ឋដែលរស់នៅក្នុងដែនដីឃុំ សង្កាត់របស់ខ្លួនគ្រប់គ្រង ជារៀងរាល់ខែ នាថ្ងៃទី០៥ នៃខែបន្ទាប់ និងរាល់ដំណាច់ឆ្នាំនីមួយៗ រួចបញ្ជូនសៀវភៅទាំងនេះ ផ្ញើមកសាលាក្រុង ស្រុក ខណ្ឌសាមី ដើម្បីយកទៅតម្កល់ទុកនៅសាលាក្រុង ស្រុក។

ចំណាំ៖ នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ឃុំ សង្កាត់ត្រូវធ្វើសំណើរទៅអភិបាលក្រុង ស្រុក ខណ្ឌ ប៉ុន្តែលិខិតស្នើសុំនេះ ត្រូវចម្លងជូនរាជធានី ខេត្ត ដើម្បីជូនជ្រាប។ លិខិតអត្រានុកូលដ្ឋានទាំងអស់រៀបចំឡើងដោយមន្ត្រីអត្រានុកូលដ្ឋាន ពោលគឺមេឃុំ ចៅសង្កាត់ ដែលអាចធ្វើប្រតិភូតកម្មនៃអំណាចរបស់

ខ្លួនទៅឲ្យជំទប់ ឬចៅសង្កាត់រង និងទៅឲ្យមន្ត្រីឃុំសង្កាត់ដទៃទៀតបាន។ លិខិតនេះ គឺបង្កើតឡើងដោយបានសហការរវាងអាជ្ញាធរសាធារណៈ និងបុគ្គលឯកជន។

- **តួនាទីរបស់ភូមិ៖** មេភូមិជាសេវានៅក្នុងមូលដ្ឋានមួយមានតួនាទីយ៉ាងសំខាន់ណាស់ ដោយសារនៅជៀកប្រជាពលរដ្ឋ ធ្វើការចុះនូវសៀវភៅអត្រានុកូលដ្ឋានទាន់ពេលវេលា ហើយត្រូវការកត់ត្រាជាប្រចាំខែនីមួយៗឲ្យបានច្បាស់លាស់ដូចជា៖
  - ទារកដែលទើបកើត
  - ទារកដែលទើបនិងកើត ហើយស្លាប់
  - អ្នកបានរៀបអាពាហ៍ពិពាហ៍
  - អ្នកដែលទទួលមរណភាព។

កិច្ចការខាងលើទាំងនេះ មេភូមិត្រូវស្រង់ស្ថិតិ និងធ្វើរបាយការណ៍ រួចផ្ញើទៅសាលាឃុំ សង្កាត់ នៅថ្ងៃទី០៣ នៃខែបន្ទាប់ ដើម្បីយកមកបូកសរុប។

បញ្ជាក់៖ មន្ត្រីអត្រានុកូលដ្ឋាន មានសិទ្ធិមិនចុះអត្រានុកូលដ្ឋានឲ្យទៅជនណាមួយដែលខ្លួនយល់ឃើញថា ជននោះមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមិនមែនជាប្រជាពលរដ្ឋខ្មែរ។

- **បំរាម និងការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីការងារអត្រានុកូលដ្ឋាន**
  - រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ មន្ត្រីអត្រានុកូលដ្ឋានអាជ្ញាធរស្រុក ខណ្ឌ ខេត្ត ក្រុង មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងឡើយ។
  - ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ទៀត។ សំបុត្រអត្រានុកូលដ្ឋានរបស់ជនណាមួយជាកម្មសិទ្ធិសម្រាប់តែជននោះប៉ុណ្ណោះ មិនអនុញ្ញាតឲ្យជនដទៃយកទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនឡើយ។
  - ហាមចុះសៀវភៅអត្រានុកូលដ្ឋានប្រភេទនីមួយៗ លើសពីមួយដងសម្រាប់មនុស្សតែម្នាក់ នៅច្រើនកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។
  - សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ដែលមានកោស ឆូត លុប សរសេរជ្រៀតថែម មិនមានតម្លៃប្រើប្រាស់ជាផ្លូវការទេ។

- ការចុះសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ សាមីខ្លួន អ្នករាយការណ៍ សាក្សីត្រូវសម្តែងនូវការស្មោះត្រង់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ចំពោះការបញ្ជាក់អះអាងរបស់ខ្លួន អំពីហេតុការណ៍ដែលកើតមានឡើងហើយដែលខ្លួនបានដឹងឮ ឬឃើញផ្ទាល់។
- ជនណារាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬយកសំបុត្រអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួនឬ ឬរាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពីមួយដងនៅកន្លែងដដែល ឬកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយប្រើប្រាស់អត្រានុកូលដ្ឋានក្លែងបន្លំ ត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។
- មន្ត្រីអត្រានុកូលដ្ឋានត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបើមន្ត្រីអត្រានុកូលដ្ឋាន ណាសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឲ្យប្រជាពលរដ្ឋដែលមកសុំ ឬបានទារប្រាក់លើសពីការកំណត់ពីប្រជាពលរដ្ឋ សម្រាប់ការងារអត្រានុកូលដ្ឋានត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។[12]

❖ **សេចក្តីចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន និងសំបុត្របញ្ជាក់អត្រានុកូលដ្ឋាន**

រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានទាំងបីប្រភេទ នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលា ឃុំ ឬសង្កាត់របស់ខ្លួន ដោយចុះហត្ថលេខា ហើយត្រូវបោះត្រាពីមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់របស់ខ្លួន។ ប្រសិនបើទៅសុំចម្លងនៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវបានចុះហត្ថលេខា និងបោះត្រាដោយមន្ត្រីសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌ ដែលធ្វើប្រតិភូកម្ម។

ក្នុងករណីប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅទីនោះ គឺត្រូវទៅសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅឯបរទេសនោះ។ រាល់ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានទាំងបីប្រភេទ គឺត្រូវយកសំបុត្រច្បាប់ដើមមកជាមួយផង ប្រសិនបើមានហេតុការណ៍បាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមណាមួយ អ្នកមកសុំអាចចម្លងបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- រាយការណ៍ជាលាយលក្ខអក្សរឲ្យបានច្បាស់លាស់ អំពីមូលហេតុនៃការបាត់បង់

[12] សេចក្តីណែនាំលេខ ០០៨ សណន ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឲ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត

- បញ្ជាក់ពីឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន ដើម្បីមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅងាយស្រួលក្នុងការស្វែងរក។

❖ **ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃសេវារដ្ឋបាល**

ការបោះពុម្ពសៀវភៅអត្រានុកូលដ្ឋាន សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលអំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេស ត្រូវស្ថិតនៅក្នុងបន្ទុកថវិការដ្ឋ។ រាល់ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋាន អ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃសេវារដ្ឋបាលជាថវិកាដែលបានមកពីការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅសាលាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ។ ថ្លៃក្រដាស និងសេវារដ្ឋបាលទាំងអស់នេះ ត្រូវអនុវត្តន៍តាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រ៊ីសារពើពន្ធ និងយោងតាមសេចក្តីណែនាំលេខ ០០៨ សណន របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០០៧។

➢ ចំពោះខេត្តចំនួន ០៥ រួមមាន៖ **ខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ**

❖ **សេវាអត្រានុកូលដ្ឋានកំណើត**

- សំបុត្របញ្ជាក់កំណើតថ្លៃ ៣០០០រៀល
- សេចក្តីចម្លង ឬសំបុត្រកំណើត និងបញ្ជាក់កំណើតថ្លៃ ១០០០រៀល

❖ **សេវាអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍**

- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ២០០០រៀល
- សំបុត្រអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរថ្លៃ ៥០០០រៀល
- ឯជនបរទេស និងពលរដ្ឋខ្មែរថ្លៃ ១៥០០០រៀល
- និងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (មិនឆ្លងឆ្នាំ) ថ្លៃ ៣០០០រៀល

❖ **ថ្លៃសេវាអត្រានុកូលដ្ឋានមរណភាព**

- សំបុត្រមរណភាពទុកឲ្យហួសពេលកំណត់ ១៥ ថ្ងៃ បន្ទាប់ពីមរណភាពត្រូវបង់ថ្លៃ ១០០០រៀល
- និងសេចក្តីចម្លងសំបុត្រមរណភាពថ្លៃ ១០០០រៀល។

➢ **សម្រាប់ក្នុងរាជធានី ខេត្ត និងឃុំ សង្កាត់ក្រៅពីខេត្តទាំង៥ខាងលើនេះ**

❖ **សេវាអត្រានុកូលដ្ឋានកំណើត**

- សំបុត្របញ្ជាក់កំណើតថ្លៃ ១០,០០០រៀល

- ·សេចក្តីចម្លង ឬសំបុត្រកំណើត និងបញ្ជាក់កំណើតថ្លៃ ៣០០០រៀល

❖ **សេវាអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍**

- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ថ្លៃ ៣០០០រៀល
- សំបុត្រអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរថ្លៃ ១៥,០០០រៀល
- ឯជនបរទេស និងពលរដ្ឋខ្មែរថ្លៃ ៣០,០០០រៀល
- និងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (មិនឆ្លងឆ្នាំ) ថ្លៃ ៣០០០រៀល

❖ **ថ្លៃសេវាអត្រានុកូលដ្ឋានមរណភាព**

- សំបុត្រមរណភាពទុកឲ្យហួសពេលកំណត់ ១៥ថ្ងៃ បន្ទាប់ពីមរណភាព ត្រូវបង់ថ្លៃ ៣០០០រៀល
- និងសេចក្តីចម្លងសំបុត្រមរណភាពថ្លៃ ២០០០រៀល

ប្រសិនបើការសុំចុះអត្រានុកូលដ្ឋានទាំង៣ប្រភេទឲ្យទាន់ពេលវេលា (មិនហួសពេលកំណត់) ក្នុងអំឡុងពេល ដូចជា៖ ការចុះសំបុត្រកំណើត ការដាក់ពាក្យសុំអាពាហ៍ពិពាហ៍ និងមរណភាព ពុំត្រូវបានបង់កម្រៃសេវានៅទូទាំងប្រទេសកម្ពុជានោះទេ។

ជំពូកទី ២

នីតិវិធីនៃការលេចឡើងនូវអត្រានុកូលដ្ឋានថ្មី ៣ប្រភេទ

២.១.ដំណាក់កាលនៃការកកើតនូវអត្រានុកូលដ្ឋានថ្មី ៣ប្រភេទ

មនុស្សគ្រប់រូប គឺជា**រូបវន្តបុគ្គល** (គឺសំដៅទៅលើបុគ្គលដែលមានសាច់ មានឈាម មានជីវិតពិតៗ) ហើយមានបុគ្គលិកលក្ខណៈគតិយុត្ត ត្រូវបានទទួលនូវសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់ ចំពោះអត្ថិភាពរបស់វា ត្រូវបានផ្តល់ដោយច្បាប់តាំងតែពីពេលចាប់កំណើតរហូតដល់បញ្ចប់ទៅវិញនៅពេលមរណភាព។ កិច្ចការទាំងអស់នេះទាមទារឲ្យគ្រប់បុគ្គលមានភាពយ៉ាងសកម្មចំពោះដំណើរការប្រព្រឹត្តទៅ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ដែលជាលិខិតគតិយុត្តមួយ សម្រាប់ប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ។ ជាក់ស្តែង ដើម្បីចុះបញ្ជីទាំងនេះ គឺបុគ្គលដែលពាក់ព័ន្ធ ត្រូវសហការរវាងអាជ្ញាធរសាធារណៈ និងបុគ្គលឯកជន រួមមាន៖ មន្ត្រីអត្រានុកូលដ្ឋាន និងឪពុកឬម្តាយ សាច់ញាតិ ត្រូវយល់អំពីដំណើរការនៃនីតិវិធីក្នុងការចុះបញ្ជីនូវដំណាក់កាលនីមួយៗឲ្យបានច្បាស់លាស់។ ជាធម្មតា មនុស្សជាតិយើងត្រូវតែមាននូវព្រឹត្តិការណ៍សំខាន់ៗ ៣ គឺ **កំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលហៅថា ព្រឹត្តិការណ៍គតិយុត្ត។**

២.១.១.អត្រានុកូលដ្ឋានកំណើត

និយមន័យកំណើត

កំណើត គឺជាព្រឹត្តិការណ៍គតិយុត្តដែលនាំឲ្យកើតមាននូវរូបវន្តបុគ្គល ពោលគឺការចាប់ផ្តើម ការកកើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។ ដើម្បីឲ្យបានក្លាយជារូបវន្តបុគ្គល កំណើត គឺជាលក្ខខណ្ឌបង្កើតឲ្យមានបុគ្គលភាព។ នៅពេលកើត គ្រប់ក្មេងទាំងអស់ជារូបវន្តបុគ្គល។ ឪពុក ឬ ម្តាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូននៅសាលាឃុំ សង្កាត់នៃលំហានរបស់ឪពុក ឬម្តាយក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលទារកនោះចាប់កំណើត។[13] ត្រូវមានលក្ខខណ្ឌពីរយ៉ាងគឺ៖

- កើតមកជាមនុស្ស
- កើតមករស់ ហើយអាចនឹងរស់នៅបាន។

❖ ការកំណត់នាមត្រកូលរបស់កូនអាចធ្វើឡើងបាន ៣យ៉ាង៖

- អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយក៏បាន
- អាចយកឈ្មោះជីតាខាងឪពុកមកដាក់ជានាមត្រកូលក៏បាន
- ឬក៏អាចយកឈ្មោះរបស់ឪពុក មកដាក់នាមត្រកូលក៏បាន

[13] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៤ មាត្រា១៧

ក.ការចុះសំបុត្រកំណើតទារក

បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ។ ក្នុងករណីឪពុក ម្តាយមានធុរៈចាំបាច់ពុំអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតបានអាចពឹងសាច់ញាតិសន្តាន ឬអ្នកជិតខាង ដែលបានដឹងឮថ្លាល់ពីទារកនោះកើតត្រូវសុំចុះកំណើតរបស់កូនឲ្យបានតាមកាលកំណត់ និងឆាប់រហ័ស មិនឲ្យហួស ៣០ថ្ងៃ។ ប្រសិនបើកើតហើយទុកឲ្យហួសរយៈពេល ៣០ ថ្ងៃមិនទាន់បានចុះសំបុត្រកំណើត គឺត្រូវប្តឹងទៅសាលាឃុំ សង្កាត់របស់ខ្លួនដែលរស់នៅពិតប្រាកដក្នុងពេលបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន ០២រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត។ ចំពោះបុគ្គលដែលបានកើតមុនសម័យក្រហមខ្មែរក៏ដោយ ក្នុងសម័យខ្មែរក្រហមក៏ដោយ ក្រោយសម័យខ្មែរក្រហមក៏ដោយ ឲ្យតែកើតមុនពេលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន មានន័យថា កើតមុនថ្ងៃទី២៩ ធ្នូ ឆ្នាំ ២០០០ អនុក្រឹត្យនេះ ទុកលទ្ធភាពឲ្យមានការចុះសំបុត្របញ្ជាក់កំណើតដោយឥតគិតថ្លៃ ក៏ប៉ុន្តែត្រូវធ្វើឲ្យ បានមុនថ្ងៃ ទី៣១ សីហា ឆ្នាំ ២០០៥ មានន័យថាមកទល់ នឹងពេលឥឡូវនេះការចុះសំបុត្របញ្ជាក់កំណើតដោយឥតគិតថ្លៃនេះ ត្រូវហួសពេលធ្វើហើយ។

ការដាក់ឈ្មោះ គឺត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីឪពុកម្តាយទារកនោះ និងត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្តាយទារក ឬឯកសារភស្តុតាងផ្សេងៗដែលមានបញ្ជាក់ភាពជាប្តីប្រពន្ធទៅជាមួយផង (ប្រសិនបើមាន)។

❖ **ចំពោះកូនមានខាន់ស្លា**

កូនដែលចាត់ទុកថាមានខាន់ស្លា លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងលុះត្រាណាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេលដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍និងគ្នា បានន័យថា កូនដែលកើត១៨០ថ្ងៃយ៉ាងតិច ក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬក្នុងរយៈពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍។

ចំណែកកូនដែលកើតក្នុងរយៈពេលតិចជាង ១៨០ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងចាត់ទុកថា ជាកូនរបស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ថា ប្តីនេះបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនថ្ងៃរៀបអាពាហ៍ពិពាហ៍មកម្ល៉េះ ឬក៏ព្រមទទួលស្គាល់ថា ខ្លួនជាឪពុករបស់កូននោះ។ ករណីប្រសិនបើប្តីរបស់

ម្តាយនៃកូននោះបដិសេធមិនទទួលស្គាល់ជាឪពុករបស់កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថា ខ្លួនមិនមែនជាឪពុក។[14]

❖ **ចំពោះកូនឥតខាន់ស្លា**

កូនឥតខាន់ស្លា គឺកូនដែលកើតពីឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តាមផ្លូវច្បាប់ ក៏ហ្នឹងត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតបានដែរ។ នៅពេលធ្វើសំបុត្រកំណើត ប្រសិនបើឪពុក និងម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក និងម្តាយនោះជាឪពុក ម្តាយរបស់កូននោះ។

ក្នុងករណីមានតែឪពុក ឬមានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនដែលបានទទួលស្គាល់តែម្ខាងតែប៉ុណ្ណោះ។ ក្រោយពេលឪពុក ឬម្តាយបានប្តឹងចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឪពុក ឬម្តាយណាមិនទាន់ទទួលទារកនោះ ឪពុក ឬម្តាយនោះអាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន។ ការទទួលស្គាល់កូនអាចធ្វើមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍។[15]

❖ **នៅពេលមានពីរទ្វេជន ឬទណ្ឌិតណាម្នាក់បានសម្រាលកូនក្នុងមណ្ឌលអប់រំកែប្រែ**

អ្នកដែលទទួលខុសត្រូវនៃមណ្ឌលអប់រំកែប្រែត្រូវធ្វើកំណត់ហេតុទារកនោះឲ្យបានត្រឹមត្រូវ ចំពោះទីកន្លែងកំណើតទារក ត្រូវសរសេរទីកន្លែងនៃលំនៅរបស់ឪពុក ឬម្តាយទារកមុនពេលក្លាយជាទណ្ឌិត។ បើទារកនោះមានឪពុកត្រឹមត្រូវ នៅរស់ទទួលខុសត្រូវនៃពន្ធនាគារត្រូវប្រគល់កំណត់ហេតុនោះអោយឪពុកទារកនោះយកទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឃុំ ឬសង្កាត់ ដែលខ្លួនកំពុងរស់នៅជាប់លាប់ក្នុងពេលបច្ចុប្បន្ន។ ក្នុងករណីទារកពុំទាន់មានឪពុកច្បាស់លាស់ទេ អ្នកទទួលខុសត្រូវពន្ធនាគារ ត្រូវបញ្ជូនកំណត់ហេតុទារកទើបកើតទៅប្រគល់ឲ្យមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅ ដែលម្តាយទារកនោះរស់នៅជាប់លាប់មុនពេលក្លាយជាទណ្ឌិត ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឲ្យទាន់ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីទារកនោះកើត។[16]

❖ **ទារកដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក**

ទារកដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលកុមារ ហើយពុំទាន់មានសំបុត្រកំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះ ត្រូវធ្វើសេចក្តីរាយការណ៍ នឹងនាំទារក ឬកុមារនោះទៅបង្ហាញផ្ទាល់ចំពោះមុខមន្ត្រី

[14] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ជំពូកទី៥ មាត្រា ៨២-៨៣

[15] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ជំពូកទី៥ ផ្នែកទី២ មាត្រា ៩០-មាត្រា ៩៤

[16] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៤ មាត្រា ២០

អត្រានុកូលដ្ឋាន ដើម្បីផ្តល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឲ្យ។ ចំពោះដាក់ឈ្មោះឲ្យទារក ឬកុមារកំព្រាទាំងនោះ អាស្រ័យទៅលើអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌល និងមន្ត្រីអត្រានុកូលដ្ឋានឯកភាពដាក់ឲ្យ។[17]

- **ទារកកើតនៅបរទេស**

ក្នុងករណីទារកកើតនៅបរទេស ពីឪពុក ឬម្តាយជាពលរដ្ឋខ្មែរ ហើយរស់នៅដោយស្របច្បាប់នៅបរទេស ឪពុក ម្តាយរបស់ទារកនេះ អាចទៅសុំចុះសំបុត្រកំណើតកូននៅអាជ្ញាធរអត្រានុកូលដ្ឋានរបស់ប្រទេសដែលខ្លួនរស់នៅនោះបានទៅតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ។[18]

បន្ទាប់មកទៀត គាត់អាចមានលទ្ធភាពពីរ៖

១.គាត់ទៅសុំចុះសំបុត្រកំណើត នៅឯស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជា ដែលប្រចាំនៅក្នុងប្រទេស ដែលគាត់រស់នៅនោះ។ ក្នុងករណីនេះ ស្ថានទូត ឬស្ថានកុងស៊ុល នឹងចេញសំបុត្រកំណើតច្បាប់ដើមដែលអាចយកមកប្រើប្រាស់ជាផ្លូវការបាន ដូចសំបុត្រកំណើត ដែលចេញដោយមេឃុំ ចៅសង្កាត់ នៅក្នុងប្រទេសកម្ពុជាដែរ។

២.ឪពុកម្តាយមិនចាំបាច់ទៅសុំចុះសំបុត្រកំណើតនៅស្ថានទូត ឬស្ថានកុងស៊ុលកម្ពុជាក៏បានដែរ។ ក៏ប៉ុន្តែនៅពេលគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញគាត់ត្រូវយកសំបុត្រកំណើតដែលចេញដោយអាជ្ញាធរបរទេសទៅបង្ហាញមេឃុំ ឬចៅសង្កាត់ នៃទីលំនៅថ្មីរបស់គាត់ ដើម្បីសុំសំបុត្រកំណើតថ្មី។

- **ចំពោះទារកដែលកើតពីឪពុកម្តាយជាជនបរទេស និងជនអន្តោប្រវេសន៍រស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា**

ឪពុកម្តាយទារកនោះ អាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជាប្រសិនបើមាន។ ចំពោះអ្នកមកការយការណ៍សុំចុះសំបុត្រកំណើតត្រូវតែឪពុកម្តាយផ្ទាល់ទើបបាន គឺមិនអាចអនុញ្ញាតឲ្យអ្នកដទៃមកការយការណ៍ជំនួសបានឡើយ ។[19]

- **សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតរួមមាន៖**
  - សៀវភៅអត្រានុកូលដ្ឋានកំណើត (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
  - សៀវភៅអត្រានុកូលដ្ឋានកំណើតសម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់

[17] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៤ មាត្រា ២០-២១

[18] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៤ មាត្រា ២៦

[19] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៤ មាត្រា ២៧

សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត ចំពោះសៀវភៅអត្រានុកូលដ្ឋានកំណើត និងចម្លងសំបុត្របញ្ជាក់កំណើតមិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

- **ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតរួមមាន៖**
  - សំបុត្រកំណើត
  - សំបុត្របញ្ជាក់កំណើត
  - សេចក្តីចម្លងសំបុត្រកំណើត (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅ ក្រុង ស្រុក ខណ្ឌ)
  - សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។ (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅ ក្រុង ស្រុក ខណ្ឌ)

យោងតាម សេចក្តីណែនាំ របស់ ក្រសួង មហាផ្ទៃ (ស.ណ.ន ១៨ ឧសភា ២០០៧) អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម៖

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុ អំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅពន្ធនាគារ ឬ
- លិខិតបញ្ជាក់របស់ឪពុក ម្តាយ អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក បើឪពុក ម្តាយទារកពឹងពាក់សាច់ញាតិ ឬអ្នកជិតខាងអោយទៅរាយការណ៍ជំនួស
- សៀវភៅគ្រួសារដែលមានឈ្មោះឪពុក ម្តាយទារក (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុក ម្តាយទារក (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឪពុក ឬម្តាយ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុក ម្តាយទារក (ប្រសិនបើមាន)

ទារកដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតក្នុងរយៈពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្តល់សំបុត្រកំណើតច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ។

❖ **មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកនូវលិខិតស្នាមចាំបាច់ និងកំណើតទារក ក្នុងសំណុំឯកសារកំណើត នៅ ឃុំ ឬសង្កាត់៖**

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅពន្ធនាគារ និងលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- លិខិតបញ្ជាក់របស់ឪពុក ម្តាយ អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក បើឪពុក ម្តាយទារកពឹងពាក់សាច់ញាតិ ឬ អ្នកជិតខាងអោយទៅរាយការណ៍ជំនួស
- មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមឲ្យទៅអ្នករាយការណ៍ ក្រៅពីលិខិតស្នាមចាំបាច់ពាក់ព័ន្ធនិងកំណើតដែលត្រូវរក្សាទុក។

ខ.ការចុះអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើត

នៅក្នុងពេលមានអ្នកមករាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសុំសំបុត្របញ្ជាក់កំណើត និងបន្ទាប់ពីបានពិនិត្យលិខិតឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីបញ្ជាក់កំណើតចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណត់ភ្លោះ។

ក្រោយពេលសរសេរបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឲ្យខុសពីខ្លឹមសារក្នុងបញ្ជីបញ្ជាក់កំណើត ដោយដកស្រង់យកចំណុចសំខាន់ៗ ពីបញ្ជីបញ្ជាក់កំណើត។

បញ្ជាក់៖ ការប្រគល់សំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក ក្រោយពីសរសេរ ចុះហត្ថលេខា និងបោះត្រាលើសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក រួចហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ទៅឲ្យសាមីខ្លួនដែលមកសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងណែនាំឲ្យអ្នកថែរក្សាទុកដាក់ឲ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្របញ្ជាក់កំណើតច្បាប់ដើមជូនជាលើកទីពីរបាននោះទេ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នករាយការណ៍ថា សំបុត្របញ្ជាក់កំណើតច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនមានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារមួយនោះទេ។ ដូច្នេះ គួរធ្វើសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតឲ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

- **លិខិតស្នាមនានាដែលទាក់ទង និងការបញ្ជាក់កំណើត**

សាមីខ្លួន និងសាក្សីត្រូវយកជាប់ជាមួយនូវលិខិតស្នាមចាំបាច់មួយចំនួន ដូចខាងក្រោម៖

- សៀវភៅគ្រួសាររបស់សាមីខ្លួន និងរបស់សាក្សី ឬ
- អត្តសញ្ញាណរបស់សាមីខ្លួន និងរបស់សាក្សី (ប្រសិនបើមាន) ឬ
- ឯកសារបៀវត្ស៍ ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី បើជាមន្ត្រីរាជការ

- **បើអាចធ្វើបានមន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងបញ្ជាក់កំណើត៖**

- ច្បាប់ថតចម្លងសៀវភៅគ្រួសាររបស់សាមីខ្លួន និងរបស់សាក្សី ឬ
- ច្បាប់ថតចម្លងអត្តសញ្ញាណរបស់សាមីខ្លួន និងរបស់សាក្សី ឬ
- ច្បាប់ថតចម្លងឯកសារបៀវត្ស សោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមីបើជាមន្ត្រីរាជការ

មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមទៅសាមីខ្លួន និងសាមីវិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

២.១.២.អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

និយមន័យអាពាហ៍ពិពាហ៍

តាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

(សំ. បា. អាវាហ + វិវាហ ខ្មែរប្រើផ្លាស់ វ ជា ព) តាមរូបសព្ទ អាវាហ (**អាពាហ៍**) ប្រែថា **"នាំមក"** វិវាហ (**ពិពាហ៍**) ប្រែថា **"នាំត្រឡប់ទៅវិញ"** មានន័យថា នាំកូនស្រីមកខាងលំនៅកូនប្រុស។ នាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ។[20]

ហេតុនេះអាពាហ៍ពិពាហ៍ គឺជាការផ្សំផ្គុំយ៉ាងឱឡារិកជាផ្លូវការរវាងបុរសម្នាក់ និងស្រីម្នាក់ ដើម្បីបង្កើតគ្រួសារថ្មីមួយ ដូច្នេះហើយបានជាតម្រូវឱ្យបុរស និងស្ត្រីចាំបាច់ត្រូវរៀបអាពាហ៍ពិពាហ៍ព្រោះដើម្បីឱ្យត្រឹមត្រូវតាមផ្លូវច្បាប់ និងតាមប្រពៃណីទំនៀមទម្លាប់។

អាពាហ៍ពិពាហ៍ តាមន័យគតិយុត្ត គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមសង្វាសជាមួយគ្នាតាមបទបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈទៅបាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមមាត្រាដែលបានចែងក្នុងច្បាប់ស្តីពីស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ដោយមានការដាក់សុំរៀប

[20] វចនានុក្រមខ្មែរ សង្ឃរាជ ជួន ណាត បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

អាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងពីរ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ហើយគ្មានជនណាមួយអាចបង្ខំបុគ្គលម្នាក់ឲ្យរៀបអាពាហ៍ពិពាហ៍ ឬរារាំងមិនឲ្យរៀបអាពាហ៍ពិពាហ៍បានឡើយ។[21]

បញ្ជាក់ : ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី មិនមែនជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះទេ។ ការប្រើពាក្យថា **"អាពាហ៍ពិពាហ៍"** ក្នុងន័យថា អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ឬការចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ក.ការរៀបអាពាហ៍ពិពាហ៍មាន៤ប្រភេទ ដូចខាងក្រោម៖

១.ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅក្នុងប្រទេសកម្ពុជា

ប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបចំអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ នៃលំនៅដ្ឋានខាងសាមីខ្លួនទាំងពីរដែលរស់នៅពិតប្រាកដបច្ចុប្បន្ន។ នៅពេលមានសាមីខ្លួនប្តី ឬប្រពន្ធមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសុំសំបុត្រអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យលិខិតស្នាមឃើញថា ត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ បន្ទាប់មកត្រូវសរសេរចុះបញ្ជី អាពាហ៍ពិពាហ៍ចំនួន ០២ ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ភ្លោះ។ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីការអាពាហ៍ពិពាហ៍ នឹងគ្រួសារ និងត្រូវតែអនុវត្តទៅតាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញាតិនៃអត្រានុកូលដ្ឋាន ជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា កិច្ចសន្យានេះត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធ និងសាក្សីគ្រប់អាយុការពីរនាក់។[22]

២.ការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និង ជនបរទេសនៅក្នុងប្រទេសកម្ពុជា

ជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ទោះបីជនបរទេសនោះស្ថិតក្រៅប្រទេសកម្ពុជាក្តី កំពុងស្ថិតក្នុងប្រទេសកម្ពុជាក្តី ចាំបាច់ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។ ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជាជនបរទេសត្រូវបំពេញបែបបទនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេស ហើយក្រសួងការបរទេស និងសហប្រតិបត្តិ

[21] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ជំពូកទី២ មាត្រា៣

[22] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៥ មាត្រា ២៨-៣០

ការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យចុះបញ្ជីរួចជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនពលរដ្ឋខ្មែរ។

ដើម្បីបំពេញសាមីខ្លួនទាំងពីរ គឺទាំងភាគីជាពលរដ្ឋខ្មែរ ទាំងភាគីជាពលរដ្ឋបរទេស ចាំបាច់ត្រូវតែបំពេញលក្ខខណ្ឌរួមមួយចំនួនដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរ ដូចជាករណីអាពាហ៍ពិពាហ៍ទូទៅ រវាងខ្មែរ និងខ្មែរដែរគឺ៖

ក្នុងករណីអាពាហ៍ពិពាហ៍ រវាងនារីខ្មែរ និងបុរសបរទេសនេះ ត្រូវបំពេញទៅតាម លក្ខខណ្ឌបន្ថែមដែលកំណត់ដោយក្រសួងការបរទេសខ្មែរតាមរយៈ កំណត់ទូត ចេញកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ គឺ៖

- អាយុមិនត្រូវឲ្យលើសពី ៥០ឆ្នាំ
- ត្រូវមានប្រាក់ចំណូលយ៉ាងតិច ២៥០០ដុល្លារ ក្នុងមួយខែ

ម្យ៉ាងទៀតយោងតាមអនុក្រឹត្យ លេខ ១៨៣ ចុះថ្ងៃទី៣ វិច្ឆិកា ២០០៨ ការរៀបអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម គឺត្រូវហាមឃាត់ដាច់ខាត។

❖ **សំណុំបែបបទនៃការសុំរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ទៅក្រសួងការបរទេស ដោយត្រូវមានភ្ជាប់នូវ៖**

យោងតាមអនុក្រឹត្យ ១៨៣ ខាងលើនេះ ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវតែមានវត្តមាននៅក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នេះដោយខ្លួនឯង។

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយត្រូវបំពេញទៅតាមទម្រង់ដែលមានស្រាប់ ចេញដោយអាជ្ញាធរខ្មែរ
- ឯកសារថតចម្លង នៃលិខិតឆ្លងដែនរបស់សាមីខ្លួនជាជនបរទេស ដោយមានទិដ្ឋាការ (Visa) ចូលក្នុងប្រទេសកម្ពុជា ដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬម៉ែម៉ាយ ចេញដោយសមត្ថកិច្ចប្រទេសរបស់សាមីខ្លួនជាជនបរទេស
- លិខិតបញ្ជាក់សុខភាព ចេញដោយសមត្ថកិច្ចកម្ពុជា
- លិខិតថ្កោលទោស ចេញដោយសមត្ថកិច្ចប្រទេសរបស់សាមីខ្លួនជាជនបរទេស
- លិខិតបញ្ជាក់ពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជាជនបរទេស ដោយមានបញ្ជាក់ពីចំនួនប្រាក់ចំណូលប្រចាំខែ ចេញដោយសមត្ថកិច្ចប្រទេសរបស់សាមីខ្លួនជាជនបរទេស ។

សំណុំឯកសារទាំងអស់នេះ (ក្រៅពីពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងលិខិតបញ្ជាក់សុខភាព) គឺត្រូវមានបោះត្រាបញ្ជាក់នីត្យានុកូលភាព ពីស្ថានទូត នៃប្រទេសរបស់សាមីខ្លួនជាជនបរទេស ដែលប្រចាំនៅក្នុងប្រទេសកម្ពុជា ម្យ៉ាងទៀតបើតាមកំណត់ទូតរបស់ក្រសួងការបរទេសខ្មែរ ចុះថ្ងៃទី២៣ មីនា ឆ្នាំ២០០៩ សាមីខ្លួនជាជនបរទេសមិនត្រូវទាក់ទង ដាក់សំណុំបែបបទសុំរៀបអាពាហ៍ពិពាហ៍នេះទៅក្រសួងការបរទេសដោយផ្ទាល់ទេ គឺត្រូវដាក់តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល នៃប្រទេសរបស់សាមីខ្លួនជាជនបរទេសដែលប្រចាំនៅកម្ពុជា។ ក្រោយពីទទួលបានសំណុំបែបបទនេះហើយ ក្រសួងការបរទេសមានរយៈពេលយ៉ាងយូរ ៥ថ្ងៃ (ថ្ងៃធ្វើការ) ដើម្បីពិនិត្យ និងសម្រេច។ ប្រសិនបើមើលទៅឃើញថា មានសំណុំឯកសារគ្រប់គ្រាន់ ហើយសាមីខ្លួនជាជនបរទេសបំពេញទៅតាមលក្ខខណ្ឌ ដែលបានកំណត់ហើយក្រសួងការបរទេសត្រូវបញ្ជូនសំណុំបែបបទនេះបន្តទៅឲ្យក្រសួងមហាផ្ទៃ។ ក្រសួងមហាផ្ទៃក៏មានពេលយ៉ាងយូរ ៥ថ្ងៃដែរ ដើម្បីពិនិត្យ និងចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍នេះ។ ពិនិត្យនិងចុះបញ្ជីចប់សព្វគ្រប់ហើយ ក្រសួងមហាផ្ទៃត្រូវជូនដំណឹង អំពីការសុំរៀបអាពាហ៍ពិពាហ៍នេះ ទៅខាងមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជាពលរដ្ឋខ្មែរហើយក៏ត្រូវជូនដំណឹងទៅសាមីខ្លួនជាជនបរទេសដែរ។ ទទួលបានចម្លើយពីក្រសួងមហាផ្ទៃ អំពីការចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍នេះហើយ សាមីខ្លួនទាំងពីរ គឺទាំងពលរដ្ឋខ្មែរ និងទាំងជនបរទេស ត្រូវរៀបចំដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ស្របពេលជាមួយគ្នាទៅឃុំ ឬសង្កាត់នៅខាងលំនៅរបស់សាមីខ្លួនជាពលរដ្ឋខ្មែរ ទៅតាមនីតិវិធីសុំអាពាហ៍ពិពាហ៍ធម្មតា។

- **សំណុំបែបបទសម្រាប់សាមីខ្លួនជាពលរដ្ឋខ្មែរ គឺត្រូវមានភ្ជាប់៖**
  - ពាក្យសុំរៀបអាពាហ៍ពិពាហ៍
  - សេចក្តីចម្លងសំបុត្រកំណើត
  - លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬម៉ែម៉ាយ ដែលចេញដោយមេឃុំ ឬចៅសង្កាត់
  - លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាល

ក្រោយពីពិនិត្យមើលសំណុំឯកសាររបស់សាមីខ្លួនទាំងពីរ ឃើញថា ត្រឹមត្រូវតាមច្បាប់ហើយ មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដើម្បីយកទៅបិទផ្សាយនៅផ្ទះរបស់សាមីខ្លួនជាពលរដ្ឋខ្មែរផង នៅសាលាឃុំ ឬសង្កាត់នេះផង និងនៅស្ថានទូត នៃប្រទេសរបស់សាមីខ្លួនជាជនបរទេសផង។ ១០ថ្ងៃក្រោយបន្ទាប់ពីបិទប័ណ្ណប្រកាសហើយ បើសិនជាមិនមានអ្នកណាប្តឹងតវ៉ាជំទាស់នឹងការរៀបអាពាហ៍ពិពាហ៍នេះទេ ទើបសាមីខ្លួនអាចរៀបចំពិធីអាពាហ៍ពិពាហ៍បាន។ នៅចុងបញ្ចប់នៃនីតិវិធីដើម្បីឲ្យអាពាហ៍ពិពាហ៍មានសុពលភាពពេញលក្ខណៈច្បាប់ សាមីខ្លួនទាំងពីរត្រូវទៅចុះបញ្ជីអាពាហ៍ពិពាហ៍នៅសាលាឃុំ

ឬសង្កាត់គឺនៅកន្លែងដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។ ការចុះបញ្ជីអាពាហ៍ពិពាហ៍នេះ ត្រូវមានវត្តមានផ្ទាល់របស់សាមីខ្លួនទាំងពីរ បូករួមជាមួយនឹងសាក្សី ដែលមានអាយុគ្រប់ការចំនួន២រូប។[23]

៣.ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា

ជនបរទេស និងអន្តោប្រវេសន៍ដែលរស់នៅស្របច្បាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍បានដោយអនុវត្តន៍តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន នៅទីកន្លែងដែលខ្លួនស្នាក់នៅជាប់លាប់ដោយប្រាប់ពីទីកន្លែង និងពេលវេលារៀបអាពាហ៍ពិពាហ៍នោះឲ្យបានច្បាស់លាស់។[24]

- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អាចទៅសុំចុះនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា (ប្រសិនបើមាន) ឬអាចទៅសុំចុះនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ដោយអនុវត្តន៍តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ អាចចុះសៀវភៅអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងអន្តោប្រវេសន៍នោះបានដោយអនុវត្តន៍តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅឃុំ ឬសង្កាត់ សម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តន៍ដូចគ្នានឹងការណែនាំចុះសៀវភៅអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរដែរ លើកលែងចំណុចមួយចំនួន ដូចខាងក្រោម៖
    - សញ្ជាតិ៖ ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន៍ដែលបានរៀបអាពាហ៍ពិពាហ៍ ។
    - ទីលំនៅឯបរទេស៖ ត្រូវសរសេរទីលំនៅរបស់សាមីខ្លួនប្តី ប្រពន្ធ នៅប្រទេសដើមរបស់ខ្លួន ជាអក្សរខ្មែរ ដោយបញ្ជាក់ពីទីលំនៅឯបរទេសអោយបានត្រឹមត្រូវ។
    - លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ ៖ ត្រូវសរសេរលេខលិខិតឆ្លងដែន និងថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។

[23] អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ជំពូកទី២ មាត្រា ៦ មាត្រា៧ មាត្រា៩

[24] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៥ មាត្រា ៣៨

– ទិដ្ឋាការ ឬលិខិតអនុញ្ញាតឲ្យស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ៖ ត្រូវសរសេរលេខទិដ្ឋាការ ឬលិខិតអនុញ្ញាតឲ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។

បញ្ជាក់៖ បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬលិខិតអនុញ្ញាតឲ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឲ្យចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទេ ហើយទន្ទឹមនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ត្រីមានសមត្ថកិច្ចភ្លាម។

៤.ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលកំពុងរស់នៅស្របច្បាប់ឯបរទេស

ដើម្បីបានប្រព្រឹត្តិទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់ស្តីពី អាពាហ៍ពិពាហ៍ នោះ ដែលត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ ការចុះសំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ បើប្តី ឬប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍ នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ចតចម្លងផ្លូវការនោះទុកហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី ឲ្យទៅជននោះយកទៅប្រើប្រាស់។[25]

❖ **អត្ថប្រយោជន៍ក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍ ចំពោះប្តី ឬប្រពន្ធដែលរៀបការ ៖**

១.ជាប្តីប្រពន្ធស្របច្បាប់ដែលផ្លូវច្បាប់ដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ ពោល គឺមានតែអំណាចតុលាការទើបអាចកាត់សេចក្តីលែងលះបាន

២.ទ្រព្យសម្បត្តិរួម ក្រោយអាពាហ៍ពិពាហ៍ត្រូវចែកគ្នាស្មើនៅពេលលែងលះ

៣.កាន់តែមានសុភមង្គល និងជឿទុកចិត្តគ្នាពេលមានសំបុត្រអាពាហ៍ពិពាហ៍

៤.ទទួលមរតកស្របច្បាប់

៥.ចុះសំបុត្រកំណើត ឬ បញ្ជាក់សំបុត្រកំណើតកូន

៦.ធ្វើប្លង់ ដី /ផ្ទះ

៧.ធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ

[25] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ជំពូកទី៤ មាត្រា៧៩-៨០

៨.ការពារប្រឆាំង នឹងទ្វេពន្ធភាព (ការពារប្រឆាំងការមានប្តីច្រើន ឬមានប្រពន្ធច្រើន)

៩.ជួយការពារទ្រព្យសម្បត្តិរួមរបស់ប្តី /ប្រពន្ធ

១០.ទទួលអាហារកិច្ចពេលឪពុកម្តាយលែងលះគ្នា

១១.គ្មានអំពើហិង្សាចំពោះកូន

១២.ការគាំទ្រដល់កូន។

ខ.លក្ខខណ្ឌ និងនីតិវិធី

❖ **ចំពោះលក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន៖**

- កិច្ចសន្យាអាពាហ៍ពិពាហ៍ ត្រូវធ្វើនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានភាគីខាងស្រី
- ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាមុននៅឃុំ សង្កាត់ ខាងលំនៅរបស់ភាគីខាងស្រី
- ការជូនដំណឹងជាសាធារណៈ អំពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យភាគីដែលពាក់ព័ន្ធអាចប្តឹងតវ៉ាបាន
- ភាគីទាំងពីរត្រូវមានភេទខុសគ្នា តាមគោលការណ៍ស្មគ្រចិត្តប្តីមួយ ប្រពន្ធមួយ
- បុរសអាចរៀបអាពាហ៍ពិពាហ៍ចាប់ពីអាយុ ២០ឆ្នាំឡើង ចំណែកនារីចាប់ពីអាយុ ១៨ឆ្នាំឡើង
- អាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់រវាងសាខាញាតិ ទោះជាសាខាញាតិនោះ មានខាន់ស្លា ឬឥតខាន់ស្លាក្តីរហូតដល់ខ្សែលោហិតទី៣ រាប់ទាំងខ្សែទីបីផងដែរ
- ចំពោះភាគីមិនទាន់មានអាយុគ្រប់ការ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល
- ក្នុងករណីភាគីម្ខាងមានអាយុចាប់ពី១៨ឆ្នាំឡើង ហើយភាគីម្ខាងទៀតមិនទាន់ដល់អាយុ១៨ឆ្នាំ ប៉ុន្តែមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់ភាគី ដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ
- សហព័ទ្ធ អាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន បើចំណងអាពាហ៍ពិពាហ៍ចាស់ ត្រូវបានរំលាយដោយអំណាចសាលក្រម ឬដោយភាគីម្ខាងទទួលមរណៈភាព។ ក្រោយរៀបអាពិហ៍ពិពាហ៍រួចបើប្តីស្លាប់ ឬលែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធីភាព (ភាពមេម៉ែមាយ) ចំនួន**៣០០ថ្ងៃ** គិតពីថ្ងៃដែលប្តីស្លាប់ ឬពីថ្ងៃប្រកាស សាលក្រមស្តាពរ។

❖ **ចំពោះបុរសនារី ដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន៖**

- បុគ្គលមានភេទដូចគ្នា
- បុគ្គលគ្មានពលានុភាពនៃលិង្គ
- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលជាដាច់
- ជនវិកលចរិត ជនមិនដឹងខុសត្រូវ បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ។
- បុគ្គលដែលជាប់ចំណងសាច់ញាតិលោហិត (ញាតិដែលមានឈាមជាមួយគ្នា) ឬញាតិពន្ធ (សាច់ថ្លៃ) ក្នុងខ្សែផ្ចាល់ ទោះជាចំណងនោះមានខាន់ស្លា ឬឥតខាន់ស្លា ឬសាច់ញាតិចិញ្ចឹម។

ឧទាហរណ៍ ៖ ឪពុក ម្តាយ និងកូន (ថ្នាក់ទី១) បងប្អូនបង្កើត (ថ្នាក់ទី២) មា មីង និងក្មួយ (ថ្នាក់ទី៣)មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ចំណែកឪពុកម្តាយ និងកូនប្រសារ (សាខាញាតិពន្ធថ្នាក់ទី១) បងប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២) មា មីង និងក្មួយប្រសារ (សាខាញាតិថ្នាក់ទី៣) អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានតាមផ្លូវច្បាប់ ប្រសិនបើសហព័ទ្ធណាមួយស្លាប់។

❖ **សៀវភៅអត្រានុកូលដ្ឋានដែលទាក់ទងនឹងអាពាហ៍ពិពាហ៍**

- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ (អនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៧)

❖ **ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍**

- សំបុត្រអាពាហ៍ពិពាហ៍។
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៧)។
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍។
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (សម្រាប់ចម្លងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រសួងមហាផ្ទៃ)។

❖ **ការដាក់ពាក្យ និងការជូនដំណឹង និងការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍**

បុរស នារីដែលមានបំណងរៀបអាពាហ៍អាពាហ៍តាមផ្លូវច្បាប់ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានសាមីខ្លួនខាងនារី។ បុរស នារីដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ ពុំទាន់បានសុំចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឲ្យមានការរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធមានលក្ខណៈជាប្តីប្រពន្ធស្របច្បាប់ មានបញ្ហាដូច្នេះសាមីខ្លួនទាំងពីរ

រូបត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់សាមី នៃលំនៅឋានដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន។

- **បុរស នារី ដែលមកសុំច្បាប់អាពាហ៍ពិពាហ៍ ត្រូវភ្ជាប់មកជាមួយនូវ៖**
  - ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនទាំងពីរទំហំ ៤x៦ ថតចំពីមុខក្នុងរយៈពេល០៣ខែចុងក្រោយ។
  - សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។
  - លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ របស់សាមីខ្លួនទាំងពីរនាក់ លិខិតបញ្ជាក់ត្រូវចេញដោយមេឃុំ ឬចៅសង្កាត់សាមី។ បើក្នុងករណីមេម៉ាយ ឬពោះម៉ាយ ដោយប្តី ឬប្រពន្ធស្លាប់ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព ប៉ុន្តែបើមេម៉ាយ ឬពោះម៉ាយលែងលះគ្នា ត្រូវភ្ជាប់មកជាមួយនូវសាលក្រមតុលាការ។
  - សៀវភៅគ្រួសារ ដែលមានទិន្នន័យរបស់សាមីខ្លួនទាំងពីរនាក់ច្បាស់លាស់ និងត្រឹមត្រូវ។
- **នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវត្រួតពិនិត្យឲ្យបានហ្មត់ចត់ចំពោះបុរស នារីដែលបានដាក់ពាក្យសុំនោះ ៖**
  - បើពិនិត្យទៅឃើញថាមិនមានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាននោះទេ មន្ត្រីអត្រានុកូលដ្ឋានមិនអនុញ្ញាតឲ្យបុរសនារីនោះរៀបអាពាហ៍ពិពាហ៍បានឡើយ។
  - បើពិនិត្យទៅឃើញថា មានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈចំនួន ០៥ច្បាប់ដូចខាងក្រោម ៖
    - ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅលំនៅដ្ឋានសាមីខ្លួននារី។
    - ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
    - ០១ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី។
    - ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅដ្ឋានសាមីខ្លួនបុរស០១ច្បាប់ និងនៅសាលាឃុំ ឬសង្កាត់សាមីខ្លួនបុរស ០១ច្បាប់។
- **ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈ**

ក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបណ្តឹងទាស់ត្រូវបានដោះស្រាយរួចរាល់តាមគោលការណ៍ដែលបានចែងក្នុងក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន។

មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- នាមត្រកូល និងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្ន នៃអនាគតប្តី ឬប្រពន្ធ។
- នាមត្រកូល និងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្នរបស់ឪពុក ម្តាយ នៃអនាគតប្តីប្រពន្ធ (បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ផង)។

❖ **ចំពោះមោឃភាពនៃអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍ត្រូវចាត់ជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះ ចុះបញ្ជីនៅពេល ដែលសហព័ទ្ធណាម្នាក់ឆ្គួត ឬមិនដឹងខុសត្រូវ។ តែបើសហព័ទ្ធនោះបានជាស្រួលឡើងវិញ ហើយហេតុដែលនាំឲ្យទុកជាមោឃៈនោះ ត្រូវបានរលាយទៅវិញដែរ។ ចំពោះអាពាហ៍ពិពាហ៍រវាងបុរសអាយុតិចជាង ២០ឆ្នាំ ឬនារីអាយុតិចជាង ១៨ឆ្នាំ ត្រូវទុកជាមោឃៈ។ ប៉ុន្តែកាលបើប្តី ឬប្រពន្ធនោះដល់អាយុតាមបញ្ញត្តិច្បាប់ អាចរៀបអាពាហ៍ពិពាហ៍វិញបាន។

❖ **នីតិវិធីនៃការស្នើសុំសំបុត្រចម្លង និង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍**

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ មិនត្រូវអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេស ក្នុងករណីដូចជា៖

- សំណុំឯកសាររៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសពុំបានចុះបញ្ជី និងពុំបានជូនដំណឹងពីការរៀបអាពាហ៍ពិពាហ៍ពីក្រសួងមហាផ្ទៃ។
- សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ឬរបស់សាមីខ្លួនពលរដ្ឋខ្មែរពុំបានបំពេញត្រឹមត្រូវតាមបែបបទ និងនីតិវិធីដែលបានកំណត់។
- សាមីខ្លួនពលរដ្ឋខ្មែរពុំមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងឃុំ ឬសង្កាត់ក្នុងដែនដីដែលខ្លួនគ្រប់គ្រង។
- សាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេសពុំទាន់គ្រប់អាយុដែលច្បាប់អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍។
- មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ហើយមិនបានដោះស្រាយឲ្យបានចប់សព្វគ្រប់។

❖ **បំរាម និងការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍**

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវដូចខាងក្រោម៖

- ត្រូវប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានដែលបោះពុម្ពតាមគំរូឯកភាពចេញដោយក្រសួងមហាផ្ទៃ និងអនុវត្តឲ្យបានត្រឹមត្រូវតាមបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋានអំពីការចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ការចេញសំបុត្រអាពាហ៍ពិពាហ៍ និងការចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍។
- រាល់សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្រៅពីខ្ចង់សរសេរឈ្មោះជាអក្សរឡាតាំង គឺមិនអនុញ្ញាតឲ្យសរសេរភាសាបរទេសបញ្ចូលឡើយ។
- រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទមិនអនុញ្ញាតឲ្យ កោស ឆូត លុប ឬសរសេរជ្រៀតឡើយ។

២.១.២.អត្រានុកូលដ្ឋានមរណភាព

និយមន័យមរណភាព

មរណភាព របស់បុគ្គលម្នាក់ៗជាព្រឹត្តិការណ៍គតិយុត្ត ដែលនាំអោយបុគ្គលិកលក្ខណៈគតិយុត្តរបស់រូបវន្តបុគ្គលនោះត្រូវបញ្ចប់ គឺជាសេចក្តីស្លាប់ ឬស្ថានភាពនៃការទទួលរងនូវសេចក្តីស្លាប់។ ទោះបីជាបុគ្គលិកលក្ខណៈគតិយុត្ត ត្រូវបានបញ្ចប់នៅពេលមរណភាពក៏ដោយ ក៏ច្បាប់បានកំណត់ទទួលស្គាល់ និងបានផ្តល់នូវអានុភាពខាងផ្លូវច្បាប់ខ្លះ ដូចជាបណ្តាំសាសន៍ជាដើម។

នឹងចាត់ទុកថាមរណភាព ក្នុងករណីមានបុគ្គលណាម្នាក់បានបាត់ខ្លួន ឬអវត្តមានក្នុងថេរវេលាមួយដែលច្បាប់បានកំណត់ ហើយគ្មាននរណាដឹងថាជននោះស្លាប់ ឬរស់ ហើយមានញាតិលោហិត ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធបានប្តឹងសុំឲ្យតុលាការប្រកាសពីការបាត់ខ្លួន ឬអវត្តមានរបស់ជននោះ ហើយប្រសិនបើតុលាការចេញសាលក្រមថាការបាត់ខ្លួន ឬអវត្តមាន ថាជាមរណភាព។

ក.ការកើតឡើងនូវអត្រានុកូលដ្ឋានមរណភាព

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិ ឬអ្នកជិតខាង ឬអ្នកមានភារកិច្ច នៅក្រសួងស្ថាប័នអង្គភាពអ្នកស្លាប់ត្រូវរាយការណ៍ជូនទៅមន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ជាទីកន្លែងដែលអ្នកស្លាប់នោះរស់នៅជាប់លាប់។ បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដូចជា ស្លាប់ដោយសារជម្ងឺ ឬដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ និងពាក់ព័ន្ធដល់មានមន្ទិលសង្ស័យ ដោយអំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់

អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកស្លាប់នោះ ដើម្បីឲ្យសមត្ថកិច្ចជំនាញនានាពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ឬបើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឲ្យគ្រោះថ្នាក់ដល់សង្គមត្រូវរាយការណ៍ទៅមន្ទីរពេទ្យភ្លាម។ ក្រោយពីមានការសម្រេច យ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឲ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន។ ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ឲ្យទាន់ពេលវេលាចំពោះការប្រគល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹកនេះ ទៅឲ្យអ្នកមករាយការណ៍អំពីមរណភាពដែលសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពដោយមិនមានបង់ថ្លៃអ្វីឡើយ។ ប៉ុន្តែក្នុងករណីបើមានអ្នកស្លាប់ទុកអោយហួសរយៈពេលកំណត់ ១៥ថ្ងៃ ឬទុកឲ្យហួសមួយឆ្នាំបន្ទាប់ពីស្លាប់ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពនោះទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវទៅប្តឹងសុំសាលក្រមពីតុលាការរាជធានីខេត្ត-ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព។[26]

បញ្ហាក់: ចំពោះសាកសពដែលមិនស្គាល់អត្តសញ្ញាណមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពដោយសរសេរយោងកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច នៅរឹមទំព័រខាងឆ្វេងនៃបញ្ជីមរណភាពហើយសរសេរចុះនៅក្នុងបញ្ជីមរណភាព តាមខ្លឹមសារនៃកំណត់ហេតុរបស់សមត្ថកិច្ច ដូចជា៖

- ភេទ
- ទីកន្លែងស្លាប់ : យកកន្លែងដែលឃើញសាកសព
- មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍ : យកតាមកំណត់ហេតុរបស់សមត្ថកិច្ច
- ថ្ងៃ ខែ ឆ្នាំ ស្លាប់ : យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចច្បាប់ចម្លង០១ច្បាប់ ជាឯកសារនៅសាលាឃុំ សង្កាត់។

❖ **សម្រាប់ប្រជាពលរដ្ឋខ្មែរ**

បើមានពលរដ្ឋខ្មែរស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់នោះរស់នៅដើម្បីជូនដំណឹងដល់ក្រុមគ្រួសារអ្នកស្លាប់ ឲ្យទៅយកសពធ្វើបុណ្យតាមប្រពៃណី ត្រូវចុះសៀវភៅមរណភាពនៅឃុំ សង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់។ បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មាន

[26] អនុក្រឹត្យលេខ១០៣ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៦ មាត្រា ៣៥-៣៦

អ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬបញ្ចុះសពនោះនិងចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ។[27]

❖ **ចំពោះទណ្ឌិតដែលបានស្លាប់នៅពន្ធនាគារ**

ប្រសិនបើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះ ដើម្បីឲ្យមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព។ ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាព រួចប្រគល់អោយអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។[28]

❖ **ចំពោះពលរដ្ឋខ្មែរដែលស្លាប់នៅឯបរទេស**

បើមានពលរដ្ឋខ្មែរស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ។ ពេលត្រឡប់មកប្រទេសកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅប្រទេសនោះទៅចុះសៀវភៅនៅឃុំ ឬសង្កាត់ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនចេញទៅបរទេស។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់អោយសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់។ បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់ទៅប្រទេសកម្ពុជាវិញអាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន។[29]

❖ **សម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ ដែលរស់នៅប្រទេសកម្ពុជា**

ចំពោះជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីប្រទេសកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវអាចទៅសុំចុះសៀវភៅមរណភាពនៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅ នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅប្រទេសកម្ពុជាប្រសិនបើមាន។ ការចុះ

[27] អនុក្រឹត្យលេខ១០៣ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៦ មាត្រា ៣៧
[28] អនុក្រឹត្យលេខ១០៣ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៦ មាត្រា ៣៨
[29] អនុក្រឹត្យលេខ១០៣ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៦ មាត្រា ៤១

ឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងរួមជាមួយអក្សរខ្មែរផងហើយរបៀបចុះសៀវភៅអត្រានុកូលដ្ឋានជនបរទេស និងជនអន្តោប្រវេសន៍ត្រូវអនុវត្តដូចគ្នា។[30]

សម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ ត្រូវមានឯកសារបន្ថែមទៀតដូចជា ៖

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលនៅមានសុពលភាព
- សញ្ជាតិ ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន៍ដែលស្លាប់ (តាមលិខិតឆ្លងដែន)
- ទីលំនៅឯបរទេស ត្រូវសរសេរទីលំនៅ នៅប្រទេសដើមរបស់អ្នកស្លាប់ជាអក្សរខ្មែរ ដោយបញ្ជាក់ទីលំនៅឯបរទេសឲ្យបានពិតប្រាកដ
- ទិដ្ឋាការ ឬលិខិតអនុញ្ញាតឲ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅមានសុពលភាព។

បញ្ជាក់ : បើលិខិតស្មាមណាមួយមានការសង្ស័យ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើទំនាក់ទំនងជាមួយនឹងសមត្ថកិច្ចដែលពាក់ព័ន្ធនឹងលិខិតស្មាមនោះ។

➢ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្មាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព ៖

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀតករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្មាមដែលពាក់ព័ន្ធនឹងសពរួមជាមួយទៅអ្នករាយការណ៍វិញក្រៅពីលិខិតស្មាមចាំបាច់ដែលត្រូវរក្សាទុក នឹងការសរសេរចុះបញ្ជីមរណភាពរបស់ពលរដ្ឋខ្មែរដែរ។

❖ **សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព**

- សៀវភៅអត្រានុកូលដ្ឋានមរណភាព (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព

ចំពោះសៀវភៅចម្លងមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព មិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

[30] អនុក្រឹត្យលេខ១០៣ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ជំពូកទី៦ មាត្រា ៤២

❖ **ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព**

- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព
- សេចក្តីចម្លងសំបុត្រមរណភាព
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព

❖ **លិខិតស្នាមនានា ដែលពាក់ព័ន្ធនឹងសព**

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមនានា ដូចជា ៖

- លិខិតជូនដំណឹងមរណភាព
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់មានការទាក់ទងនឹងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ទៅស្លាប់ក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងពន្ធនាគារ ។
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)។
- សំបុត្រមរណភាពច្បាប់ដើមចាស់ ក្នុងករណី អ្នកស្លាប់មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រមរណភាពច្បាប់ដើម ដើម្បីប្តូរយកសំបុត្រមរណភាពថ្មី។

❖ **នីតិវិធី អ្នកដែលមានសិទ្ធិសុំចុះបញ្ជីបញ្ជាក់មរណភាព**

- បើប្តីស្លាប់ អ្នកមានសិទ្ធិ គឺប្រពន្ធ
- បើប្រពន្ធស្លាប់ អ្នកមានសិទ្ធិ គឺប្តី
- បើឪពុក ម្តាយស្លាប់ អ្នកមានសិទ្ធិ គឺកូនទី១
- បើឪពុក ម្តាយ និងកូនទី១ស្លាប់ អ្នកមានសិទ្ធិ គឺកូនទី២ ។ល។

❖ **លិខិតស្នាមសម្រាប់បង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់**

- សៀវភៅគ្រួសាររបស់សាមីខ្លួនអ្នកសុំបញ្ជាក់ និងរបស់សាក្សី (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន អ្នកសុំបញ្ជាក់ និងរបស់សាក្សី (ប្រសិនបើមាន)
- សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាពក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់ នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ហើយត្រូវបោះត្រាផង។
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាស្រុក ខណ្ឌ ឬនៅតុលាការខេត្ត ក្រុងសាមី។
- បើសុំចម្លង ឬសម្រង់នៅសាលាស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលស្រុក ខណ្ឌ និងបោះត្រាផង
- បើសុំចម្លង ឬសម្រង់នៅតុលាការខេត្ត ក្រុង ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី (មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន) និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយប្រធានតុលាការ ឬចៅក្រមជំនួស និងបោះត្រាផង។
- ប្រសិនបើប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់នៅឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ។
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង។
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់ នៅក្រសួងមហាផ្ទៃ ឬក្រសួងយុត្តិធម៌ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ។
- អ្នកមកសុំចម្លង ឬសម្រង់សំបុត្រមរណភាព ត្រូវយកសំបុត្រមរណភាពច្បាប់ដើមមកជាមួយ។

- អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ត្រូវយកសំបុត្របញ្ជាក់មរណភាពច្បាប់ដើមមកជាមួយ។
- សម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានមរណភាពនិងសៀវភៅបញ្ជាក់មរណភាពដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារតាមសំណើររបស់អ្នកមកសុំស្រង់ប៉ុណ្ណោះ។

២.២.សារៈប្រយោជន៍នៃលិខិតអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន ជាសេវាមូលដ្ឋានមួយរបស់រដ្ឋ ដែលផ្តល់ប្រយោជន៍ចំពោះប្រជាពលរដ្ឋផង និងសង្គមជាតិផង។ អត្រានុកូលដ្ឋានជាកត្តាមួយចូលរួមចំណែកក្នុងការអភិវឌ្ឍ វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសង្គមមានភាពសុខសាន្ត និងសុវត្ថិភាពដ៏រឹងមាំ។ សៀវភៅអត្រានុកូលដ្ឋានបានតម្កល់ទុកជាសក្ខីកម្មដែលមានប្រយោជន៍សម្រាប់ទិន្នន័យវិភាគនូវឯកសារផ្សេងៗ ដូចជា សម្រាប់ធ្វើបញ្ជីបោះឆ្នោត ទិញលក់អចលនទ្រព្យជាដើម។ អត្រានុកូលដ្ឋានបានផ្តល់សារៈប្រយោជន៍ចំពោះ សង្គមជាតិ និងចំពោះខ្លួនយើងដូចជា៖

២.២.១.សារៈប្រយោជន៍ចំពោះសង្គមជាតិ

ជួយពង្រឹងនីតិរដ្ឋ និងអភិវឌ្ឍន៍ប្រទេសជាតិ: មានន័យថា ប្រសិនបើប្រជាពលរដ្ឋបានបំពេញកាតព្វកិច្ចចុះអត្រានុកូលដ្ឋានគ្រប់ៗគ្នា ការប្រតិបត្តិច្បាប់ និងដំណើរការស្តាប់ននានា នោះវានឹងផ្តល់លទ្ធភាពងាយស្រួលដល់រដ្ឋក្នុងការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងងាយស្រួលក្នុងការលើកផែនការអភិវឌ្ឍន៍។

លើកម្ពស់កិត្យានុភាពជាតិ : បើប្រជាពលរដ្ឋមានសំណុំឯកសារផ្ទាល់ខ្លួនគ្រប់ៗគ្នា មានន័យថាប្រជាពលរដ្ឋយើងបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយតម្រូវអោយខ្លួនមានការណែកិច្ចក្នុងសង្គមដែលជាហេតុធ្វើឲ្យសង្គមមានការអភិវឌ្ឍន៍ តាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។ ទាំងនេះហើយជាភាពថ្លៃថ្នូរ និងកិត្តិយសរបស់ប្រទេសជាតិ។

ជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម : ព្រោះថាអត្រានុកូលដ្ឋានបានបង្ហាញច្បាប់អត្តសញ្ញាណនៃរូបវន្តបុគ្គលក្នុងទំនាក់ទំនងគតិយុត្តិ ហេតុដូចនេះ ឯកសារអត្រានុកូលដ្ឋានមានប្រយោជន៍ជាសំណុំលិខិតយុត្តិកម្មដែលត្រូវយកជាភស្តុតាងក្នុងនីតិវិធីតុលាការ។

២.២.២. សារៈប្រយោជន៍ចំពោះខ្លួនឯង

- សម្រាប់បញ្ជាក់ពីឋានៈ និងសិទ្ធិក្នុងវង្វង់គ្រួសារ
- សម្រាប់សុំលិខិតឆ្លងដែន
- សម្រាប់សុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងចេញសៀវភៅគ្រួសារ និងប័ណ្ណស្នាក់នៅ

- សម្រាប់ចូលបម្រើការងារផ្សេងៗដើម្បីបញ្ជាក់ថាបុគ្គលម្នាក់មានអាយុអាចបំពេញការងារបាន
- សម្រាប់ចុះឈ្មោះចូលរៀនតាមគ្រឹះស្ថានសិក្សានានារបស់រដ្ឋ និងឯកជន
- សម្រាប់ចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត
- សម្រាប់ការប្រលងប្រជែងចូលធ្វើជាមន្ត្រីរាជការ

ការមិនបានចុះសៀវភៅអត្រានុកូលដ្ឋាននាំឲ្យពលរដ្ឋបាត់បង់អត្តសញ្ញាណផ្ទាល់ខ្លួន ការបាត់បង់នេះនឹងបង្កការលំបាកក្នុងសង្គមពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួនពលរដ្ឋ និងខកខានមិនបានបំពេញករណីយកិច្ចចំពោះគ្រួសារ ក៏ដូចជាចំពោះប្រទេសជាតិ ជាពិសេសពាក់ព័ន្ធក្នុងនីតិវិធីរដ្ឋបាលក៏ដូចជា នីតិវិធីតុលាការដែលគេតម្រូវការភស្តុតាងជាសំអាងនៅចំពោះមុខច្បាប់ ។

ជំពូកទី ៣
បញ្ហាចោទឡើងផ្សេងៗ និងវិធីដោះស្រាយ

៣.១.កំណែតម្រូវ និងការសុំអោយភាពមិនច្បាស់

ការចុះបញ្ជីអត្រានុកូលដ្ឋាន ឬលិខិតស្នាមដទៃទៀតឲ្យបានត្រឹមត្រូវ គឺជាការសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ ព្រោះការចុះបញ្ជី ឬលិខិតស្នាខ្លះ ពិបាកក្នុងការធ្វើការកែប្រែណាស់ និងមានភាពស្មុកស្មាញក្នុងនីតិវិធីនៃការកែប្រែ ហើយការចុះបញ្ជីខ្លះទៀតមិនអាចចុះជាលើកទីពីរបាន ដូចជា ការចុះបញ្ជីអត្រានុកូលដ្ឋានកំណើតជាដើម។

ប្រជាពលរដ្ឋប្រមាណ ៣៥ ភាគរយនៃប្រជាពលរដ្ឋទាំងអស់ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណ ឬលិខិតស្នាមនានារួច ហើយដែលកំពុងជួបប្រទះបញ្ហាខុសទិន្នន័យគ្នា ដូចជាមានប្រជាពលរដ្ឋខ្លះបានធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានលើសពីមួយដង ដូចដែលច្បាប់បានកំណត់។

យោងតាមអនុក្រឹត្យលេខ១៣៨អនក្រ.បក ចុះថ្ងៃទី០៥ខែកក្កដាឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ បានផ្តល់សមត្ថកិច្ចមួយចំនួនដល់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យសម្រេចនិងអនុញ្ញាតឲ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានឡើងវិញស្របតាមបញ្ញត្តិច្បាប់។ អនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការកែតម្រូវ និងការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋាន ដើម្បីដោះស្រាយការលំបាកចំពោះមុខរបស់ប្រជាពលរដ្ឋ។

ក្នុងការអនុវត្តសេចក្តីណែនាំលេខ០៣៥ សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ សម្រាប់រយៈពេល ០២ឆ្នាំកន្លងមក គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋឲ្យទទួលបានសេវាកែតម្រូវ និងធ្វើមោយភាព ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន កាន់តែងាយស្រួល និងទូលំទូលាយ។ បច្ចុប្បន្នប្រជាពលរដ្ឋកាន់តែច្រើនបានទទួលព័ត៌មានអំពីដំណើរការ និងនីតិវិធីនៃការកែតម្រូវ និងធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាននៅក្រសួងមហាផ្ទៃនេះ ហើយបន្តគាំទ្រ និងមកស្នើសុំកែតម្រូវ និងធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន តាមរយៈរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។[31] ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងបន្តជួយការផ្តល់សេវានេះ ក្រសួងមហាផ្ទៃសម្រេចដាច់ចេញនូវសេចក្តីណែនាំថ្មីស្តីពីការបន្តដំណើរការកែតម្រូវ និងការឆ្លើយមោយភាពនៃបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

[31]សេចក្តីណែនាំលេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៩ ស្តីពីការបន្តដំណើរកែតម្រូវ និងធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

៣.១.១.អំពីចិន្តន័យដែលអាចកែតម្រូវបាន

១.ការខុសឆ្គងអក្ខរាវិរុទ្ធលើ នាមត្រកូល និង/ឬនាមខ្លួនជា "អក្សរខ្មែរ"និង"អក្សរឡាតាំង"របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្តាយ(មានន័យថាសូរសំឡេងដូចគ្នា ឬប្រហាក់ប្រហែលគ្នាប៉ុន្តែការសរសេរខុសគ្នា)។

២.ការសរសេរខុស"ភេទ"នៅពេលចុះបញ្ជី ដូចជា ភេទ "ប្រុស"តែសរសេរដាក់ថាភេទ"ស្រី"ឬភេទ"ស្រី" តែសរសេរដាក់ថាភេទ"ប្រុស"។

៣.អាយុរបស់ឪពុក ឬម្តាយតិចជាង ឬតំណាលគ្នានឹងអាយុកូនដែលមិនសមនឹងកើតមាន ឬការចុះបញ្ជីថ្ងៃខែឆ្នាំកំណើតច្រឡំ ដូចជា កើតឆ្នាំ១៩៧៥ដាក់ថាឆ្នាំ១៩៥៧។

៤.ខុសថ្ងៃកំណើតសុរិយគតិ(ដូចជាថ្ងៃទី៣០ខែកុម្ភៈឬថ្ងៃទី៣១ខែមេសា)។

៥.ខុសថ្ងៃកំណើតចន្ទគតិ ដូចជាសរសេរចុះដាក់ថ្ងៃច័ន្ទទី១៣ ខែមេសា ឆ្នាំ១៩៧២ ប៉ុន្តែជាក់ស្តែង នៅថ្ងៃទី១៣ខែមេសាឆ្នាំ១៩៧២ជាថ្ងៃព្រហស្បតិ៍។

៦.ការភាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល ដូចជាសរសេរដាក់ថា ស្រុកកំពង់សៀម ខេត្តកំពង់ស្ពឺ ប៉ុន្តែជាក់ស្តែងស្រុកកំពង់សៀម ស្ថិតក្នុងខេត្តកំពង់ចាម។

៧.ខ្វង់ទីកន្លែងកំណើត បានសរសេរខុសពីទីកន្លែងកំណើតដែលសាមីខ្លួនកើតជាក់ស្តែង ឬសរសេរខុសពីទីតាំងភូមិសាស្ត្ររដ្ឋបាលនាសម័យដែលបុគ្គលនោះកើត ឧទាហរណ៍ បញ្ជីកំណើតរបស់បុគ្គលម្នាក់បានចុះថា កើតឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែ ក្នុងអំឡុងឆ្នាំ ១៩៨៥ ស្រុកមង្គលបុរី ស្ថិតនៅក្នុងខេត្តបាត់ដំបង ពីព្រោះមិនទាន់បង្កើតខេត្តបន្ទាយមានជ័យនៅឡើយ។

៨.ការខកខានមិនបានចុះព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋានលើកលែងតែការបន្ថែមទិន្នន័យព័ត៌មានណាដែលធ្វើឲ្យសាមីខ្លួនរួចផុតពីការទទួលខុសត្រូវផ្លូវច្បាប់។

៩.សម្រេចមោយភាពលើបញ្ជីអត្រានុកូលដ្ឋាន ទាំងឡាយណាដែលបានចុះជាន់គ្នា។

១០.កែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ។

៣.១.២.អំពីសមត្ថកិច្ច

១.ក្នុងឆ្នាំកំពុងអនុវត្តការកែតម្រូវទិន្នន័យ និងការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។

២.ក្នុងឆ្នាំកន្លងផុតការកែតម្រូវទិន្នន័យ និងការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋាន ជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៣.ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមិនអាចសម្រេចកែតម្រូវទិន្នន័យព័ត៌មាន ដូចមានចែងក្នុងចំណុច"ក"ខាងលើ ឬការកែតម្រូវទិន្នន័យដែលមិនមែនជាសមត្ថកិច្ចរបស់ខ្លួនត្រូវជូនទៅតុលាការជាសមត្ថកិច្ច។

៣.១.៣.អំពីនីតិវិធី

ក.ការកែតម្រូវ

សាមីជន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋានទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅសាលាឃុំ សង្កាត់ ក្នុងករណីពិនិត្យឃើញថាសំបុត្រអត្រានុកូលដ្ឋានរបស់ខ្លួនបានសរសេរទិន្នន័យព័ត៌មានមួយចំនួនខុស។ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ត្រូវកែតម្រូវបញ្ជីអត្រានុកូលដ្ឋានរបស់អ្នកដាក់ពាក្យសុំ ស្របតាមការណែនាំនៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន។

ខ.ការដាក់ពាក្យសុំ

សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន (ឧបសម្ព័ន្ធ១) នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។ សាលាក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននិងកំពុងរក្សាទុក។ ទទួលបានពាក្យសុំ សាលាក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនសំណុំឯកសារពាក់ព័ន្ធមកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរ០៣ (បី) ថ្ងៃការងារ។

គ.ឯកសារភ្ជាប់

- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និង/ឬសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់
- សៀវភៅស្នាក់នៅ និង/ឬសៀវភៅគ្រួសារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អាយុចាប់ពី១៥ឆ្នាំឡើង) ឬ
- លិខិតឆ្លងដែន បើមាន
- ឯកសារពាក់ព័ន្ធផ្សេងៗ ដូចជាប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ។ល។
- រាល់ឯកសារភ្ជាប់ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលត្រឹមត្រូវ លើកលែងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់។

ឃ.ការសម្រេចកែតម្រូវរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវធ្វើជាសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យលើទិដ្ឋភាពច្បាប់នៃឯកសារពាក់ព័ន្ធ និងមូលហេតុនៃការស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន។ ក្នុងករណីចាំបាច់នាយកដ្ឋានអត្រានុកូលដ្ឋានអាចស្រាវជ្រាវបន្ថែម អំពីមូលហេតុនៃស្នើសុំកែតម្រូវបញ្ជីអត្រានុកូលដ្ឋាននេះបាន។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវចេញសំបុត្រអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមថ្មី០១(មួយ)ច្បាប់ ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែងដែលចេញសំបុត្រអត្រានុកូលដ្ឋាននោះរួចដកហូត និងមោយៈនូវសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមចាស់ និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានដែលខុសទាំងអស់។

- **ការស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋានត្រូវពិនិត្យសម្រេច៖**

មិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវដែលដាក់នៅនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងមិនឲ្យលើសរយៈពេល២០ថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវដែលដាក់នៅសាលាក្រុង ស្រុក ខណ្ឌ។

- **សេចក្តីសម្រេចកែតម្រូវត្រូវធ្វើឡើងចំនួន០៤ (បួន) ច្បាប់ ក្នុងនោះ៖**

០១(មួយ) ច្បាប់សម្រាប់ចម្លងជូនសាលារាជធានី ខេត្ត

០១(មួយ) ច្បាប់សម្រាប់បញ្ជូនទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ និង

០១(មួយ) ច្បាប់សម្រាប់សាមីខ្លួន។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិអាចសម្រេចបដិសេធមិនឲ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមការស្នើសុំបាន ដោយមានបញ្ជាក់អំពីមូលហេតុជាក់លាក់ ករណីនេះសាមីខ្លួនអាចប្តឹងជំទាស់ទៅតុលាការបាន។

៣.២.កំណែតម្រូវ និងការធ្វើមោយភាព

១.សម្រាប់ឆ្នាំកំពុងអនុវត្ត

ការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋាន ត្រូវធ្វើសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិក្នុងការពិនិត្យសម្រេចលើការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋានទាំងឡាយណាដែលៈ

- ចុះបញ្ជីផ្ទុយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន
- ចុះបញ្ជីអត្រានុកូលដ្ឋានលើសពី០១ (មួយ)ដង នៅកន្លែងដដែល ឬនៅកន្លែងផ្សេងទៀត។

ករណីរកឃើញបញ្ហាដូចខាងលើនេះ នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវជូនដំណឹងដល់សាមីខ្លួន ឬអាណាព្យាបាល តាមរយៈអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដើម្បីឲ្យដាក់ពាក្យធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើសពី០១ដងនោះ ដើម្បីធ្វើការជ្រើសរើសយកបញ្ជីណាមួយដែលជាទិន្នន័យត្រឹមត្រូវដើម្បីប្រើប្រាស់ជាផ្លូវការ។

ករណីដែលសាមីខ្លួន ឬអាណាព្យាបាលមិនដាក់ពាក្យសុំធ្វើមោយភាពបញ្ជីណាមួយ ក្នុងអំឡុងពេល ៦០(ហុកសិប)ថ្ងៃ ចាប់ពីទទួលបានលិខិតជូនដំណឹង មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមានសិទ្ធិចេញសេចក្តីមោយភាពសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទក្រោយ។

- **សេចក្តីសម្រេចធ្វើមោយភាពត្រូវធ្វើឡើងចំនួន០៤ (បួន) ច្បាប់នោះ៖**
  - ០១(មួយ) ច្បាប់សម្រាប់បញ្ជូនទៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ
  - ០១(មួយ) ច្បាប់សម្រាប់ចម្លងជូនសាលារាជធានី ខេត្ត
  - ០១(មួយ) ច្បាប់សម្រាប់បញ្ជូនទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ និង
  - ០១(មួយ) ច្បាប់សម្រាប់សាមីខ្លួន។

សាមីខ្លួនអាចធ្វើការតវ៉ាពីការសម្រេចនេះមកមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ យ៉ាងយូរបន្ទាប់ពីបានទទួលសេចក្តីសម្រេចធ្វើមោយភាពនេះ។

២.ការអនុវត្តការងាររបស់មន្ត្រីរក្សាសៀវភៅ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវ៖

កិបភ្ជាប់សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ នៅគល់បញ្ជីអត្រានុកូលដ្ឋានដែលត្រូវធ្វើការកែតម្រូវទិន្នន័យ ឬមោយភាពបញ្ជីអត្រានុកូលដ្ឋាន

ធ្វើការកែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកបិចព៌ណក្រហម និងសរសេរជួសនូវទិន្នន័យដែលត្រឹមត្រូវដោយទឹកបិចពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើគល់បញ្ជីដែលត្រូវធ្វើការកែតម្រូវទិន្នន័យនោះ តាមខ្លឹមសារដូចមាននៅក្នុង(ឧបសម្ព័ន្ធទី៣)។

ធ្វើការមោយភាពបញ្ជីអត្រានុកូលដ្ឋាន ដោយសរសេរទឹកបិចពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើគល់បញ្ជីដែលត្រូវមោយភាពនោះ តាមខ្លឹមសារដូចមាននៅក្នុង(ឧបសម្ព័ន្ធទី៤)។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានតាមការស្នើសុំ ដោយផ្អែកលើសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិការកែតម្រូវ និងការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋានណាមួយដែលមានចេតនាធ្វើឲ្យប្រាសចាកការពិតត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ជាធរមាន។

៣.២.១.បញ្ហាប្រឈមដែលប្រជាពលរដ្ឋជួបប្រទះញឹកញាប់

ការចុះបញ្ជីអត្រានុកូលដ្ឋាន តាមរយៈការសិក្សាផ្សៀងផ្ទាត់ទិន្នន័យទៅលើប្រជាពលរដ្ឋនាពេលកន្លងមក ក្រសួងមហាផ្ទៃបានកត់សម្គាល់ឃើញថាប្រជាពលរដ្ឋដែលកំពុងជួបប្រទះបញ្ហាខុសទិន្នន័យ អត្តសញ្ញាណរបស់ខ្លួននៃអត្រានុកូលដ្ឋានប្រភេទតែមួយលើសពីមួយដង ជាពិសេសការចុះបញ្ជីក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ដែលបានធ្វើឲ្យសាមីខ្លួនជួបការលំបាកយ៉ាងខ្លាំងក្នុងការស្នើសុំសេវារដ្ឋបាលស្មុគស្មាញ ដែលមិនអាចឆ្លើយតបបានទៅ នឹងសំណូមពររបស់ប្រជាពលរដ្ឋ។ តែយ៉ាងណាក្តី កំហុសបច្ចេកទេសទាំងនោះ ត្រូវបានធ្វើការកែប្រែរួចឲ្យអស់ក្នុងរយៈពេលប្រាំឆ្នាំមកហើយ ដោយមានការអំពាវនាវដល់មន្ត្រីអត្រានុកូលដ្ឋានគ្រប់ជាន់ថ្នាក់ ធ្វើការប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ ជៀសវាងការភ័ន្តច្រឡំ និងខុសទិន្នន័យ ដែលជាកត្តាធ្វើឲ្យខ្វះទំនុកចិត្តពីប្រជាពលរដ្ឋទៅលើសមត្ថកិច្ច។ សូមបញ្ជាក់ថាកន្លងមកមន្ត្រីអត្រានុកូលដ្ឋានមួយចំនួនរងការរិះគន់ថាបានបំពេញការងារចុះបញ្ជីអត្រានុកូលដ្ឋានដោយខ្វះការប្រុងប្រយ័ត្នចំពោះការយល់ដឹងរបស់មន្ត្រីនៅមានកំរិត និងរួមផ្សំផងដែរនូវអំពើពុករលួយជាហេតុនាំឲ្យមានការថ្នាំងថ្នាក់ចិត្តខ្លះពីប្រជាពលរដ្ឋមួយចំនួនផងដែរទាក់ទងនឹងសកម្មភាពនៃការផ្តល់សេវារបស់មន្ត្រី។ ចំពោះនៅឃុំ សង្កាត់ការផ្តល់សេវាពេលខ្លះមានការយឺតយ៉ាវក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ឬឃុំ សង្កាត់ខ្លះមានការខ្វះខាតសៀវភៅអត្រានុកូលដ្ឋាន(អស់សៀវភៅ) សម្រាប់ការចុះបញ្ជីឲ្យពួកគាត់មិនទាន់ពេលវេលាដែលប្រជាពលរដ្ឋត្រូវការ។

បញ្ហាទាក់ទងនិងឥរិយាបទរបស់មន្ត្រីអត្រានុកូលដ្ឋានមួយចំនួន គឺទំនាក់ទំនងរវាងមន្ត្រី និងប្រជាពលរដ្ឋ ដូចជាមិនសូវមានភាពស្និទ្ធស្នាល ឬទន់ភ្លន់ចំពោះប្រជាពលរដ្ឋនោះទេ ព្រមទាំងមិនយកចិត្តទុកដាក់នឹងការងារថែមទៀតផង។ ទោះបីជាពេលវេលាកំណត់ជាក់លាក់សម្រាប់ការរាយការណ៍ពីថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក រាជធានី ខេត្ត យ៉ាងណាក៏ដោយ ក៏ការអនុវត្តពុំទាន់ម៉ត់ចត់ និងតឹងរឹងដែរ ហើយក្រសួងមហាផ្ទៃក៏មិនបានទទួលរបាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានពីគ្រប់រាជធានី ខេត្តទាំងអស់ទាន់ពេលវេលាដែរ។ យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងាររបស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្នុងឆ្នាំ

២០២០កន្លងមក ឃើញថាបញ្ហាប្រឈមរបស់មន្ត្រីបម្រើការងារនៅនាយកដ្ឋានអត្រានុកូលដ្ឋាននៅមានចំនួនតិចនៅឡើយ ដោយសារកត្តានេះទើបធ្វើឲ្យកិច្ចការមួយចំនួនមានការយឺតយ៉ាវម្យ៉ាងវិញទៀតមន្ត្រីដែលអនុវត្តការងារអត្រានុកូលដ្ឋាននៅតាមតំបន់នីមួយៗ ក្នុងប្រទេស មានការផ្លាស់ប្តូរញឹកញាប់ នេះហើយជាមូលហេតុធ្វើឲ្យមានការខុសឆ្គងពេលចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋមិនល្អប្រសើរឡើយ។ ឧទាហ៍រណ៍ កាលពីឆ្នាំ ២០០២-២០០៦ កន្លងមកក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃបានលើកឡើងថា ប្រជាពលរដ្ឋខ្មែរយ៉ាងតិច៣៥ភាគរយ ប្រហែលជាង២លាននាក់ បានជួបប្រទះបញ្ហាខុសឈ្មោះ និងអាយុនៅក្នុងអត្រានុកូលដ្ឋានរបស់ពួកគេ ហើយកត្តានេះបានធ្វើឲ្យពួកគេជួបប្រទះការលំបាកក្នុងការធ្វើអ្វីមួយតាមរដ្ឋបាល និងបញ្ហាផ្សេងៗទៀត។ ប៉ុន្តែបញ្ហាទាំងនេះ ធ្វើឲ្យក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំការកែតម្រូវ និងធ្វើការមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន តាំងពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៩ ក៏បានចេញសេចក្តីណែនាំនេះបន្តអនុវត្តរហូតមកដល់បច្ចុប្បន្ន។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ កន្លងមកនេះ ក្រសួងមហាផ្ទៃបានរៀបចំដឹកនាំកិច្ចប្រជុំលើកទី៥ នៃគណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (គ.ជ.ដ.អ) នៅទីស្តីការក្រសួងមហាផ្ទៃដោយមានវត្តមាន សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា សម្តេចបានបង្ហាញការកត់សម្គាល់ថានៅឆ្នាំ២០២០កន្លងទៅ នៅប្រទេសជាច្រើនទៀតនៅលើសាកលលោក និងកម្ពុជាបានជួបបញ្ហាអំពីជំងឺកូវីដ-១៩ (Covid19)បានធ្វើឲ្យរងការប៉ះពាល់ដល់ការអនុវត្តគោលដៅយុទ្ធសាស្ត្រនីមួយៗ នៃផែនការថ្នាក់ជាតិស្តីពីអត្តសញ្ញាណកម្ម ក៏រងផលប៉ះពាល់ផងដែរ។

បញ្ហាលើប្រជាពលរដ្ឋ យើងបានសង្កេតឃើញថា ការយល់ដឹងប្រជាពលរដ្ឋនៅមានកំរិត និងភាពខ្វះខាតនូវទំទាក់ទំនងទៅនិងសិទ្ធិ និងកាតព្វកិច្ច ពួកគាត់គិតថា ការចុះបញ្ជីអត្រានុកូលដ្ឋានមិនមានប្រយោជន៍សម្រាប់ពួកគាត់ កត្តាទាំងនេះ ដោយសារមិនសូវយកចិត្តទុកដាក់ក្នុងការស្វែងយល់កាន់តែច្បាស់លាស់ មកពីគ្មានការយល់ដឹង ឬខ្វះអ្នកជួយពន្យល់បន្ថែម អំពីនីតិវិធីនៃការចុះបញ្ជី ឬ ខ្វះខាតឯកសារភ្ជាប់មួយចំនួននៅពេលដែលពួកគាត់មកចុះសំបុត្រអត្រានុកូលដ្ឋានទាំង៣នេះ។ គឺមកពីការមមារញឹកក្នុងការងារប្រចាំថ្ងៃក្នុងគ្រួសារ ហេតុដូច្នេះហើយ ទើបធ្វើឲ្យពួកគាត់មានការធ្វេសប្រហែសមិនបានចុះសំបុត្រអត្រានុកូលដ្ឋានទាន់ពេលវេលា។

៣.២.២.ដំណោះស្រាយចំពោះបញ្ហា

ដើម្បីដោះស្រាយបញ្ហាទាំងនេះបាន ឬធ្វើអោយប្រសើរឡើងបន្ថែមទៀតនោះ គឺជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល តម្រូវឲ្យមានការកសាងសមត្ថភាពដល់មន្ត្រីនៅ

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងការពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយ រួចហើយយកមកវាយតម្លៃបានបង្កើតឲ្យមានភស្តុតាងជាមូលដ្ឋានចាំបាច់ សម្រាប់ធ្វើការអភិវឌ្ឍន៍ផែនការធ្វើឲ្យប្រសើរឡើងដែលអាចទុកចិត្តបានក្នុងការអនុវត្តកិច្ចការនេះ។ ទស្សនវិស័យមួយចំនួន នៃដំណើរការចុះបញ្ជីអត្រានុកូលដ្ឋានបច្ចុប្បន្ននេះ តម្រូវឲ្យមានការផ្លាស់ប្តូរ ដោយសារក្រមរដ្ឋប្បវេណីថ្មី ច្បាប់ស្តីពីអត្រានុកូលដ្ឋានថ្មី គឺកំពុងស្ថិតក្នុងសេចក្តីព្រាងនៅឡើយ ដែលនឹងរួមបញ្ចូលទាំងដំណើរការ ការរៀបចំអត្តសញ្ញាណ រួមមានលិខិតឆ្លងដែន សៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណផងដែរ។

ចំណុចមួយចំនួនសម្រាប់យកទៅដោះស្រាយមានដូចខាងក្រោម៖

១.បង្កើតគណៈកម្មាធិការជាតិស្តីពីការគ្រប់គ្រងប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ដែលមានសមាសភាពមកពីតំណាងនៃក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ។

២.វិសោធនកម្មក្របខណ្ឌច្បាប់ ដើម្បីទទួលស្គាល់មុខងារស្ថិតិអត្រានុកូលដ្ឋាន នៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងវិសោធនកម្មក្របខណ្ឌច្បាប់ ដោយផ្តល់តួនាទី និងការទទួលខុសត្រូវដល់មណ្ឌលសុខភាព ហើយជូនដំណឹងទៅការិយាល័យស្ថិតិអត្រានុកូលដ្ឋាន ពីកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។

៣.ការបែងចែក និងទុកពេលមួយថ្ងៃ ឬមួយសប្តាហ៍ ដើម្បីឲ្យមេឃុំ ចៅសង្កាត់ប្រចាំការនៅសាលាឃុំសង្កាត់ពេញមួយថ្ងៃ ក្នុងការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ។

៤.ជំហានអន្តរកាលនៃការប្តូរពីការប្រើប្រាស់ការសរសេរក្រដាសជាមូលដ្ឋាន ទៅជាការប្រើប្រព័ន្ធព័ត៌មានវិទ្យានៃអត្រានុកូលដ្ឋាន។

៥.បង្កើតឲ្យមានយន្តការត្រួតពិនិត្យ និងវាយតម្លៃឲ្យទៀងទាត់ ដោយផ្តល់ព័ត៌មានត្រលប់ទៅដល់ឃុំសង្កាត់ ដើម្បីលើកទឹកចិត្តក្នុងការរាយការណ៍ពីទិន្នន័យឲ្យបានពេញលេញ និងគាំទ្រដល់ទិន្នន័យដែលបានចុះបញ្ជីរួច។

សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវសារណា អំពីប្រធានបទ **អត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន** ខាងលើរួចមក យើងអាចសន្និដ្ឋានបានថា ការចុះបញ្ជីសៀវភៅអត្រានុកូលដ្ឋានពិតជាមានសារៈសំខាន់ណាស់ គឺជាសេវារដ្ឋបាលដែលប្រើប្រាស់ដើម្បីធ្វើការកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗ៣ជាគោលធំៗមានដូចជា៖ **កំណើត អាពាហ៍ពិពាហ៍ និងមរណភាព** សម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាប្រទេសនីមួយៗ ជាពិសេសប្រជាពលរដ្ឋដែលរស់ក្នុងប្រទេសកម្ពុជា ដើម្បីបញ្ជាក់ពីសញ្ជាតិរបស់ខ្លួន និងការផ្តល់សញ្ជាតិដល់ជនអន្តោប្រវេសន៍ដែលមករស់នៅក្នុងប្រទេសកម្ពុជា មួយផ្នែកទៀតដើម្បីងាយស្រួលអោយដឹងអំពីស្ថិតិអត្រានុកូលដ្ឋាន។ ការចុះបញ្ជីអត្រានុកូលដ្ឋានកំណើតដើម្បីបញ្ជាក់ពីសញ្ជាតិ ទីកន្លែងរស់នៅ និងអាណាព្យាបាលទារក អាពាហ៍ពិពាហ៍ដើម្បីចងភ្ជាប់បុគ្គលពីរនាក់ឲ្យមានការទទួលខុសត្រូវភាពជា មាតាបិតា និងករណីកិច្ចទៅវិញទៅមកចំពោះសហព័ទ្ធ ចំណែកមរណភាព គឺជាការប្រកាសនៃបុគ្គលភាពដែលបានស្លាប់ និងងាយស្រួលក្នុងការអនុវត្តច្បាប់នានា។ ហើយការសុំចុះសៀវភៅអត្រានុកូលដ្ឋាន គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប។ កិច្ចការនេះវាពិតជាជួយសម្រួលដល់ប្រជាពលរដ្ឋក្នុងការបំពេញកិច្ចរដ្ឋបាលផ្សេងៗ ដោយឡែកយើងសង្កេតឃើញថា ការចុះសៀវភៅអត្រានុកូលដ្ឋានសម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍មានភាពស្មុកស្មាញ និងបង្កលក្ខណៈពិបាកដល់មន្ត្រីអត្រានុកូលដ្ឋានដោយមានលក្ខខណ្ឌជាច្រើន មុននឹងបានចូលសញ្ជាតិជាពលរដ្ឋកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានបានបញ្ញត្តច្បាប់សម្រាប់ការពារមុនពេលមានករណីណាមួយដែលអាចនឹងកើតឡើងចំពោះជនណាម្នាក់ដែលលួចក្លែងបន្លំ និងងាយស្រួលដល់ការអនុវត្តច្បាប់ក្នុងស្ថានភាពចាំបាច់ណាមួយ។ ហើយការចុះសៀវភៅអត្រានុកូលដ្ឋាននេះមានផលប្រយោជន៍ជាច្រើនសម្រាប់តម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសកម្ពុជា។

ដោយឡែកនៅតាមតំបន់មួយចំនួនតូចប្រជាពលខ្លះមិនបានអោយតម្លៃទៅលើការចុះបញ្ជីអត្រានុកូលដ្ឋាននេះទេ ជាពិសេសពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាល។ បញ្ហាទាំងនេះបណ្តាលមកពីកត្តាការយល់ដឹង ការផ្សាយព័ត៌មានមិនបានទូលំទូលាយ ផ្នត់គំនិត និងជីវភាព។ កត្តាមួយទៀត បណ្តាលមកពីសមត្ថភាពមន្ត្រីអត្រានុកូលដ្ឋាន នឹងមិនបានយកចិត្តទុកដាក់ឃ្លាំមើលមន្ត្រីក្រោមឱវាទ ក្នុងការបំពេញការងារអោយបានគ្រប់ម៉ោង និងឥរិយាបថមន្ត្រីតាមមូលដ្ឋាន។

សេវាមួយនេះ គឺជាផ្នែកមួយនៃសេវាសាធារណៈ ដើម្បីបំរើប្រយោជន៍មហាជនទូទៅ ដែលមានវិសាលភាពទូលំទូលាយសម្រាប់សង្គមក្នុងការអភិវឌ្ឍន៍ដែលមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាលកម្ពុជា។

អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងឈ្វេងយល់ខ្លឹមសារប្រធានបទខាងលើរួចមក ក្រុមយើងខ្ញុំសូមធ្វើការផ្តល់នូវអនុសាសន៍ខ្លះៗ ដើម្បីជាគំនិតក្នុងការកែតម្រូវចំណុចមួយចំនួនដែលខ្វះខាតត្រូវបន្ថែមដូចខាងក្រោម៖

- ជួយពង្រឹងសមត្ថភាពមន្ត្រីអត្រានុកូលដ្ឋាន តាមតំបន់នីមួយៗ និងយកចិត្តទុកដាក់ដើម្បីបំពេញមុខងារ រៀងៗខ្លួនអោយបានច្បាស់លាស់។
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យរដ្ឋបាល ឃុំ សង្កាត់ដែលធ្វើការមិនបានពេញម៉ោងដែលក្រសួងបាន កំណត់ ។
- កំណត់កម្រិតចំណេះដឹង និងបទពិសោធន៍ ចំណេះដឹងបេក្ខជនដែលបានជាប់ឈ្មោះជាមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់។
- សម្របសម្រួលការងារចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីចាំបាច់ដែលប្រជាពលរដ្ឋត្រូវការ។
- ជួយពន្យល់ និងផ្សព្វផ្សាយបន្ថែមទៀត តាមគ្រប់រូបភាព (វិទ្យុ ទូរទស្ស ខិតប័ណ្ណព័ត៌មាន...)។
- សំរួលដល់សង្គមស៊ីវិលក្នុងការធ្វើសកម្មភាពជួយពន្យល់អំពីសារៈប្រយោជន៍នៃអត្រានុកូលដ្ឋានដល់ ប្រជាពលរដ្ឋ។
- ជួយបណ្តុះបណ្តាលបន្ថែមដល់មន្ត្រី និងអាជ្ញាធរមានសមត្ថកិច្ចចំពោះអត្រានុកូលដ្ឋាន។
- ជួយសម្រួលដល់ប្រជាពលរដ្ឋណាដែលខុសឈ្មោះ ឬថ្ងៃ ខែ ឆ្នាំកំណើត។
- យកចិត្តទុកដាក់ខ្ពស់ក្នុងការចុះបញ្ជីស្ថិតិអត្រានុកូលដ្ឋាន ជនបរទេស និងជនអន្តោរប្រវេសន៍ដែលឆ្លង ដែនខុសច្បាប់ចូលមកប្រទេសកម្ពុជា។

ឯកសារយោង

❖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ ៥៦ ក្រ ចុះថ្ងៃទី២៦ខែកក្កដា ឆ្នាំ១៩៨៩
- ច្បាប់ ស្តីពីសញ្ជាតិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨
- អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០
- អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការកែសំរួលមាត្រា៨ និងមាត្រា ២៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អនុក្រឹត្យអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការកំណត់ថ្លៃជាវក្រដាស អត្រានុកូលដ្ឋាន និងថ្លៃតែមប្រ៊ីសារពើពន្ធ
- អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ការកែសម្រួលអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ស្ងួនថ្មីនៃ អនុក្រឹត្យលេខ១៧ អនក្រ.បក
- អនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលចំណុច "ក"និង "ខ" មាត្រា ៥៩ថ្មីស្ងួននៃ អនក្រ.បក លេខ១០៦
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពី ការកែសំរួលមាត្រា៩ និងមាត្រា ៥២ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អនុក្រឹត្យអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃ រៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សេចក្តីណែនាំអន្តរក្រសួងលេខ០១០ សណន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការកែតម្រូវ និង បំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ
- សេចក្តីណែនាំលេខ០០៨ សណន ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅ អត្រានុកូលដ្ឋាន ឲ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត
- សេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់អនុក្រឹត្យស្តីពីការ កំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- សេចក្តីណែនាំលេខ០១៥ សណន ចុះថ្ងៃ សណន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការចេញលិខិតរដ្ឋបាល និង លិខិតអត្រានុកូលដ្ឋានឲ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍
- សេចក្តីណែនាំលេខ០៣៥ សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការកែតម្រូវ និងការធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន
- សេចក្តីណែនាំលេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៩ ស្តីពីការបន្តដំណើរកែតម្រូវ និងធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន
- ប្រកាសលេខ១០៨៦ ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះការិយាល័យកិច្ចការទូទៅ ជាការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋានចំណុះ សាលាខេត្ត ក្រុង។

❖ **សៀវភៅ និង ឯកសារចងក្រងផ្សេងៗ**

- កម្រងឯកសារស្តីពី របៀបកត់ត្រាការងាររអត្រានុកូលដ្ឋាន (ដោយ៖ នាយកដ្ឋានអត្រានុកូលដ្ឋាន ឆ្នាំ ២០១៥)
- ការវាយតម្លៃលើគុណភាព និងការប្រើប្រាស់ព័ត៌មាន កំណើត មរណភាព និងមូលហេតុនៃការស្លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖
ច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
ច្បាប់ ស្តីពីសញ្ជាតិ

ផ្នែកទី ៣

អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

មាត្រា ២១- អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះ ចុះបញ្ជីនៅពេលដែលសហព័ន្ធណាម្នាក់ឆ្កួត ឬ មិនដឹងខុសត្រូវ ។ តែបើសហព័ន្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំឱ្យទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

មាត្រា ២២- អាពាហ៍ពិពាហ៍រវាងបុរសអាយុគិចជាង ២០ ឆ្នាំ ឬ នារីអាយុគិចជាង ១៨ ឆ្នាំ ត្រូវទុកជាមោឃៈ ។

អាពាហ៍ពិពាហ៍ដែលទុកជាមោឃៈនោះនឹងពែងមោឃៈមៅវិញ កាលបើប្តី ឬ ប្រពន្ធ នោះចំរើនវ័យ ដល់អាយុតាម បញ្ញត្តិច្បាប់ ឬ ក្នុងករណីដែលមានចែងក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ២ ។

មាត្រា ២៣- អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ កាលបើសហព័ន្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវគេចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្តឹងនោះ មិនធ្វើក្នុង រយៈ ៦ ខែ គិតពីថ្ងៃដែលគេលែងបង្ខំមក ។

មាត្រា ២៤- អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំពោះអាពាហ៍ពិពាហ៍មុនរបស់សហព័ន្ធណាម្នាក់មិនទាន់រលាយ ។

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ក្រោយ មិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃមុនអាពាហ៍ពិពាហ៍ក្រោយ នេះមក អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ។

មាត្រា ២៥- អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬ ញាតិព័ន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវទុកជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៨ វាក្យខ័ណ្ឌទី ២ ។

ការប្តឹងសុំមោឃភាព នៃអាពាហ៍ពិពាហ៍ខាងលើនេះ មិនអាចផុតអាជ្ញាយុកាលឡើយ ។

មាត្រា ២៦- មានតែសហព័ន្ធ រដ្ឋអាជ្ញា និង ជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ។

បើជនដែលបានដាក់ពាក្យប្តឹងនោះស្លាប់ សិទ្ធិវន្តអាចប្តឹងជំនួសបាន ។

មាត្រា ២៧-កូនកើតអំពីអាពាហ៍ពិពាហ៍ដែលតុលាការបានប្រកាសជាមោឃៈ ត្រូវទុកជាកូនមានខាន់ស្លោទោះបីហេតុដែលនាំឱ្យមានមោឃភាពនោះ យ៉ាងណាក៏ដោយ ។

សិទ្ធិ និង កាតព្វកិច្ចរបស់ឪពុក ម្តាយ និង កូនត្រូវមានដូចគ្នាក្នុងករណីនៃឪពុក ម្តាយលែងលះគ្នា ។

ការចែកទ្រព្យសម្បត្តិរវាង ប្តី ប្រពន្ធ នៃអាពាហ៍ពិពាហ៍ដែលតុលាការប្រកាសជាមោឃៈក៏ត្រូវធ្វើដូចក្នុងករណីលែងលះគ្នាដែរ ។

តារាងនៃថ្នាក់ញាតិភាព
(TABLEAU DES DEGRÉS DE LA PARENTÉ)

ខ្សែផ្ដាល់
(Ligne directe)
ខ្សែខាងឪពុក ខ្សែខាងម្ដាយ



សាខាញាតិ
(Ligne collatérale)



ចំពោះខ្សែផ្តាល់ ក៏ដូចជាសាខាញាតិ សុទ្ធតែមានញាតិលោហិត និង ញាតិពន្ធ ។

ញាតិលោហិត : ញាតិដែលមានឈាមជាមួយគ្នា ។

ញាតិពន្ធ : សាច់ថ្លៃ (បងថ្លៃ ប្អូនថ្លៃ ឪពុក-ម្តាយក្មេក និង កូនប្រសា ជីតា ជីដូនក្មេក និង ចៅប្រសា) ។

សាខាញាតិ : ញាតិដែលចែកចេញជា មែកធាងពីអ្នកបង្កើតរួមដូចជាមីងមា ក្មួយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ។

បងប្អូនបង្កើត : កូនដែលកើតពីឪពុក-ម្តាយជាមួយគ្នា គឺរួមឪពុក-ម្តាយ ឬ រួមតែឪពុក គឺឪពុកជាមួយគ្នា ម្តាយទីទៃ ឬ ក៏រួមតែម្តាយ គឺម្តាយជាមួយគ្នា ឪពុកទីទៃ ។

ជំពូកទី ៤

អំពីអាពាហ៍ពិពាហ៍នៅរាជរដ្ឋាភិបាលនៃ និង
អាពាហ៍ពិពាហ៍ជាមួយបរទេស

ផ្នែកទី ១
អំពីអាពាហ៍ពិពាហ៍

មាត្រា ៧៩. អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេសដែលរស់នៅឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃស្ថានទូត ឬ ស្ថានកុង ស៊ុល នៃរដ្ឋកម្ពុជាប្រចាំនៅប្រទេសដែលភាគីមានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា និង អាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទំរង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់ នៃកន្លែងរៀបអាពាហ៍ពាហ៍នោះ ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃរដ្ឋកម្ពុជា ។

លិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍នេះ ត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៃស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកម្ពុជា ឬគូស្វាមីភរិយាមកតាំងទីលំនៅនៅរដ្ឋកម្ពុជា ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៅឃុំ ឬ សង្កាត់ ដែលមកតាំងទីលំនៅនោះ ។

មាត្រា ៨០. អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ជនបរទេសនៅរដ្ឋកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃរដ្ឋកម្ពុជា ។

ផ្នែកទី ២

អំពីការរំលាយអាពាហ៍ពិពាហ៍

មាត្រា ៨១- ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់ឃកជាការ បាននៅរដ្ឋកម្ពុជា ។

- ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬ ការរំលាយ អាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជាត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា ។

- តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយ អាពាហ៍ពិពាហ៍ របស់សហព័ន្ធណាមួយដែលចូលមកតាំងទីលំនៅ។រដ្ឋកម្ពុជា ។

ជំពូកទី ៥

អំពីគ្រួសារ

ផ្នែកទី ១

អំពីកូនមានខាន់ស្លា

មាត្រា ៨២- កូន នឹងទុកជាកូនមានខាន់ស្លា លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀប អាពាហ៍ពិពាហ៍ជាមួយគ្នា និង លុះត្រាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេល ដែលឪពុក ម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថា កូនដែលកើត ១៨០ ថ្ងៃយ៉ាងតិច ក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល ៣០០ ថ្ងៃ គិតពីថ្ងៃដាច់ចំណង អាពាហ៍ពិពាហ៍ ។

មាត្រា ៨៣- កូនដែលកើតក្នុងរយៈវេលាតិចជាង ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងទុកថា កូន របស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ថា ប្តីនេះបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃ ពោះតាំងពីមុនរៀបអាពាហ៍ពិពាហ៍មកម្ល៉េះ ឬ ក៏ព្រមទទួលស្គាល់ថា ខ្លួនជាឪពុករបស់កូន នោះ ។ បើមិនដូច្នេះទេ ប្តីរបស់ម្តាយនៃកូននោះអាចបដិសេធថា ខ្លួនមិនមែនជាឪពុករបស់ កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថាខ្លួនមិនមែនជាឪពុក ។

មាត្រា ៨៤- កូនដែលកើតក្នុងល័ក្ខខ័ណ្ឌ នៃពេលដែលមានចែងក្នុងមាត្រា៨២ ជាភស្តុតាងយ៉ាងមាំ តម្រូវឱ្យ សន្មត់ថា ប្តីនៃម្តាយគឺពិតជាឪពុករបស់កូននោះ ។ ប្តីនៃម្តាយអាចមិនទទួលស្គាល់ថា កូននោះ ជាកូនរបស់ខ្លួនបាន លុះណាតែប្តីនោះប្តឹងបដិសេធបិតុភាព ។

មាត្រា ៨៥- ការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាព ត្រូវប្តឹងប្តឹងពីម្តាយ និង ពីកូន ចំពោះមុខតុលាការប្រជា ជនខាងលំនៅនៃម្តាយក្នុងរយៈពេល ២ ខែ គិតពីថ្ងៃដែលខ្លួនបានដឹងពីកំណើតនៃកូននោះ ។

ផ្នែកទី ២

អំពីការរំលាយអាពាហ៍ពិពាហ៍

មាត្រា ៨១- ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ។

- ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬ ការរំលាយអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជាត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា ។

- តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍ របស់សហព័ន្ធណាមួយដែលចូលមកតាំងទីលំនៅ។រដ្ឋកម្ពុជា ។

ជំពូកទី ៥

អំពីគ្រួសារ

ផ្នែកទី ១

អំពីកូនមានខាន់ស្លា

មាត្រា ៨២- កូន នីងទុកជាកូនមានខាន់ស្លា លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង លុះត្រាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេល ដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថា កូនដែលកើត ១៨០ ថ្ងៃយ៉ាងតិចក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល ៣០០ ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍ ។

មាត្រា ៨៣- កូនដែលកើតក្នុងរយៈវេលាតិចជាង ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងទុកថា កូនរបស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ថា ប្តីនេះបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនរៀបអាពាហ៍ពិពាហ៍មកម្ល៉េះ ឬ ក៏ព្រមទទួលស្គាល់ថា ខ្លួនជាឪពុករបស់កូននោះ ។ បើមិនដូច្នេះទេ ប្តីរបស់ម្តាយនៃកូននោះអាចបដិសេធថា ខ្លួនមិនមែនជាឪពុករបស់កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថាខ្លួនមិនមែនជាឪពុក ។

មាត្រា ៨៤- កូនដែលកើតក្នុងល័ក្ខខ័ណ្ឌ នៃពេលដែលមានចែងក្នុងមាត្រា៨២ ជាភស្តុតាងយ៉ាងមាំ តម្រូវឱ្យសន្មត់ថា ប្តីនៃម្តាយគឺពិតជាឪពុករបស់កូននោះ ។ ប្តីនៃម្តាយអាចមិនទទួលស្គាល់ថា កូននោះជាកូនរបស់ខ្លួនបាន លុះណាតែប្តីនោះប្តឹងបដិសេធបិតុភាព ។

មាត្រា ៨៥- ការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាព ត្រូវប្តឹងប្តឹងពីម្តាយ និង ពីកូន ចំពោះមុខតុលាការប្រជាជនខាងលំនៅនៃម្តាយក្នុងរយៈពេល ២ ខែ គិតពីថ្ងៃដែលខ្លួនបានដឹងពីកំណើតនៃកូននោះ ។

មាត្រា ៨៦- ប្តីត្រូវជូនភស្តុតាងថា កាលប្រពន្ធខ្លួនមានគភ៌ ក្នុងរយៈពេលដែលច្បាប់បានកំណត់នោះ ខ្លួនមានវិបត្តិខាងរូបកាយ មិនអាចរួមដំណេកជាមួយម្តាយនៃកូននោះបានទេ ។ វិបត្តិខាងរូបកាយដែលពុំអាចឱ្យរួមដំណេកបាននោះ អាចកើតមកពីហេតុ ២ យ៉ាង :

១- ប្តីប្រពន្ធរស់នៅដាច់ឆ្ងាយពីគ្នា

២- ប្តីគ្មានពលានុភាពបណ្តាលមកពីកាយវិកលកម្ម ដែលមិនអាចឱ្យបន្តពូជបាន ។

មាត្រា ៨៧- ទាយាទខាងប្តី អាចនឹងប្តឹងបដិសេធកូននោះជួសបាន ក្នុងរយៈពេលដែលមានចែងក្នុងមាត្រា ៨៥ ប្រសិនបើប្តីនោះមិនអាចប្តឹងបាន ដោយប្តីនោះស្លាប់បាត់ខ្លួន ឬ ក៏ឆ្កួតលេលា ។

ទាយាទខាងប្តីអាចនឹងបន្តការប្តឹងបដិសេធកូននោះបាន ប្រសិនបើក្នុងរយៈពេល ដែលមានចែងក្នុងមាត្រា ៨៥ ក្តីនោះបានប្តឹងបដិសេធរួចហើយ ហើយស្លាប់បាត់ខ្លួន ឬ ក៏ឆ្កួតលេលា ។

មាត្រា ៨៨- សាលក្រមដែលសំរេចទទួលបណ្តឹងបដិសេធនោះ ទុកជាត្រឹមត្រូវ ត្រូវបង្គាប់អោយលុបឈ្មោះប្តីនោះ ចេញពីបញ្ជីសំបុត្រកំណើតរបស់កូន ហើយឱ្យដកត្រកូលឪពុកចេញពីកូន ដោយយកត្រកូលម្តាយដាក់ជំនួសវិញ ។

មាត្រា ៨៩- ត្រូវបញ្ជូនសេចក្តីសំរេចនៃសាលក្រមទៅឱ្យមន្ត្រីអត្រានុកូលដ្ឋានដែលបានធ្វើសំបុត្រកំណើតរបស់ កូននោះ ដើម្បីឱ្យចម្លងដាក់ក្នុង បញ្ជីសំបុត្រកំណើតហើយចុះនិទ្ទេសនៅរឹមទំព័រ នៃសំបុត្រ កំណើតដែលត្រូវកែនោះ ។

ផ្នែកទី ២

អំពីកូនឥតខាន់ស្លា

មាត្រា ៩០- ដែលហៅថា កូនឥតខាន់ស្លា គឺកូនដែលកើតពីឪពុកម្តាយគ្មានចំណងដៃអាពាហ៍ពិពាហ៍ ។

មាត្រា ៩១- នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយ ដែលគ្មានចំណងដៃអាពាហ៍ពិពាហ៍ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា កូនដែលកើតមកនោះជាកូនរបស់ខ្លួន នោះត្រូវចាត់ទុកឪពុកម្តាយនេះថា ឪពុកម្តាយរបស់កូននោះ ។

មាត្រា ៩២- បើមានតែឪពុក ឬ មានតែម្តាយ ឆ្លើយទទួលស្គាល់ម្នាក់ឯងទេ កូននោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានឆ្លើយទទួលស្គាល់តែម្នាក់ប៉ុណ្ណោះ ។

មាត្រា ៩៣- ក្រោយពេលដែលឪពុក ឬ ម្តាយបានប្តឹងចុះកំណើតកូន ឪពុក ឬ ម្តាយណាដែលមិនទាន់ទទួលស្គាល់ឪពុក ឬម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

មាត្រា ៩៤- កូនឥតខាន់ស្លាដែលឪពុកម្តាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន បើក្រោយពីកំណើតរបស់កូននោះ ឪពុកម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

ផ្នែកទី ៣
អំពីការស្វែងរកបិតុភាព ឬ មាតុភាព
នៃកូនឥតខាន់ស្លា

មាត្រា ៩៥- បើគ្មានលិខិតធ្វើទទួលស្គាល់ ដោយស្ម័គ្រចិត្តនូវកូនឥតខាន់ស្លាទេ នោះតុលាការប្រជាជនអាចតម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់កូននោះបាន ។

មាត្រា ៩៦- កូនឥតខាន់ស្លាដែលឪពុក ឬ ម្តាយមិនបានទទួលស្គាល់ មានសិទ្ធិប្តឹងសុំឱ្យតុលាការប្រជាជនរកឪពុក ឬ រកម្តាយឱ្យខ្លួនបាន ។

មាត្រា ៩៧- បណ្តឹងសុំឱ្យតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់នោះ អាចធ្វើឡើងក្នុងរយៈពេល ២ ឆ្នាំ គិតពីថ្ងៃដែលកូននោះមានអនីតិភាព ។

អនីតិភាពត្រូវកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ ។

ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ អ្នកអាណាព្យាបាលរបស់កូននោះមានសិទ្ធិប្តឹងជួស សុំឱ្យតុលាការប្រជាជន រកមាតុភាពឱ្យកូននោះ ។

មាត្រា ៩៨- តុលាការប្រជាជន អាចតម្រូវឱ្យនារីជាម្តាយទទួលស្គាល់កូនឥតខាន់ស្លាបាន បើមានភស្តុតាងបញ្ជាក់ថា :

ក- នារីនោះបានបង្កើតកូនប្រាកដមែន

ខ- អត្តសញ្ញាណរបស់កូនដែលនារីនោះបានបង្កើត និង អត្តសញ្ញាណរបស់កូន ដែលប្តឹងទាមទាររកមាតុភាព នោះមិនខុសប្លែកពីគ្នា ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

មាត្រា ៩៩- តុលាការប្រជាជន អាចតំរូវឱ្យបុរសជាឪពុកទទួលស្គាល់កូនឥតខាន់ស្លាបាន :

១-បើបុរសនោះបានធ្វើពង្រត់ ឬ បានចាប់រំលោភសន្តវៈនារីជាម្តាយដោយរំលោភ ហើយបើសម័យធ្វើពង្រត់ ឬ ចាប់រំលោភសពសន្តវៈនោះ ត្រូវគ្នានឹងសម័យដែលនារីនោះមានគភ៌ ។

- កូនដែលឪពុកម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ។

២- ត្រូវបានសញ្ជាតិខ្មែរ ដោយកើតក្នុងព្រះរាជាណាចក្រកម្ពុជា ៖

- កូនដែលកើតពីឪពុកនិងម្តាយជាជនបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

- កូនដែលកើតពីឪពុកម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

ផ្នែកទី ២
សញ្ជាតិខ្មែរដោយការស៊ុំកូនពេញលេញ

មាត្រា១០ .-

កូនជនបរទេសដែលត្រូវបានសុំជាកូនស៊ុំពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលស៊ុំកូនពេញលេញត្រូវបានបង្កើតឡើងស្របតាមច្បាប់ជាធរមាន ។

ជំពូកទី ៥
សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

មាត្រា១១ .-

ស្ត្រី ឬបុរសបរទេសដែលយកប្តី ឬប្រពន្ធពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ (ដប់ពីរ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ត្រូវបានអនុញ្ញាតឱ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន ។

មាត្រា១២ .-

ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ។

៤- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ។

៥- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

មាត្រា១៣ .-

ជនបរទេសដែលសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍អាចសុំប្តូរឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះ ត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំទាមទារសញ្ជាតិខ្មែររបស់ខ្លួន ។

មាត្រា១៤ .-

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចបដិសេធការទាមទារសញ្ជាតិខ្មែរ សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ា ។

មាត្រា១៥ .-

បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ព្រមទាំងនីតិវិធីនៃការប្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

មាត្រា១៦ .-

ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា១៧ .-

ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសទេ ។

ជំពូកទី ៦
សញ្ជាតូបនីយកម្ម

មាត្រា១៨ .-

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។

សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលតាមអំណាចឆន្ទានុសិទ្ធិ ។

មាត្រា១៩ .-

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដោយគិតរហូតដល់ពេលបានទទួលបណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះ

ជនបរទេសអន្តោប្រវេសន្ត ។

៤- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងមាត្រា២១ និងមាត្រា២២ នៃច្បាប់នេះ ។

៥- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញកស្តែងថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់និងប្រពៃណីល្អរបស់ខ្មែរ ។

៦- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

មាត្រា២០ .-

ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដូចមានចែងក្នុងចំណុចទី៣ មាត្រា១៩ នៃច្បាប់នេះ ត្រូវបន្តយមកនៅ ៣(បី)ឆ្នាំវិញ ។

មាត្រា២១ .-

ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់ ពីស្ថាប័នមានសមត្ថកិច្ច ហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចជាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីជនបរទេសនោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ ទី៥ និងទី៦ មាត្រា១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ១២ (ដប់ពីរ) ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំនួនទឹកប្រាក់ វិស័យអាទិភាព និងប្រភេទគម្រោងវិនិយោគ ព្រមទាំងលក្ខខណ្ឌផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា២២ .-

ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចជាក់ពាក្យសុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ និងទី៦ មាត្រា១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ៦ (ប្រាំមួយ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ ឬវិស័យមនុស្សធម៌ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា២៣ .-

ជនបរទេសដែលបានបង្ហាញនូវកេស្តតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចជាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៦ មាត្រា១៩ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា២៤ .-

ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន ដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ ។

មាត្រា២៥ .-

ជនបរទេសអាចសុំប្តូរឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំសញ្ជាតូបនីយកម្មរបស់ខ្លួន ។

មាត្រា២៦ .-

បែបបទ និងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

មាត្រា២៧ .-

ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៧
ការបាត់សញ្ជាតិខ្មែរ

មាត្រា២៨ .-

ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ យ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតនិងដោយគ្មានការបង្ខិតបង្ខំ ។

ត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ពលរដ្ឋខ្មែរជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន ។

មាត្រា២៩ .-

បែបបទ និងនីតិវិធីនៃការសុំលះបង់សញ្ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី២ ៖
អនុក្រឹត្យស្តីពី អត្រាឧកូលដ្ឋាន និងគំរូលិខិត អត្រាឧកូលដ្ឋាន កំណើត អពាហ៍ពិពាហ៍ មរណភាព

មាត្រា ៤ .- ឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

អនុក្រឹត្យលេខ ១០៣ អនក្រ.បក
ស្តីពីអត្រានុកូលដ្ឋាន

***

រដ្ឋធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៥ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ អេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងយុត្តិធម៌
- តាមការឯកភាពរបស់ពេញអង្គមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

សំរេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ .- អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និង និតិវិធី នៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .- អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និង ដែលបង្កើតអោយជននោះមានសិទ្ធិ និងកាតព្វកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់ធានាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និង ជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែលសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍និងសំបុត្រមរណភាព។

មាត្រា ៣ .- ការសុំចុះអត្រានុកូលដ្ឋានក្នុងស្បៀវភៅអត្រានុកូលដ្ឋានជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ គ្រប់រូប ។

មាត្រា ៤ .- រាល់ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នករាយការណ៍ និង ឬ សាក្សី និង ឬ សាមីខ្លួនត្រូវទៅផ្តាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះស្បៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និង សាក្សី ត្រូវទៅផ្តាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា ៥ .- ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តរោយឯកភាពគ្នាទូទាំងប្រទេស ។ គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ១៦ .-

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានអោយបានឯកភាពទូទាំងប្រទេស និង រណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទនីមួយៗ និង ធានាផ្គត់ផ្គង់សៀវភៅ និង សំបុត្រអត្រានុកូលដ្ឋានអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

ជំពូកទី ៤
អំពីសំបុត្រកំណើត

មាត្រា ១៧ .-

បើមានទារកកើត ឪពុក ឬ ម្តាយ មានភាពពូកិច្ចត្រូវទៅរាយការណ៍ ចុះស៊ៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានរមិទន្លែយ៍របស់ឪពុកម្តាយទារកនោះ មិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុកនិងម្តាយនៃទារកនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតអោយទៅចុះស៊ៀវភៅកំណើតអោយបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

មាត្រា ១៨ .-

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីជូនពាយួរលង់មក ហើយ ឬ អាចយកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្តាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនអោយទារក ។

មាត្រា ១៩ .-

បើមានជនណាពីសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់អោយមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬ សង្កាត់នៃទីកន្លែងដែលពីសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់អោយ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលពីសបាននោះ ដោយស្មាន និង ឈ្មោះឪពុកម្តាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលពីសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាស៊ុំទារកដែលជីសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអង្គភាពត្រូវបញ្ជូនទារកដែលជីសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និង កំណត់ហេតុស្តីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។

មាត្រា ២០ .-

ចំពោះទារក ឬ កុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្តីរាយការណ៍ និង នាំទារក ឬ កុមារនោះទៅជូនមន្ត្រីអង្គភាពនៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រីអង្គភាពផ្តល់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអោយ ។

មាត្រា ២១ .-

ការស៊ុំទារក ឬ កុមារ ពីជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការស៊ុំទារកដែលជីសបាន និងការស៊ុំទារក ឬ កូនពីឪពុក ម្តាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ជួបមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាស៊ុំកូនខាងលើនេះ ត្រូវចុះក្នុងស្បៀវភៅអង្គភាព ។

មាត្រា ២២ .-

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្តាយ ឬ ឪពុក ។

មាត្រា ២៣ .-

ទារកកើត ឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងស្បៀវភៅកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខមន្ត្រីអង្គភាពថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអង្គភាពត្រូវចាត់ទុកឪពុក ម្តាយនោះថាជាឪពុក ម្តាយរបស់កូននោះ ។

ករណីមានតែឪពុក ឬ មានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬ ម្តាយបានប្តឹងចុះក្នុងស្បៀវភៅកំណើត ឪពុកឬ ម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់ នឹង ទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា នឹង ពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

មាត្រា ២៤ .-

ក្រោយពេលចុះស្បៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់អោយអ្នកពាក់ព័ន្ធនូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ២៥ .-

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ ចុះស្បៀវភៅកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវទៅសុំសំណល់ក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលទារកនោះ ត្រូវយកសំណល់ក្រមតុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីចុះស្បៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ។

មាត្រា ២៦ .-

ទារកកើតពីឪពុក ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្រុកច្បាប់ឯបរទេស ឬ ពីឪពុកជាពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះ អាចសុំចុះ ស្បៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះស្បៀវភៅកំណើតនៅឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញអោយ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតចាស់មកប្តូរការនោះទុក ហើយចម្លងចេញពីស្បៀវភៅ នូវសំបុត្រកំណើតថ្មីអោយយកទៅប្រើប្រាស់ ។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះស្បៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់អោយនោះមកពីប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ២៧ .-

ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះ

សៀវភៅកំណើតនៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនស៊ាំនៅជាប់ជាប់ ឬ អាចហៅចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និង នាមផ្ទាល់ខ្លួន និងនាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ៥
អំពីសំបុត្រអាពាហ៍ពិពាហ៍

មាត្រា ២៨ .-

បុរស នារី នៃលុមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យអោយបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីការអាពាហ៍ពិពាហ៍ និង ត្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៩ .-

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលត្រូវនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់ នៃសាមីខ្លួនខាងនារី ០១ ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សង្កាត់នៃសាមីខ្លួនបុរស ០១ ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ ៖

១-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្តី ប្រពន្ធ ។

២-នាមត្រកូល មានខ្លួន អាយុ មុខរបរ និង លំនៅរបស់ ឪពុក ម្តាយ នៃអនាគត ប្តី ប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ ។

៣-រយៈពេលប្តឹងជំទាស់

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ អុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីផ្តល់ឱកាសមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍

[illegible] លុះត្រាតែមានភ្ជាប់នូវឯកសារដែលបញ្ជាក់ពីមានប្រកាសអាពាហ៍ពិពាហ៍ពិតប្រាកដ លុះត្រាតែមានភ្ជាប់នូវឯកសារបញ្ជាក់ថាមានសាក្សីចូលរួមចុះហត្ថលេខាយ៉ាងតិច ២នាក់ ។

មាត្រា ៣០ .-

អាពាហ៍ពិពាហ៍ នឹងគ្មានផលត្រឹមត្រូវតាមច្បាប់ឡើយ លុះត្រាតែបុរស និងនារីពេញសុទ្ធចិត្តទទួលគ្នាជា ប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងស្បៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតអេដែ ប្តី ប្រពន្ធ និង សាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

មាត្រា ៣១ .-

ពេលសាមីខ្លួនជាអនាថជន ប្តី និង ប្រពន្ធ អាចសុំការណ៍សុំចុះស្បៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលត្រូវចុះស្បៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួន ប្តីប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ៣២ .-

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង ជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តិទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូអាពាហ៍មានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តិទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់របៀបការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងស្បៀវភៅអាពាហ៍ពិពាហ៍ នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេស នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬ បើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះ ស្បៀវភៅអាពាហ៍ពិពាហ៍ នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ឬ មន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ចម្លងផ្លូវការនោះទុកហើយចម្លងចេញពីស្បៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី អោយទៅជននោះយកទៅប្រើប្រាស់ ។

មាត្រា ៣៣ .-

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣៤ .-

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអន្តរាគមន៍ក្លួនដ្ឋាន ដោយគ្រាប់ពីទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះ អោយបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះស្នៀវរៀអាពាហ៍ពិពាហ៍នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះស្នៀវរៀអាពាហ៍ពិពាហ៍ នៅមន្ត្រីអន្តរាគមន៍ក្លួនដ្ឋានតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង រួមជាមួយអក្សរខ្មែរផង ។

ជំពូកទី៦
អំពីសំបុត្រមរណភាព

មាត្រា ៣៥ .-

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអន្តរាគមន៍ក្លួនដ្ឋានសាលាឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

មន្ត្រីអន្តរាគមន៍ក្លួនដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬ ដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះស្នៀវរៀមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ ថ្ងៃ គ្រាយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលអោយគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬ ផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬ ផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអន្តរាគមន៍ក្លួនដ្ឋានត្រូវធ្វើលិខិតឯនុញ្ញាអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពតាមការសម្រេចនោះ ។

មាត្រា ៣៣ .-

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣៤ .-

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន ដោយគ្រាប់ពីទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះ អោយបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះស្បៀវភៅអាពាហ៍ពិពាហ៍នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះស្បៀវភៅអាពាហ៍ពិពាហ៍ នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង រួមជាមួយអក្សរខ្មែរផង ។

ជំពូកទី៦
អំពីសំបុត្រមរណភាព

មាត្រា ៣៥ .-

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់ឈាប់របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬ ដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្ម នៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះស្បៀវភៅមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលអោយគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬ ផ្នែកអនាម័យភូមិ ។ បើពេទ្យ ឬ ផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតឯនុញ្ញាអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពតាមការសម្រេចនោះ ។

មាត្រា ៣៦ .-

បើមានអ្នកស្លាប់ដោយអូសហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យដល់អំពើឃាតកម្ម នៃបទឧប្បត្តិហេតុក្រិដ្ឋ មន្ត្រីអង្គរក្សលដ្ឋាន ឬ ជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាម ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីអោយសមត្ថកិច្ចជំនាញនានាពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាងណាពិភាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអង្គរក្សលដ្ឋានអនុញ្ញាតអោយធ្វើបុណ្យបូជា ឬ បញ្ចុះសពបាន ។

មាត្រា ៣៧ .-

បើមានពលរដ្ឋខ្មែរស់នៅក្នុងឃុំ ឬ សង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬ សង្កាត់ផ្សេង មន្ត្រីអង្គរក្សលដ្ឋាននៃឃុំ ឬ សង្កាត់ ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអង្គរក្សលដ្ឋាននៃឃុំ ឬ សង្កាត់របស់អ្នកស្លាប់រស់នៅ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់អោយទៅយកសពធ្វើបុណ្យ និង ចុះស្បៀវភៅមរណភាពនៅឃុំ ឬ សង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬ គ្មានអ្នកសាច់ស្គាល់ទេ មន្ត្រីអង្គរក្សលដ្ឋាននៃឃុំ ឬ សង្កាត់ ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬ បញ្ចុះសពនោះ និង ចុះស្បៀវភៅមរណភាពក្នុងឃុំ ឬ សង្កាត់នោះ ។

មាត្រា ៣៨ .-

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអង្គរក្សលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះ ដើម្បីមន្ត្រីអង្គរក្សលដ្ឋានចុះក្នុងស្បៀវភៅមរណភាព ។

មាត្រា ៣៩ .-

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអង្គរក្សលដ្ឋានត្រូវចុះស្បៀវភៅមរណភាពរួចប្រគល់អោយអ្នកស៊ុំនូវសំបុត្រមរណភាពច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ៤០ .-

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះស្បៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រម

តុលាការនោះមកសុំមន្ត្រីអន្តរាគមន៍ភូលដ្ឋាន ឃុំ ឬ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះស្បៀវភៅមរណភាព ។

មាត្រា ៤១ .-

ប៉ុន្តែបើមានពលរដ្ឋខ្មែរស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះស្បៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាព ដែលធ្វើនៅបរទេសនោះទៅចុះស្បៀវភៅនៅ ឃុំ ឬ សង្កាត់ ដែលគាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់ ឈាប់មុនចេញទៅបរទេស ។

មន្ត្រីអន្តរាគមន៍ភូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពចំតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីស្បៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់អោយគាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះស្បៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញ អាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ៤២ .-

ជនអន្តោប្រវេសន៍ និង ជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬ អ្នកទទួលខុសត្រូវ អាចទៅចុះស្បៀវភៅមរណភាពនៅសាលាឃុំ ឬ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់ឈាប់មុនពេលខ្លួនស្លាប់ ឬ អាចទៅចុះស្បៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនលើមាន ។

បើចុះស្បៀវភៅមរណភាពនៅឃុំ ឬ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងរួមជាមួយអក្សរខ្មែរផង ។

ជំពូកទី៧

អំពីសំបុត្របញ្ជាក់កំណើត

មាត្រា ៤៣ .-

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអន្តរាគមន៍ភូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះស្បៀវភៅបញ្ជាក់កំណើតបាន តាមគំរូណែនាំថ្មី

នៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីពិជននិងជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និង ធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើត នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលប្រេវត្យ ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារប្រេវត្យ ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំ កំណើត ដែលចុះនៅក្នុងស្បៀវភៅបញ្ជាក់កំណើតមិនត្រូវអោយខុសពីថ្ងៃខែកំណើត ដែលមាននៅក្នុងឯកសារប្រេវត្យ ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

មាត្រា ៤៤ .-

ពេលមានអ្នកមកសុំចុះស្បៀវភៅបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះស្បៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬ ក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

ជំពូកទី៨
អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

មាត្រា ៤៥ .-

ពលរដ្ឋខ្មែរដែលបានឆ្នាជាប្តី ឬ ប្រពន្ធពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះស្បៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់ បច្ចុប្បន្នដោយមានសាក្សីចំនួន ០២រូប ជានីពិជន និងជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះនិងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាអ្នកឆ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា ៤៦ .-

ពេលមានសាមីខ្លួនប្តី និង ប្រពន្ធមកសុំចុះស្បៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះស្បៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់ អាពាហ៍ពិពាហ៍ច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់អ្នកត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ។

ជំពូកទី៩

អំពីសំបុត្របញ្ជាក់មរណភាព

មាត្រា ៤៧ .-

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមានហើយ គ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះស្បៀវភៅបញ្ជាក់មរណភាព ជុំវិញនាំនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់ឈាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២ រូប ជានីតិជន និង ជាមនុស្សគួរអោយជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និង ធ្លាប់ រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា ៤៨ .-

ពេលមានអ្នកមកសុំចុះស្បៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះស្បៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់អោយអ្នកមកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និងចេញ សេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

ជំពូកទី១០

អំពីសេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋាន

មាត្រា ៤៩ .-

សេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និង សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នានឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីស្បៀវភៅអត្រានុកូលដ្ឋាន ។

មាត្រា ៥០ .-

បើមានអ្នកមកសុំចម្លង ឬ សុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬ សម្រង់ត្រូវស្រង់ចេញពីស្បៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រចេះ (១) ---- កណ្តាល ------ លេខ (៤)------ ២៥ ----------
ស្រុក ខ្សាច់ (២) ---- កណ្តាលស្ទឹង --- សៀវភៅកំណើតលេខ (៥)--០១/២០១២--
ឃុំ សង្កាត់ (៣) ---- គោកត្រប់ ----- ឆ្នាំ (៦)-------- ២០១២----------

សំបុត្រកំណើត

នាមត្រកូល (៧)		សម	ភេទ (៩)
នាមខ្លួនទារក (៨)		សិថ្ថី	ប្រុស
ជាអក្សរឡាតាំង (១០)	នាមត្រកូល	SAM	
	នាមខ្លួនទារក	SITHY	
សញ្ជាតិ (១១)		ខ្មែរ	
ថ្ងៃ ខែ ឆ្នាំកំណើត (១២)		ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២	
ទីកន្លែងកំណើត (១៣) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស		.... ភូមិគោកត្រឹង ឃុំគោកត្រប់ ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា	

ឪពុក ម្តាយទារក	ឪពុក	ម្តាយ
នាមត្រកូល និងនាមខ្លួន (១៤)	សម សោភ័ណ	គុណ រតនា
ជាអក្សរឡាតាំង (១៥)	SAM SORPHORN	KUN RATANA
សញ្ជាតិ (១៦)	ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (១៧)	ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥	ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០
ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស	...ភូមិព្រែកកែវ ឃុំកោះខែល ស្រុក ស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា...	...ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា...
ទីលំនៅពេលទារកកើត (១៩)	.....ភូមិគោកត្រឹង ឃុំគោកត្រប់ ស្រុកកណ្តាល ស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា	

(២០) ធ្វើនៅ.... គោកត្រប់ ..... ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២

(២១) មន្ត្រីអត្រានុកូលដ្ឋាន
មេឃុំ

(២២) ហត្ថលេខា និងត្រា
ម្រី ហៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង (១) ---- *កណ្តាល* ------
ស្រុក ខណ្ឌ (២) ---- *កណ្តាលស្ទឹង* ---
ឃុំ សង្កាត់ (៣) ---- *គោកត្រប់* -----

សេចក្តីចម្លងសំបុត្រកំណើត

ចម្លងសំបុត្រកំណើតចេញពី		(៤) សៀវភៅកំណើត លេខ ៖ *០១/២០១២*	(៥) សំបុត្រកំណើត លេខ *២៥* ចុះថ្ងៃទី*១២* ខែមករា ឆ្នាំ*២០១២*	
នាមត្រកូល (៦)		*សម*		ភេទ (៨) *ប្រុស*
នាមខ្លួនទារក (៧)		*សិថ្ថី*		
ជាអក្សរឡាតាំង (៩)	នាមត្រកូល	*SAM*		
	នាមខ្លួនទារក	*SITHY*		
សញ្ជាតិ (១០)		*ខ្មែរ*		
ថ្ងៃ ខែ ឆ្នាំកំណើត (១១)		*ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២*		
ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស		*.... ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា .....*		
ឪពុក ម្តាយទារក		**ឪពុក**	**ម្តាយ**	
នាមត្រកូល និងនាមខ្លួន (១៣)		*សម សោភ័ណ*	*គុណ រតនា*	
ជាអក្សរឡាតាំង (១៤)		*SAM SORPHORN*	*KUN RATANA*	
សញ្ជាតិ (១៥)		*ខ្មែរ*	*ខ្មែរ*	
ថ្ងៃ ខែ ឆ្នាំកំណើត (១៦)		*ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥*	*ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០*	
ទីកន្លែងកំណើត (១៧) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស		*.....ភូមិព្រែកកែវ ឃុំកោះខែល ស្រុក ស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា.....*	*.....ភូមិពោធិ ឃុំស្អា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា.....*	
ទីលំនៅពេលទារកកើត (១៨)		*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា*	*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា*	

(១៩) ធ្វើនៅ.... *គោកត្រប់* ..... ថ្ងៃទី *០១* ខែ *មីនា* ឆ្នាំ *២០១២*

(២០) **មន្ត្រីអត្រានុកូលដ្ឋាន-----**

មេឃុំ

(២១) *ហត្ថលេខា និងត្រា*

ទ្រី ហៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី(១) ----- ភ្នំពេញ -----
ស្រុក ខណ្ឌ (២) ----- ឫស្សីកែវ -----
ឃុំ សង្កាត់ (៣) ----- ជាក់ខែង ------

លេខ (៤)-------0៩----------
សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-01/2012
ឆ្នាំ (៦)-------- ២០១២ ----------

សំបុត្រអាពាហ៍ពិពាហ៍

អំពីប្តី ប្រពន្ធ		ប្តី	ប្រពន្ធ
នាមត្រកូល (៧)		សាយ	អ៊ូ
នាមខ្លួន (៨)		សំអាន	ន្នួនស្រី
ជាអក្សរឡាតាំង (៩)	នាមត្រកូល	SAY	OU
	នាមខ្លួន	SAM ANN	NUON SREY
សញ្ជាតិ (១០)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (១១)		ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣	ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩
ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស		ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា	ភូមិក្តីចាស់ ឃុំជាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា
មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣)		សាស្ត្រាចារ្យ	គ្រូពេទ្យ
ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤)		ភូមិជាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា	ភូមិក្តីចាស់ សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥)		ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២	
ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦)		សង្កាត់ជាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ	

អំពីឪពុក ម្តាយ	ខាងប្តី	ខាងប្រពន្ធ
នាមត្រកូល និង នាមខ្លួនឪពុក (១៧)	សាយ សំអឿន	អ៊ូ សែម
ជាអក្សរឡាតាំង (១៨)	SAY SAM OEUN	OU SEM
សញ្ជាតិ (១៩)	ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (២០)	ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦	ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥
នាមត្រកូល និង នាមខ្លួនម្តាយ (២១)	សែម បុប្ផា	ន្នួន ផល្លា
ជាអក្សរឡាតាំង (២២)	SEM BOPHA	NUON PHALLA
សញ្ជាតិ (២៣)	ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (២៤)	ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨	ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០

(២៥) ធ្វើនៅ.... ជាក់ខែង .... ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**

មេឃុំ

(២៧) ហត្ថលេខា និងត្រា

ផែ សូនី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី(១) ----- ភ្នំពេញ----
ស្រុក ខណ្ឌ (២) ----- ឫស្សីកែវ ---
ឃុំ សង្កាត់ (៣) ----- បាក់ខែង ----

សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី		(៤) ស្បៀវភៅអាពាហ៍ពិពាហ៍ លេខ ៖--- ០១/២០១២-----	(៥) សំបុត្រអាពាហ៍ពិពាហ៍ លេខ ០៩ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២
អំពីប្តី ប្រពន្ធ		ប្តី	ប្រពន្ធ
នាមត្រកូល (៦)		សាយ	អ៊ូ
នាមខ្លួន (៧)		សំអាន	ន្នួនស្រី
ជាអក្សរឡាតាំង (៨)	នាមត្រកូល	SAY	OU
	នាមខ្លួន	SAM ANN	NUON SREY
សញ្ជាតិ (៩)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (១០)		ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣	ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩
ទីកន្លែងកំណើត (១១) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តដ ក្រុង ប្រទេស		ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា	ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា
មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១២)		សាស្ត្រាចារ្យ	ព្រះពេទ្យ
ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣)		ភូមិបាក់ខែង សង្កាត់ព្រែកល្វែប ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា	ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤)		ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២	
ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥)		សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ	
អំពីឪពុក ម្តាយ		ខាងប្តី	ខាងប្រពន្ធ
នាមត្រកូល និង នាមខ្លួនឪពុក (១៦)		សាយ សំអឿន	អ៊ូ សែម
ជាអក្សរឡាតាំង (១៧)		SAY SAM OEUN	OU SEM
សញ្ជាតិ (១៨)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (១៩)		ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦	ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥
នាមត្រកូល និង នាមខ្លួនម្តាយ (២០)		សែម បុផ្ផា	ន្នួន ផល្លា
ជាអក្សរឡាតាំង (២១)		SEM BOPHA	NUON PHALLA
សញ្ជាតិ (២២)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (២៣)		ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨	ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០

(២៤) ធ្វើនៅ.... បាក់ខែង.... ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន-----**

មេឃុំ

(២៦) ហត្ថលេខា និងត្រា

ផែ សូនី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ---------- ភេទ---------- សញ្ជាតិ---------- ឆ្នាំកំណើត----------
មុខរបរបច្ចុប្បន្ន---------- ស្ថានភាពផ្ទាល់ខ្លួន----------
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ---------- ក្រុម---------- ភូមិ---------- ឃុំ សង្កាត់ ----------
ក្រុង ស្រុក ខណ្ឌ---------- រាជធានី ខេត្ត ----------។ ឪពុកឈ្មោះ---------- អាយុ-------
ឆ្នាំ (រស់ ស្លាប់) ម្តាយឈ្មោះ----------អាយុ-------ឆ្នាំ (រស់ ស្លាប់)។

គោរពជូន

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់.....

<u>កម្មវត្ថុ</u> ៖ សំណើសុំរៀបអាពាហ៍ពិពាហ៍។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ----------ភេទ------
សញ្ជាតិ----------ឆ្នាំកំណើត----------មុខរបរ----------
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម--------- ភូមិ----------ឃុំ សង្កាត់----------
ក្រុង ស្រុក ខណ្ឌ---------- រាជធានី ខេត្ត ----------។

ខ្ញុំសូមអះអាងថា ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---------- មេត្តាអនុញ្ញាត
ឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ។

ធ្វើនៅថ្ងៃទី------ ខែ---------- ឆ្នាំ-------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

ស្នាមមេដៃស្តាំសាមីខ្លួន

- ----------
- ----------
- ----------

ឈ្មោះ----------

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង ----------

ស្រុក ខណ្ឌ ----------

ឃុំ សង្កាត់ ----------

លេខ ----------

បំណុំប្រកាសអាពាហ៍ពិពាហ៍

អំពីសាមីខ្លួន	ខាងប្រុស	ខាងស្រី
នាមត្រកូល និង នាមខ្លួន		
ជាអក្សរឡាតាំង		
សញ្ជាតិ		
ថ្ងៃ ខែ ឆ្នាំកំណើត		
ទីកន្លែងកំណើត		
មុខរបរបច្ចុប្បន្ន		
ទីលំនៅបច្ចុប្បន្ន		
រយៈពេលប្តឹងជិទាស់		
នាមត្រកូល និងនាមខ្លួនឪពុក		
ថ្ងៃ ខែ ឆ្នាំកំណើត		
មុខរបរបច្ចុប្បន្ន		
ទីលំនៅបច្ចុប្បន្ន		
នាមត្រកូល និងនាមខ្លួនម្តាយ		
ថ្ងៃ ខែ ឆ្នាំកំណើត		
មុខរបរបច្ចុប្បន្ន		
ទីលំនៅបច្ចុប្បន្ន		

បំណុំប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី..... ខែ..... ឆ្នាំ..... ។

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....

មន្ត្រីអត្រានុកូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង (១) ----- កណ្តាល -----
ស្រុក ខណ្ឌ (២) ----- ស្អាង --------
ឃុំ សង្កាត់ (៣) ----------

សេចក្តីបម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចេញពី		(៤) ស្បៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ លេខ ៖ ០១/២០០៥	(៥) សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ១២ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥
អំពីប្តី ប្រពន្ធ		ប្តី	ប្រពន្ធ
នាមត្រកូល (៦)		ខេត	ភូង
នាមខ្លួន (៧)		ស្បឿង	វណ្ណា
ជាអក្សរឡាតាំង (៨)	នាមត្រកូល	TEP	PHUONG
	នាមខ្លួន	SOEUNG	VANNA
សញ្ជាតិ (៩)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (១១)		ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨	ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣
ទីកន្លែងកំណើត (១១) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស		ភូមិកណ្តាល ឃុំព្រែកល្អៅ ស្រុកតញ្ជុង ខេត្តកណ្តាល ប្រទេសកម្ពុជា	ភូមិសំបាន់លើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា
មុខរបរពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១២)		គ្រូបង្រៀន	ជាងកាត់ដេរ
ទីលំនៅពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៣)		ភូមិសំបាន់លើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា	ភូមិសំបាន់លើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា
ថ្ងៃ ខែ ឆ្នាំចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៤)		ថ្ងៃ សុក្រ ទី ១៥ ខែ សីហា ឆ្នាំ ២០០៥	
ទីកន្លែងចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៥)		ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល	
អំពីឪពុក ម្តាយ		ខាងប្តី	ខាងប្រពន្ធ
នាមត្រកូល និង នាមខ្លួនឪពុក (១៦)		ខេត សួង	កៅ សៀម
ជាអក្សរឡាតាំង (១៧)		TEP SUONG	KAO SEAM
សញ្ជាតិ (១៨)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (១៩)		ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩២៣	ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩២២
នាមត្រកូល និង នាមខ្លួនម្តាយ (២០)		ប្រាក់ សម្បត្តិ	សុខ សន
ជាអក្សរឡាតាំង (២១)		PRAK SAMBATH	SOK SAN
សញ្ជាតិ (២២)		ខ្មែរ	ខ្មែរ
ថ្ងៃ ខែ ឆ្នាំកំណើត (២៣)		ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩២៥	ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩២៦

លេខ (៧)..... ០៥ ស.ប.អ .....
យើង (ខ).... អភិបាលស្រុកស្អាង .....
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា
របស់លោក (គ).....កុង្ក គីមយ៉ន..... ជាមន្ត្រីអក្សាស្បៀវភៅ
អត្រានុកូលដ្ឋាន (ឃ).....ស្រុកស្អាង.....ពិតប្រាកដមែន។
(ង) ថ្ងៃនៅ...ស្អាង.... ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២
(ច) ហត្ថលេខា និងត្រា
ខឹម ច័ន្ទតារី

(២៤) ថ្ងៃនៅ....ស្អាង ..... ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២
(២៥) មន្ត្រីអក្សរស្បៀវភៅអត្រានុកូលដ្ឋាន----
ហត្ថលេខា
កុង្ក គីមយ៉ន

ខេត្ត ក្រុង (១)..... លេខ (៤).....

ស្រុក ខណ្ឌ (២)..... សៀវភៅអាពាហ៍ពិពាហ៍លេខ (៥).....

ឃុំ សង្កាត់ (៣)..... ឆ្នាំ (៦).....

បញ្ជីអាពាហ៍ពិពាហ៍សំរាប់ជនបរទេស និង ជនអន្តោប្រវេសន្តស្របច្បាប់

អំពីប្តី ប្រពន្ធ		ប្តី	ប្រពន្ធ
នាមត្រកូល (៧)			
នាមខ្លួន (៨)			
ជាអក្សរឡាតាំង (៩)	នាមត្រកូល		
	នាមខ្លួន		
សញ្ជាតិ (១០)			
ថ្ងៃ ខែ ឆ្នាំកំណើត (១១)			
ទីកន្លែងកំណើត (១២)			
មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣)			
ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤)			
ទីលំនៅឯបរទេស (១៥)			
លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៦)			
ទិដ្ឋាការ ឬលិខិតអនុញ្ញាតរស់នៅកម្ពុជាលេខ ថ្ងៃ ខែឆ្នាំ (១៧)			
ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៨)			
ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៩)			
ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (២០)			
លេខ និង ថ្ងៃ ខែ ឆ្នាំ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (២១)			

អំពីឪពុក ម្តាយ	ខាងប្តី		ខាងប្រពន្ធ	
នាមត្រកូល និង នាមខ្លួនឪពុក (២២)	(២៣)	រស់ ឬ ស្លាប់		រស់ ឬ ស្លាប់
ជាអក្សរឡាតាំង (២៤)				
សញ្ជាតិ (២៥)				
ថ្ងៃ ខែ ឆ្នាំកំណើត (២៦)				
មុខរបរបច្ចុប្បន្ន (២៧)				
ទីលំនៅបច្ចុប្បន្ន (២៨)				
នាមត្រកូល និង នាមខ្លួនម្តាយ (២៩)	(៣០)	រស់ ឬ ស្លាប់		រស់ ឬ ស្លាប់
ជាអក្សរឡាតាំង (៣១)				
សញ្ជាតិ (៣២)				
ថ្ងៃ ខែ ឆ្នាំកំណើត (៣៣)				
មុខរបរបច្ចុប្បន្ន (៣៤)				
ទីលំនៅបច្ចុប្បន្ន (៣៥)				

អំពីសាក្សី	សាក្សី		សាក្សី	
នាមត្រកូល និង នាមខ្លួន (៣៦)	(៣៧)	ភេទ		ភេទ
ជាអក្សរឡាតាំង (៣៨)				
សញ្ជាតិ (៣៩)				
ថ្ងៃ ខែ ឆ្នាំកំណើត (៤០)				
មុខរបរបច្ចុប្បន្ន (៤១)				
ទីលំនៅបច្ចុប្បន្ន (៤២)				
លេខអត្តសញ្ញាណប័ណ្ណ (៤៣)				

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះស៊ៀវភៅអត្រានុកូលដ្ឋាន ឱ្យអ្នកដែលមកសុំជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៥) ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....

(៤៤) **ស្ថាមអេដ៍ស្តាំ** (៤៦) **មន្ត្រីអត្រានុកូលដ្ឋាន**

ប្តី ប្រពន្ធ សាក្សី សាក្សី

(៤៧) ហត្ថលេខា និងត្រា

~~រាជធានី~~ ~~ខេត្ត~~ (១)..... *កណ្តាល* .....

~~ក្រុង~~ ~~ស្រុក~~ ~~ខណ្ឌ~~ (២)..... *ស្វាយ* .....

~~ឃុំ~~ ~~សង្កាត់~~ (៣)..... *កោះកែវ* .....

លេខ (៤)..... *០៣* .....

សៀវភៅមរណភាពលេខ (៥)....*០១/២០១៤*....

ឆ្នាំ (៦)..... *២០១៤* .....

បញ្ជីមរណភាព

នាមត្រកូល (៧)		*ស៊ីម*	ភេទ (៩)	សញ្ជាតិ (១០)
នាមខ្លួនសព (៨)		*វ៉ាណា*	*ស្រី*	*ខ្មែរ*
ជាអក្សរឡាតាំង (១១)	នាមត្រកូល	*SIM*		
	នាមខ្លួនសព	*VANNA*		
ថ្ងៃ ខែ ឆ្នាំកំណើត (១២)		*ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១*		
ទីកន្លែងកំណើត (១៣) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស		..... *ភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា*		
ស្ថានភាពសព (១៤) នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ		*មានប្តី*		
មុខរបររបស់សពមុនពេលស្លាប់ (១៥)		*កសិករ*		
ទីលំនៅរបស់សពមុនពេលស្លាប់ (១៦)		*ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា*		
លេខអត្តសញ្ញាណប័ណ្ណ (១៧)		*គ្មាន*		
ថ្ងៃ ខែ ឆ្នាំស្លាប់ (១៨)		*ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤*		
ទីកន្លែងស្លាប់ (១៩)		*ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា*		
មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍ (២០)		*ជើសឈាម*		
នាមត្រកូល និង នាមខ្លួនឪពុកសព (២១)		*ស៊ីម សារឿន*		សញ្ជាតិ *ខ្មែរ* (២២)
ជាអក្សរឡាតាំង (២៤)		*SIM SAROEUN*		~~រស់~~ ឬ ស្លាប់ (២៣)
ថ្ងៃ ខែ ឆ្នាំកំណើត (២៥)		*ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០*		
នាមត្រកូល និង នាមខ្លួនម្តាយសព (២៦)		*ស្រី នាង*		សញ្ជាតិ *ខ្មែរ* (២៧)
ជាអក្សរឡាតាំង (២៩)		*SREY NEANG*		~~រស់~~ ឬ ស្លាប់ (២៨)
ថ្ងៃ ខែ ឆ្នាំកំណើត (៣០)		*ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២*		
នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព (៣១)		*សោម សាវិទ្ធ*	ភេទ (៣២)	សញ្ជាតិ (៣៣)
ថ្ងៃ ខែ ឆ្នាំកំណើត (៣៤)		*ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៤៩*	*ប្រុស*	*ខ្មែរ*
ត្រូវជាអ្វីនឹងសព (៣៥)		*កូនបង្កើត*		
មុខរបរបច្ចុប្បន្ន (៣៦)		*កសិករ*		
ទីលំនៅបច្ចុប្បន្ន (៣៧)		*ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា*		
លេខអត្តសញ្ញាណប័ណ្ណ (៣៨)		*គ្មាន*		

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះស៊ើរវៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋ ដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

(៤០) ធ្វើនៅ...*កោះកែវ*..... ថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*

(៣៩) **ស្ថាមមេដៃស្តាំអ្នករាយការណ៍**

សោម សាវិទ្ធ

(៤១) **មន្ត្រីអត្រានុកូលដ្ឋាន**

មេឃុំ

(៤២) *ហត្ថលេខា និងត្រា*

ប៊ុត ប៊ុន

រាជធានី ខេត្ត (១)..... លេខ (៤).....

ក្រុង ស្រុក ខណ្ឌ (២)..... សៀវភៅមរណភាពលេខ (៥).....

ឃុំ សង្កាត់ (៣)..... ឆ្នាំ (៦).....

បញ្ជីមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់

នាមត្រកូល(៧)			ភេទ(៩)
នាមខ្លួនសព(៨)			
ជាអក្សរឡាតាំង(១០)	នាមត្រកូល		
	នាមខ្លួនសព		
សញ្ជាតិ(១១)			
ថ្ងៃ ខែ ឆ្នាំកំណើត(១២)			
ទីកន្លែងកំណើត (១៣)			
ស្ថានភាពសព(នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ)(១៤)			
មុខរបរមុនពេលស្លាប់ (១៥)			
ទីលំនៅមុនពេលស្លាប់ (១៦)			
ទីលំនៅឯបរទេស (១៧)			
លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៨)			
ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃខែឆ្នាំ(១៩)			
ថ្ងៃ ខែ ឆ្នាំស្លាប់ (២០)			
ទីកន្លែងស្លាប់ (២១)			
មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍(២២)			
នាមត្រកូល និង នាមខ្លួនឪពុកសព (២៣)		ថ្ងៃ ខែ ឆ្នាំកំណើត (២៤)	
ជាអក្សរឡាតាំង (២៥)			
សញ្ជាតិ(២៦)			
ទីលំនៅបច្ចុប្បន្នរបស់ឪពុកសព (២៧)			
នាមត្រកូល និង នាមខ្លួនម្តាយសព (២៨)		ថ្ងៃ ខែ ឆ្នាំកំណើត (២៩)	
ជាអក្សរឡាតាំង (៣០)			
សញ្ជាតិ(៣១)			
ទីលំនៅបច្ចុប្បន្នរបស់ម្តាយសព (៣២)			
នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព(៣៣)		ភេទ(៣៤)	សញ្ជាតិ(៣៥)
ជាអក្សរឡាតាំង (៣៦)			
ថ្ងៃ ខែ ឆ្នាំកំណើត (៣៧)			
ត្រូវជាអ្វីនឹងសព (៣៨)			
មុខរបរបច្ចុប្បន្ន (៣៩)			
ទីលំនៅបច្ចុប្បន្ន (៤០)			
លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (៤១)			
លេខអត្តសញ្ញាណប័ណ្ណ (៤២)			

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្ធំ ចុះស៊ៀវភៅអត្រានុកូលដ្ឋានឱ្យអ្នកដែលមកសុំជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៤) ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....

(៤៣) **ស្នាមមេដៃស្តាំអ្នករាយការណ៍** (៤៥) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៦) ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត (១) ---- *កណ្តាល* ------

ក្រុង ស្រុក ខណ្ឌ (២) ----- *ល្វាឯម* ----

ឃុំ សង្កាត់ (៣) ----- *កោះកែវ* ----

លេខ (៤)--------- *០៣* ----------

សៀវតៅមរណភាពលេខ (៥)--*០១/២០១៤*--

ឆ្នាំ (៦)---------- *២០១៤* ----------

សំបុត្រមរណភាព

នាមត្រកូល (៧)		*ស៊ីម*	តេទ (៩) *ស្រី*
នាមខ្លួនសព (៨)		*វណ្ណា*	
ជាអក្សរឡាតាំង (១០)	នាមត្រកូល	SIM	
	នាមខ្លួនសព	VANNA	
សញ្ជាតិ (១១)		*ខ្មែរ*	
ថ្ងៃ ខែ ឆ្នាំកំណើត (១២)		*ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១*	
ទីកន្លែងកំណើត (១៣) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស		.....ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា*	
ស្ថានភាពសព (១៤) នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ		*មានប្តី*	
ថ្ងៃ ខែ ឆ្នាំស្លាប់ (១៥)		*ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤*	
នាមត្រកូល និង នាមខ្លួនឪពុកសព (១៦)		*ស៊ីម សារឿន*	សញ្ជាតិ (១៧) *ខ្មែរ*
ជាអក្សរឡាតាំង (១៨)		SIM SAROEUN	
ថ្ងៃ ខែ ឆ្នាំកំណើត (១៩)		*ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០*	
នាមត្រកូល និង នាមខ្លួនម្តាយសព (២០)		*ស្រី នាង*	សញ្ជាតិ (២១) *ខ្មែរ*
ជាអក្សរឡាតាំង (២២)		SREY NEANG	
ថ្ងៃ ខែ ឆ្នាំកំណើត (២៣)		*ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២*	

(២៤) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**

មេឃុំ

(២៦) *ហត្ថលេខា និងត្រា*

ប៊ុត ប៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ~~ខេត្ត~~ (១) ---- *កណ្តាល* -----
ក្រុង ~~ស្រុក~~ ~~ខណ្ឌ~~ (២) ----- *ល្វាឯម* ------
ឃុំ ~~សង្កាត់~~ (៣) ----- *កោះកែវ*-----

សេចក្តីចម្លងសំបុត្រមរណភាព

ចម្លងសំបុត្រមរណភាពចេញពី		(៤) ស្បៀវភៅមរណភាព លេខ៖ *០១/២០១៤*	(៥) សំបុត្រមរណភាព លេខ *០៣* ចុះថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*
នាមត្រកូល (៦)		*ស៊ឹម*	ភេទ(៨)
នាមខ្លួនសព (៧)		*វណ្ណា*	*ស្រី*
ជាអក្សរឡាតាំង(៩)	នាមត្រកូល	SIM	
	នាមខ្លួនសព	VANNA	
សញ្ជាតិ (១០)		*ខ្មែរ*	
ថ្ងៃ ខែ ឆ្នាំកំណើត (១១)		*ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១*	
ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស		.....ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា*	
ស្ថានភាពសព (១៣) នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ		*មានប្តី*	
ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤)		*ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤*	
នាមត្រកូលនិងនាមខ្លួនឪពុកសព (១៥)		*ស៊ឹម សារឿន*	សញ្ជាតិ(១៦) *ខ្មែរ*
ជាអក្សរឡាតាំង (១៧)		SIM SAROEUN	
ថ្ងៃ ខែ ឆ្នាំកំណើត (១៨)		*ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០*	
នាមត្រកូលនិងនាមខ្លួនម្តាយសព (១៩)		*ស្រី នាង*	សញ្ជាតិ(២០) *ខ្មែរ*
ជាអក្សរឡាតាំង (២១)		*SREY NEANG*	
ថ្ងៃ ខែ ឆ្នាំកំណើត (២២)		*ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២*	

(២៣) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *១៧* ខែ *មីនា* ឆ្នាំ *២០១៤*

(២៤) **មន្ត្រីអត្រានុកូលដ្ឋាន**

មេឃុំ

(២៥) *ហត្ថលេខា និងត្រា*

ប៊ុត ប៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត (១) ----- *កណ្តាល* -----
ក្រុង ស្រុក ខណ្ឌ (២) ----- *កោះធំ* ------
ឃុំ សង្កាត់ (៣) --------*ព្រែកស្តី*------

សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព

ចម្លងសំបុត្របញ្ជាក់មរណភាពចេញពី		(៤) ស្បៀវភៅបញ្ជាក់មរណភាព លេខ៖ *០១/២០០៦*	(៥) សំបុត្របញ្ជាក់មរណភាព លេខ០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦
នាមត្រកូល (៦)		*ម៉ែន*	ភេទ(៨) *ប្រុស*
នាមខ្លួនសព (៧)		*សាម៉ន*	
ជាអក្សរឡាតាំង(៩)	នាមត្រកូល	*MEN*	
	នាមខ្លួនសព	*SAMAN*	
សញ្ជាតិ (១០)		*ខ្មែរ*	
ថ្ងៃ ខែ ឆ្នាំកំណើត (១១)		*ថ្ងៃ សុក្រ ទី ០៣ ខែ មីនា ឆ្នាំ ១៩៣១*	
ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស		.... ភូមិវាលស្បូវ ឃុំវាលស្បូវ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា	
ស្ថានភាពសព (១៣) នៅលើវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ		*ពោះម៉ាយ*	
ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤)		*ថ្ងៃ ពុធ ទី ១៥ ខែ មករា ឆ្នាំ ១៩៩៧*	
នាមត្រកូលនិងនាមខ្លួនឪពុកសព (១៥)		*ម៉ែន សាម៉ន*	សញ្ជាតិ(១៦) *ខ្មែរ*
ជាអក្សរឡាតាំង (១៧)		MEN SAMEN	
ថ្ងៃ ខែ ឆ្នាំកំណើត (១៨)		*ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១០*	
នាមត្រកូលនិងនាមខ្លួនម្តាយសព (១៩)		*សួន ប្រាថ្នា*	សញ្ជាតិ(២០) *ខ្មែរ*
ជាអក្សរឡាតាំង (២១)		*SUON PRATHNA*	
ថ្ងៃ ខែ ឆ្នាំកំណើត (២២)		*ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩១២*	

លេខ(ក)..... *០១ ក.ត.ប.ម* .....

យើង(ខ).... *អភិបាលស្រុកកោះធំ* .....

បានឃើញនិងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា
របស់លោក(គ)..... *អ៊ូច ប៊ុនគីម*..... ជាមន្ត្រីរក្សាស្បៀវភៅ
អត្រានុកូលដ្ឋាន(ឃ).....ស្រុកកោះធំ.....ពិតប្រាកដមែន ។

(ង) ធ្វើនៅកោះធំ..... ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤

(ច) *ហត្ថលេខា និងត្រា*

ខៀវ សំអាត

(២៤) ធ្វើនៅ...កោះធំ.... ថ្ងៃទី *១៤* ខែ *មករា* ឆ្នាំ *២០១៤*

(២៥) **មន្ត្រីរក្សាស្បៀវភៅអត្រានុកូលដ្ឋាន**

ហត្ថលេខា

អ៊ូច ប៊ុនគីម

ឧបសម្ព័ន្ធទី៣ ៖
អនុក្រឹត្យស្តីពី ការកំណត់ផ្ទៃជាឥ
អនុក្រឹត្យស្តីពី ការកែសម្រួល
អត្រានុកូលដ្ឋាន
អនុក្រឹត្យស្តីពី មន្ត្រីអត្រានុកូលដ្ឋាន
អនុក្រឹត្យស្តីពី ការកំណត់បែបបទ
និងនីតិវិធីនៃការរៀប
អាពាហ៍ពិពាហ៍នៅទូទាំងព្រះរាជាណាចក្រ និង
ជនបរទេស

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ២៤ អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការកំណត់ថ្លៃជាមត្រដ្ឋានសម្រាន់ក្នុងលដ្ឋាន និងថ្លៃតែមប្រឹសារពើពន្ធ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ២៣ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសរអោយប្រើច្បាប់ស្តីពីការបង្កើតតែមប្រឹសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៧៦អនក្រ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលំអ និង បំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រឹ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំលើកទី១៤ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំ រ ច

មាត្រា ១៖

ត្រូវបានកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទដូចខាងក្រោម ÷

ក- ខេត្តរតនគីរី-មណ្ឌលគីរី-ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ :

- បណ្ណប្រកាសអាពាហ៍ពិពាហ៍	កំណត់ ២០០ រៀល ក្នុង ១ ទំព័រ
- សំបុត្រអាពាហ៍ពិពាហ៍	កំណត់ ១០០ រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់រអាពាហ៍ពិពាហ៍	កំណត់ ១០០ រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់កំណើត	កំណត់ ១០០ រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់មរណភាព	កំណត់ ១០០ រៀល ក្នុង ១ ទំព័រ
- សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ	កំណត់ ១០០ រៀល ក្នុង ១ ទំព័រ

ខ- ខេត្ត-ក្រុង ក្រៅពីខេត្តទាំង ០៥ ខាងលើ :

- បណ្ណប្រកាសអាពាហ៍ពិពាហ៍	កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ
- សំបុត្រអាពាហ៍ពិពាហ៍	កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍	កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់កំណើត	កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់មរណភាព	កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ
- សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ	កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ

មាត្រា ២ ៖-

ថ្លៃតែមប្រើសារពើពន្ធសំរាប់ចិទលើក្រដាសអត្រានុកូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម ៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍	កំណត់ ១.000 រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត	កំណត់ ៣00 រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត	កំណត់ ៣00 រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍	កំណត់ ១.៥00 រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍	កំណត់ ១.៥00 រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព	កំណត់ ៤00 រៀល ក្នុង ១ ច្បាប់
- សេចក្តីចម្លងឬ សម្រង់សំបុត្របញ្ជាក់មរណភាព	កំណត់ ៤00 រៀល ក្នុង ១ ច្បាប់

មាត្រា ៣ ៖-

ចំណូលដែលឃុំ សង្កាត់ ប្រមូលបានពីការលក់ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវចាត់ជាចំណូលផ្ទាល់របស់ថវិកាឃុំ សង្កាត់ ។

មាត្រា ៤ ៖-

ក្រសួងមហាផ្ទៃមានការកិច្ចបោះពុម្ពក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សំរាប់ផ្តល់ផ្តង់ដល់អាជ្ញាធរដែលមានភារកិច្ចអនុវត្តការងារចុះបញ្ជីអត្រានុកូលដ្ឋាន ។

មាត្រា ៥ ៖-

ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ ក្នុងករណីចាំបាច់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងបន្ថែមទៀត ។

មាត្រា ៦ ៖-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣/អនក្រ/២០០៨

អនុក្រឹត្យ

ស្តីពី

ការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ។
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សំរេច

មាត្រាតែមួយ ..

កែសំរួលមាត្រា ២៥ មាត្រា ៤០ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៧ មាត្រា ៥១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន

និងមាត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី ការកែសំរួលមាត្រា៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដូចខាងក្រោម :

មាត្រា២៥ថ្មី ..

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ចុះស្សៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំសំបុត្រកំណើតនេះពី មេឃុំ ចៅសង្កាត់ សាមី ដោយបង់ប្រាក់ថ្លៃសំបុត្រកំណើតដល់អាជ្ញាធរ ឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀលសំរាប់ប្រជាពលរដ្ឋមានទីលំនៅនៅក្នុងខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែមអំពីបែបបទ និង នីតិវិធីនៃការសុំ និង ការចុះស្សៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងករណីខាងលើនេះ ។

មាត្រា៤០ថ្មី ..

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ ថ្ងៃ ពុំបានទៅរាយការណ៍ចុះស្សៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅក្នុងខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែម អំពីបែបបទ នីតិវិធី នៃការសុំ និង ការចុះស្សៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងករណីខាងលើនេះ ។

មាត្រា៤៣ថ្មី ..

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះស្សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅ សាលាឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សី ចំនួន ០២ រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខ មន្ត្រីអត្រា-នុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលប្សៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារប្សៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើតហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះស្សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវអោយខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារប្សៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

មាត្រា៤៥ថ្មី ..

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះស្បៀវភៅអាពាហ៍-ពិពាហ៍ សាមីខ្លួនទាំងពីរអាចសុំចុះស្បៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជន និងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

មាត្រា៤៧ថ្មី ..

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តាន ដែលនៅរស់អាចមកសុំចុះ ស្បៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មី នៅសាលា ឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សី ចំនួន ០២ រូប ជានីតិជន ហើយមានទីលំនៅពិតប្រាកដ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា៥១ថ្មី ..

ការសុំចម្លង ឬ សំរង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឬសង្កាត់ ហើយត្រូវបោះត្រាផង ។

មាត្រា៥៩ថ្មីស្នង ..

ក. ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះស្បៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត ស្បៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ ស្បៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ជុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យនេះ ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ន្ធ ។

សំរាប់ឆ្នាំ ២០០២ ស្បៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់បញ្ចីត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅ ត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

ខ.ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ប្រជាពលរដ្ឋ ដែលបានមកចុះស្នៀវភៅអត្រានុកូលដ្ឋានរួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៥ ហើយដែលមិនទាន់បានចុះស្នៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែលឪពុកឬម្តាយ ឬ អាណាព្យាបាល មកសុំចុះស្នៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលក្នុងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នោះនឹងត្រូវបាន ផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

គ.ដើម្បីបង្កលក្ខណៈសម្បត្តិងាយស្រួល ជូនប្រជាពលរដ្ឋ ក្នុងការចុះស្នៀវភៅអត្រានុកូលដ្ឋាន ឃុំ សង្កាត់ អាចចាត់អោយមានការចុះស្នៀវភៅអត្រានុកូលដ្ឋានចល័តក្នុងឃុំ សង្កាត់ របស់ខ្លួនតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ ។

បានយកសេចក្តីជូនដំណឹងជូនសម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស. ហុកឡៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.១៣៤.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦០អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា៨និងមាត្រា៥៩នៃអនុក្រឹត្យលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៨៣អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងការងារអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា២.-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣.-

អនុក្រឹត្យនេះមានវិសាលភាពលើការគ្រប់គ្រងការងារអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

មាត្រា៤.-

អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

មាត្រា៥.-

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមានភារកិច្ច៖

- ធានាការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីអត្រានុកូលដ្ឋាន
- ដាក់ចេញនូវគោលការណ៍ សេចក្តីណែនាំ បែបបទនិងនីតិវិធីនានាស្របតាមការកំណត់នៃច្បាប់
- បញ្ជានិងណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានលើការអនុវត្តការងារអត្រានុកូលដ្ឋាន
- រាយការណ៍ពីការរំលោភបទប្បញ្ញត្តិច្បាប់ដែលប្រព្រឹត្តដោយមន្ត្រីអត្រានុកូលដ្ឋានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីចាត់វិធានការដាក់វិន័យតាមច្បាប់
- ពិនិត្យសម្រេចនិងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញស្របតាមបទប្បញ្ញត្តិនៃច្បាប់
- ពិនិត្យសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តមិនស្របតាមនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- ពិនិត្យសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋានក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិមិនអាចសម្រេចបាន
- ដាក់ឱ្យប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗជាផ្លូវការ
- ចេញសេចក្តីចម្លងនិងសម្រង់អត្រានុកូលដ្ឋានក្នុងករណីមានការស្នើសុំ។

មាត្រា៦.-

បែបបទនិងនីតិវិធីនៃការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..២៨៣.អស(ល)ប៥

អនុក្រឹត្យ

ស្តីពី

ការតំណាងបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍

រវាងពលរដ្ឋខ្មែរ និងជនបរទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញក្រឹត្យលេខ ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥ នស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឯកពន្ធភាព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីចែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា រវាងពលរដ្ឋខ្មែរ និងជនបរទេស។

មាត្រា ២.-

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាទីខ្លួន និងត្រូវអនុវត្តតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣.-

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងារឈើសូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម។

មាត្រា ៤.-

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។

ឧបសម្ព័ន្ធទី៤ ៖

សេចក្តីណែនាំស្តីពី ការចុះសៀវភៅអត្រានុកូលដ្ឋានរយៈពេលវែង ក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋាន

សេចក្តីណែនាំស្តីពី ការបន្តជំរឿន ការកែតម្រូវ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :០.០.៨៧ សជណ

ភ្ជាប់ជាមួយលិខិតចុះ
ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៧

រាជធានីភ្នំពេញ, ថ្ងៃទី ១...៨ ខែធ្នូ ឆ្នាំ ២០០៧

សេចក្តីណែនាំ
ស្តីពី
ការចុះស៊ើបតាមអត្រានុកូលដ្ឋាន
ឱ្យមានទិន្នន័យភាពត្រឹមត្រូវបញ្ចប់យុទ្ធនាការ
ចុះស៊ើបតាមអត្រានុកូលដ្ឋានចល័ត

ការចុះស៊ើបតាមអត្រានុកូលដ្ឋាន គឺជាការផ្តល់នូវឯកសារគតិយុត្តិដ៏សំខាន់ចាំបាច់ ជូនប្រជាពលរដ្ឋទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និង មរណភាព។ ឯកសារគតិយុត្តិទាំងនេះ គឺជាឯកសារ និងជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ និង ស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលដៅលើកស្ទួយនូវសិទ្ធិ ករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ ៗ នៅក្នុងក្រកូលគ្រួសារខ្លួន និង សង្គមជាតិ ។ ក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋ ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែប្រើប្រាស់ឯកសារអត្រានុកូលដ្ឋានសំរាប់ការពារសិទ្ធិ សេរីភាព ផលប្រយោជន៍ និង កាតព្វកិច្ចនានា ក្នុងសង្គម ។

អនុលោមតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីសួន នៃអនុក្រឹត្យលេខ ១០៦ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការកែសម្រួលចំណុច "ក" និង "ខ" មាត្រា ៥៩ ថ្មី សួន ។

ក្រោយពីយុទ្ធនាការ នៃការចុះស៊ើបតាមអត្រានុកូលដ្ឋានចល័ត ត្រូវបានបញ្ចប់នៅថ្ងៃទី [illegible] ឆ្នាំ ២០០៦ និង ដើម្បីឱ្យដំណើរការ នៃការចុះស៊ើបតាមអត្រានុកូលដ្ឋានអនុវត្តទៅបានល្អប្រសើរ និង [illegible] ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំ ដូចខាងក្រោម ÷

I- <u>អំពីតារកិច្ច</u> :

១- <u>ថ្នាក់ក្រសួង</u> :

នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួង លើការងារស្ថិតិ និង អត្រានុកូលដ្ឋាន និង មានភារកិច្ច ដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ ពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន
- ណែនាំ សំរបសំរួល និង ត្រួតពិនិត្យការអនុវត្តការចុះស្ទើរភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ
- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងប្រទេស
- បូកសរុបស្ថិតិប្រជាពលរដ្ឋ ដែលបានចុះស្ទើរភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ នៅគ្រប់ខេត្ត ក្រុង ទូទាំងប្រទេសរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- លើកផែនការស្នើសុំបោះពុម្ពស្ទើរភៅ និង ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ជូនដល់ខេត្ត ក្រុង អោយបានគ្រប់គ្រាន់ និង ទាន់ពេលវេលា
- សហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និង ការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន
- រៀបចំបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធពត៌មានវិទ្យា
- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន ។

២- <u>ថ្នាក់ខេត្ត ក្រុង</u> :

អភិបាលខេត្ត ក្រុង ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន នៅខេត្ត ក្រុង របស់ខ្លួន ដោយមានការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាននៃសាលាខេត្ត ក្រុងជាសេនាធិការ និង មានភារកិច្ច :

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងខេត្ត ក្រុង និង ផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃតាមការកំណត់
- ត្រួតពិនិត្យការអនុវត្តការចុះស្ទើរភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមស្រុក ខណ្ឌ និង ឃុំ សង្កាត់
- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះស្ទើរភៅអត្រានុកូលដ្ឋានគ្រប់ភេទប្រចាំខែ និង ផ្ញើរបាយការណ៍ទៅក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ) រឿងរាល់ថ្ងៃទី ១៥ នៃខែបន្ទាប់នីមួយៗ
- លើកតំរោងទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំស្ទើរភៅ និង ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សំរាប់ផ្តល់ឱ្យ ស្រុក ខណ្ឌ ធ្វើការបែងចែកដល់ឃុំ សង្កាត់ និង ធ្វើរបាយការណ៍បូកសរុបការប្រើប្រាស់ ឱ្យបានទាន់ពេលកំណត់
- សហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និង ការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន
- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ អំពីការងារអត្រានុកូលដ្ឋានដល់ស្រុក ខណ្ឌ ឃុំ សង្កាត់ចំណុះ
- ធ្វើការវាយតំលៃការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋានក្នុងខេត្ត ក្រុងរបស់ខ្លួន
- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន ។

៣- <u>ថ្នាក់ស្រុក ខណ្ឌ</u> :

អភិបាលស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និង អនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន នៅស្រុក ខណ្ឌ របស់ខ្លួន ដោយមានការិយាល័យរដ្ឋបាលទូទៅនៃសាលាស្រុក ខណ្ឌជាសេនាធិការ មានភារកិច្ចដូចខាងក្រោម ÷

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងស្រុក ខណ្ឌ និង ផ្ញើរបាយការណ៍មកខេត្ត ក្រុងតាមការកំណត់

- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះស្បៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែនីមួយៗ តាមឃុំ សង្កាត់ចំណុះ និង ផ្ញើទៅការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាននៃសាលាខេត្ត ក្រុង រៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ នីមួយៗ

- លើកគំរោងទៅសាលាខេត្ត ក្រុង ដើម្បីសុំស្បៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានសម្រាប់បែងចែកជូន ឃុំ សង្កាត់ និង បូកសរុបការប្រើប្រាស់ស្បៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន ផ្ញើមកខេត្ត ក្រុងតាមការកំណត់

- ចុះចំនួនសន្លឹក លេខរៀងសន្លឹកស្បៀវភៅអត្រានុកូលដ្ឋាន ចុះហត្ថលេខាពេញ និង សង្កេបរបស់អភិបាលស្រុក ខណ្ឌ បោះត្រា មុននឹងបែងចែកឱ្យឃុំ សង្កាត់ យកទៅប្រើប្រាស់

- ត្រួតពិនិត្យជាប្រចាំការអនុវត្តការចុះស្បៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមឃុំ សង្កាត់

- ត្រួតពិនិត្យរាល់បញ្ជីក្នុងស្បៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដែលឃុំ សង្កាត់ផ្ញើមកស្រុក ខណ្ឌ ពេលដាច់ឆ្នាំនីមួយៗ ឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងមហាផ្ទៃ

- រក្សាទុកដាក់ស្បៀវភៅអត្រានុកូលដ្ឋាន ឱ្យបានគត់មត់នៅសាលាស្រុក ខណ្ឌ មួយច្បាប់ តាមប្រភេទនីមួយៗ និង មួយច្បាប់ទៀតដូចគ្នា ផ្ញើទៅតុលាការខេត្ត ក្រុង សាមី

- ចេញសេចក្តីចម្លង ឬ សម្រង់ នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនដល់ប្រជាពលរដ្ឋ ដែលមកសុំចម្លងឆ្នាំដែលកន្លងផុត

- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ អំពីការងារអត្រានុកូលដ្ឋានដល់ឃុំ សង្កាត់ចំណុះ

- ធ្វើការវាយតំលៃ ការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋានក្នុងស្រុក ខណ្ឌរបស់ខ្លួន

- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន ។

៤- <u>ថ្នាក់ឃុំ សង្កាត់</u> :

ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ ដែលខ្លួនគ្រប់គ្រង មេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រាកូលដ្ឋាន ។ មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ÷

- លើកគម្រោងស្នើសុំស្បៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានមកសាលាស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ចលនាប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនអោយមកសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអោយបានគ្រប់ៗគ្នា និង ទាន់ពេលវេលា

- ទទួលពិនិត្យកត់ត្រារឿងហេតុសំខាន់ៗទាក់ទងទៅនឹងកំណើត អាពាហ៍ពិពាហ៍ លំនៅដ្ឋានទាំងឡាយចុះនៅក្នុងស្បៀវភៅអត្រានុកូលដ្ឋាន

- ចេញសេចក្តីចម្លង ឬ សម្រង់នៃអត្រានុកូលដ្ឋានដែលមាននៅឆ្នាំដើមដែលមិនទាន់ដាច់

- អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ ធ្វើបុណ្យចូលជា ឬ បញ្ចុះសព

- ទទួលខុសត្រូវ ចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត

- ចុះហត្ថលេខា និង បោះត្រាលើសំបុត្រអត្រានុកូលដ្ឋាន

- កែតម្រូវ ឬ បដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់

- ថែរក្សាទុកដាក់ស្បៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទអោយបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និង ការគ្រប់គ្រង

- បិទស្បៀវភៅ និង បញ្ជូនស្បៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលជាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និង នៅតុលាការខេត្ត ក្រុង សាមីមួយច្បាប់

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ឱ្យបានយល់ដឹងពីភាពកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងពីការងារអត្រានុកូលដ្ឋាន

- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ជារៀងរាល់ខែ នាថ្ងៃទី ៥ នៃខែបន្ទាប់ និង រាល់ដំណាច់ឆ្នាំនីមួយ។ ផ្ញើទៅសាលាស្រុក ខណ្ឌ សាមី

- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

ដើម្បីជួយដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយអំពីសារៈប្រយោជន៍អត្រានុកូលដ្ឋាន ឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់អាចប្រើប្រាស់នូវគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ (យោងលើសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៥ ស.ណ.ន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់) អោយជួយលើការងារនេះ ដោយបែងចែកនូវភារកិច្ចជូន ដូចខាងក្រោម ÷

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារក្នុងឃុំ សង្កាត់ ត្រូវជម្រុញការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ ឱ្យយល់ជ្រួតជ្រាបអំពីសិទ្ធិនារី និង កុមារ ពិសេសអំពីផលប្រយោជន៍ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន រួមមាន កំណើត អាពាហ៍ពិពាហ៍ និង មរណភាព និង កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ក្នុងការចុះស្បៀវភៅអត្រានុកូលដ្ឋាន។

- មេឃុំ ចៅសង្កាត់ ជំទប់ទី២ ឬ ចៅសង្កាត់រងទី២ ត្រូវចូលនៅតាមវត្តអារាម ដើម្បីសំណូមពរដល់ព្រះសង្ឃ អាចារ្យវត្ត នៅពេលមានបុណ្យទាន ឬ ពេលមានពិធីរៀបអាពាហ៍ពិពាហ៍ ឬ ពិធីបុណ្យសព សូមជួយផ្សព្វផ្សាយអោយប្រជាពលរដ្ឋអញ្ជើញទៅចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើតពេលមានទារកកើត ទៅចុះស្បៀវភៅអាពាហ៍ពិពាហ៍ពេលមានរៀបអាពាហ៍ពិពាហ៍ និង ទៅចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពពេលមានអ្នកស្លាប់ ។

- សមាជិកនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ ត្រូវចុះផ្សព្វផ្សាយផ្ទាល់នៅតាម ភូមិ ឬ ផ្ទាំមផ្ទះប្រជាពលរដ្ឋ ដើម្បីជំរាបអំពីសារៈប្រយោជន៍ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ។

- សមាជិកនៃគណៈកម្មាធិការដែលតំណាងឱ្យមណ្ឌលសុខភាពឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយផ្ទាល់នៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យរដ្ឋ និង ឯកជន ពេលមានមាតាមកសម្រាលកូននៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ ពេលចេញទៅវិញត្រូវទៅសុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យទារក នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកកុំឱ្យហួសពី ៣០ថ្ងៃ បន្ទាប់ពីប្រសូតទារក និង នៅពេលមានអ្នកស្លាប់នៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យត្រូវជម្រាបដល់ក្រុមគ្រួសារ ឬ សាច់ញាតិសន្តានៃសពឱ្យទៅសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាព

ក្នុងរយៈពេល ១៥ថ្ងៃ នៅឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកស្លាប់ ដោយមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ ចេញនូវលិខិតបញ្ជាក់អំពីកំណើត ទារកជូនទៅឪពុក ម្តាយទារក ឬ លិខិតបញ្ជាក់អំពីមរណភាពជូនទៅក្រុមគ្រួសារ ឬ សាច់ញាតិសន្តានៃអ្នកស្លាប់ ។

- សមាជិកនៃគណៈកម្មាធិការដែលតំណាងឱ្យគ្រូបង្រៀន ត្រូវចលនាជំរាបជូនលោកគ្រូ អ្នកគ្រូ នៅតាមសាលារៀន សំណូមពរឱ្យជួយផ្សព្វផ្សាយជាប្រចាំក្នុងពីរសប្តាហ៍ម្តងដល់សិស្ស ដើម្បីជម្រាបទៅឪពុក ម្តាយ នៃសិស្ស ទាំងនោះបានជ្រាបពីសារៈប្រយោជន៍ នៃការសុំចុះស្បៀវភៅអត្រានុកូលដ្ឋាន ។

- ក្នុងករណីដែលឃុំ សង្កាត់ មិនមានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ មេឃុំ ចៅសង្កាត់ ត្រូវចាត់ឱ្យជនបង្គោលទទួលបន្ទុកស្ត្រី និង កុមារ ឱ្យទទួលខុសត្រូវក្នុងការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃអត្រានុកូលដ្ឋាន និង កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ចំពោះការចុះស្បៀវភៅអត្រានុកូលដ្ឋាន ដោយអនុវត្តយកលំនាំតាមការបែងចែកប្រគល់ភារកិច្ចនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ ។

ខ្លឹមសារត្រូវដែជម្រាបជូនដល់ប្រជាពលរដ្ឋអំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព មានដូចខាងក្រោម ÷

- ពេលមានទារកកើតឪពុក ម្តាយ ត្រូវទៅរាយការណ៍សុំចុះបញ្ជីអត្រានុកូលដ្ឋានកំណើត កុំឱ្យហួសពី ៣០ថ្ងៃ បន្ទាប់ពីប្រសូតទារក នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារក ។

- ពេលបុរស នារីសុំរៀបអាពាហ៍ពិពាហ៍ ត្រូវអនុវត្តតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង ត្រួសារ ហើយត្រូវទៅសុំចុះស្បៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋាននារី ទើបអាពាហ៍ពិពាហ៍នោះ ចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់ ។

- ពេលមានអ្នកស្លាប់ ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន នៃអ្នកស្លាប់ត្រូវទៅសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេល១៥ថ្ងៃ នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកស្លាប់ ។

៥- <u>នៅភូមិ</u> :

- មេភូមិត្រូវចលនាឱ្យប្រជាពលរដ្ឋទៅចុះស្បៀវភៅអត្រាកូលដ្ឋានមានកំណើត និង មរណភាព ឱ្យបានទាន់ពេលវេលា និង អ្នកបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ និង អ្នកដែលត្រៀងរៀបចំអាពាហ៍ពិពាហ៍ ដើម្បីឱ្យស្របទៅតាមច្បាប់ ត្រូវទៅសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ ខាងលំនៅដ្ឋាននារី ស្របទៅតាមច្បាប់អាពាហ៍ពិពាហ៍ ។

- មេភូមិ ត្រូវចេញលិខិតបញ្ជាក់ទទួលស្គាល់កំណើតទារកឱ្យឪពុក ម្តាយ បើទារកកើតនៅផ្ទះ ដើម្បីឱ្យឪពុកម្តាយទារក មានឯកសារភស្តុតាងសម្រាប់ទៅសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីចុះស្បៀវភៅអត្រាកូលដ្ឋានកំណើតឱ្យកូន ។

- មេភូមិត្រូវកត់ត្រាប្រចាំខែនីមួយ។ឱ្យបានច្បាស់លាស់នូវស្ថិតិ :

. ទារកដែលទើបកើត

. ទារកដែលទើបកើត ហើយ ស្លាប់

. អ្នកដែលបានរួមរស់ជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធ មានសំបុត្រអាពាហ៍ពិពាហ៍ ។

. អ្នកដែលទទួលមរណភាព

- មេភូមិត្រូវស្រង់ស្ថិតិទារក ដែលបានសុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើតទាន់ពេលកំណត់ ៣០ថ្ងៃ រួចហើយ និង ទារកដែលមិនទាន់បានសុំចុះស្បៀវភៅអត្រានុកូលដ្ឋាន ហួសពេលកំណត់ ៣០ថ្ងៃ អ្នកទទួលមរណភាព បានសុំចុះស្បៀវភៅអត្រាកូលដ្ឋានមរណភាពបានទាន់ពេលកំណត់ ១៥ថ្ងៃ និង អ្នកទទួលមរណភាពទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ពុំបានសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាព អ្នកដែលបានរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល (បានសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រួច) និង អ្នកដែលរៀបចំអាពាហ៍ពិពាហ៍តាមប្រពៃណី តែមិនទាន់បានរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល (ពុំទាន់បានចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍) រួចផ្ទៀស្ថិតិនេះទៅសាលាឃុំ សង្កាត់ នៅថ្ងៃទី ០៣ នៃខែបន្ទាប់ ដើម្បីធ្វើការបូកសរុប។ ផ្អែកលើស្ថិតិនេះ មេភូមិត្រូវជម្រុញឱ្យ ឪពុក ម្តាយ ឬ អាណាព្យាបាលទារក ដែលទើបកើតឱ្យទៅចុះបញ្ជីកំណើតនៅសាលាឃុំ សង្កាត់ ឱ្យបានទាន់ពេលវេលា គឺកុំឱ្យហួស ៣០ថ្ងៃ បន្ទាប់ពីទារកប្រសូត ។

II- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើត និង មរណភាពក្នុងរយៈពេលកំណត់</u> :

១- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើតក្នុងរយៈពេលកំណត់ ៣០ថ្ងៃ</u> :

(យោងតាមមាត្រា ១៧ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន)

បើមានទារកកើត ឪពុក ឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃ ។ បើឪពុក ម្តាយមានធុរៈទៅមិនបានត្រូវពឹងពាក់សាច់ញាតិសន្តាន ឬ អ្នកនៅជិតខាង ដែលបានឃើញ និង ដឹងឮផ្ទាល់អំពីទារកនោះកើត ឱ្យទៅរាយការណ៍សុំចុះស្បៀវភៅកំណើតបានទាន់ពេលកំណត់ ។

អ្នកទៅរាយការណ៍សុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើត ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុ អំពីកំណើតទារករបស់អ្នកទទួលខុសត្រូវពន្ធនាគារ បើទារកកើតនៅក្នុងពន្ធនាគារ ឬ
- លិខិតបញ្ជាក់របស់ឪពុក ម្តាយ អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក បើឪពុក ម្តាយទារកពឹងពាក់សាច់ញាតិ ឬ អ្នកជិតខាងអោយទៅរាយការណ៍ជំនួស
- ស្បៀវភៅគ្រួសារដែលមានឈ្មោះឪពុក ម្តាយទារក (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុក ម្តាយទារក (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឪពុក ឬ ម្តាយ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្ររាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុក ម្តាយទារក (ប្រសិនបើមាន)

ទារកដែលបានចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងរយៈពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្តល់នូវសំបុត្រកំណើតច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ ។

២- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពក្នុងរយៈពេលកំណត់ ១៥ថ្ងៃ</u> :

(យោងមាត្រា ៣៥. មាត្រា ៣៦. មាត្រា ៣៧. មាត្រា ៣៨ និង មាត្រា ៣៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន)

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្នុងក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

ការចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីទទួលមរណភាព ។

អ្នកទៅរាយការណ៍សុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- លិខិតជូនដំណឹងមរណភាព បញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងនឹងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ ករណីស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងពន្ធនាគារ ឬ
- លិខិតជូនដំណឹងរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬ អង្គភាពរបស់អ្នកស្លាប់ ករណីអ្នកស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬ អង្គភាព
- ស្បៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវផ្តល់នូវសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ដោយឥតគិតថ្លៃ ទៅឲ្យអ្នកតំណាងក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ដែលមករាយការណ៍សុំចុះស្បៀវភៅមរណភាព ចំពោះអ្នកស្លាប់ក្នុងរយៈពេលកំណត់ ១៥ថ្ងៃ ។

III- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះអ្នកដែលរៀបការតាមប្រពៃណី អាពាហ៍ពិពាហ៍ ផ្ទៃក្នុងតាមច្បាប់ ស្តីពី អាពាហ៍ពិពាហ៍ និង ត្រូវលុបចោល</u>

(យោងមាត្រា ២៨. មាត្រា ២៩. មាត្រា ៣០ និង មាត្រា ៣១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន)

បុរស នារី ដែលបានធ្វើប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រួចផុតកំណត់១០ថ្ងៃមិនមានការប្តឹងតវ៉ា ដើម្បីធានាឱ្យអាពាហ៍ពិពាហ៍នោះមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ សាមីខ្លួនទាំងពីររូបត្រូវរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល ដោយត្រូវមកសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ដោយនាំមកជាមួយនូវប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និង សាក្សីគ្រប់អាយុការចំនួនពីរនាក់ មក៏បង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍ តាមគោលការណ៍ លំដៅឱ្យច្បាប់ការពារ សិទ្ធិ ករណីយកិច្ច និង ផលប្រយោជន៍របស់គូស្វាមីភរិយា តរៀងទៅ ។

IV- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះពលរដ្ឋខ្មែរ ដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធ តែពុំទាន់មានសំបុត្រអាពាហ៍ពិពាហ៍</u> :

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធ ឬ បានរៀបចំអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែពុំទាន់មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនទាំងពីររូប ត្រូវប្តឹងសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍(ការរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល)នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន។ ដើម្បីទទួលបាននូវសំបុត្រអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងពីររូប ត្រូវមានលិខិតស្នាម ដូចខាងក្រោម ÷

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន (ប្រសិនបើមាន) ឬ
- ស្បៀវភៅគ្រួសាររបស់សាមីខ្លួន (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន (ប្រសិនបើមាន) ។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីពិនិត្យឃើញថា មានឯកសារគ្រប់គ្រាន់ និង ត្រឹមត្រូវហើយ ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០៣ ច្បាប់ ដោយមួយច្បាប់បិទផ្សាយជាសាធារណៈនៅផ្ទះសាមីខ្លួនទាំងពីររូប មួយច្បាប់បិទនៅសាលាឃុំ សង្កាត់សាមី និង មួយច្បាប់ទៀតរក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់សាមី។ ក្នុងពេលបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រយៈពេល ១០ ថ្ងៃ បើគ្មានការប្តឹងជំទាស់ទេ សាមីខ្លួនទាំងពីររូបអាចទៅសុំចុះស្បៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (ការរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល) បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់សាមី ដោយនាំសាក្សី ០២ រូប ដែលមានអាយុគ្រប់ការ និង មានទីលំនៅពិតប្រាកដទៅជាមួយ ។

V- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើត និង មរណភាពហួសរយៈពេលកំណត់</u> :

១- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានកំណើតហួសរយៈពេល ៣០ថ្ងៃ</u> :

ពលរដ្ឋខ្មែរដែលបានកើតហើយទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំចុះស្បៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន ០២រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល និង សាក្សី ត្រូវមានទូរលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- ពាក្យប្តឹងសុំចុះស្បៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ចំនួន ០១ច្បាប់ ដែលបិទតែមប្រិ៍ថ្លៃ ១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង បិទតែមប្រិ៍ថ្លៃ ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ។ ចំពោះការបិទតែមប្រិ៍តម្លៃ ១.០០០ រៀល និង ៤.០០០ រៀល លើពាក្យប្តឹងសុំ គឺជំនួសឱ្យការបង់ប្រាក់ផ្ទាល់។

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើកើតនៅផ្ទះ ឬ
- កំណត់ហេតុ ឬ លិខិតបញ្ជាក់ពីប្រធានស្ថាប័ន ឬ អង្គភាព អំពីកំណើតរបស់ទារក ឬ កុមារ បើកើតនៅស្ថាប័ន ឬ អង្គភាព ឬ
- សៀវភៅគ្រួសាររបស់សាមីខ្លួន ឪពុក ម្តាយ និង របស់សាក្សី (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល និង របស់សាក្សី ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល និង សាក្សី (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ ឪពុក ម្តាយ (ប្រសិនបើមាន)ឬ
- ឯកសារប្បវត្តិ ឬ សោធននិវត្ត ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមីរបស់សាមីខ្លួន បើជាមន្ត្រីរាជការ កងយោធពលខេមរៈភូមិន្ទ និង កងនគរបាលជាតិ។

២- <u>ការសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពហួសរយៈពេល ១៥ថ្ងៃ</u> :

(យោងមាត្រា៤០ ថ្មី នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤)

បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់ អាជ្ញាធរឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅក្នុងខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

ក- ករណីអ្នកទទួលមរណភាព ទុកឱ្យហួសរយៈពេល ១៥ថ្ងៃ នៅក្នុងឆ្នាំ :

បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល១៥ថ្ងៃ នៅក្នុងឆ្នាំ ពុំបានទៅរាយការណ៍ចុះស្បៀវភៅអត្រានុកូលដ្ឋាន មរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់ ដែលមានអាសយដ្ឋានពិតប្រាកដរបស់ អ្នកស្លាប់។

អ្នកប្តឹងសុំត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- ពាក្យប្តឹងសុំចុះស្បៀវភៅមរណភាពរបស់ក្រុមគ្រួសារ នៃអ្នកស្លាប់ចំនួន ០១ ច្បាប់ ដែលបិទតែមប្រើថ្លៃ ១.០០០ រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង បិទតែមប្រើថ្លៃ ៤.០០០ រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។ ចំពោះការបិទតែមប្រើតម្លៃ ១.០០០ រៀល និង ៤.០០០ រៀល លើពាក្យប្តឹងសុំ គឺជំនួសឱ្យការបង់ប្រាក់ផ្ទាល់ ។

- - ស្បៀវភៅគ្រួសារ ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំចុះស្បៀវភៅមរណភាព ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពពីសមត្ថកិច្ចជំនាញ បើស្លាប់ដោយឃាតកម្ម ឬ ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ បើស្លាប់ក្នុងភូមិ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាម ក្រសួង ស្ថាប័ន ឬ អង្គភាព បើស្លាប់នៅក្នុងស្ថាប័ន ឬ អង្គភាព ឬ
- ស្បៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) ។

ខ- ករណីអ្នកទទួលមរណភាពទុកឱ្យហួសឆ្នាំ :

បើមានអ្នកស្លាប់ទុកអោយហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃអ្នកស្លាប់ ដើម្បីចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាព ។

អ្នកប្តឹងសុំ ត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- ស្បៀវភៅគ្រួសារ ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំ
- សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការខេត្ត ក្រុងសាមី
- ស្បៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកប្តឹងសុំ (ប្រសិនបើមាន) ។

កំណត់ចំណាំ :

ដោយឡែកចំពោះអ្នកស្លាប់នៅចុងខែ ធ្នូ នៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល ១៥ថ្ងៃ អាចឆ្លងចូលដល់ឆ្នាំបន្ទាប់ ក្រុមគ្រួសារអាចមកប្តឹងសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពនៅក្នុងឆ្នាំកំពុងអនុវត្ត ឬ នៅឆ្នាំបន្ទាប់បាន ។

ចំពោះអ្នកស្លាប់នៅចុងខែធ្នូនៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល ១៥ថ្ងៃ ឆ្លងចូលដល់ឆ្នាំបន្ទាប់ តែទុកឱ្យហួសរយៈពេលដែលបានកំណត់នេះអាចប្តឹងសុំចុះស្បៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឆ្នាំបន្ទាប់បាន ដោយត្រូវអនុវត្តទៅតាមបែបបទចំណុច "២" នៃចំណុចធំ " v " ស្តីពីករណីអ្នកទទួលមរណភាពទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ។

VI- <u>បែបបទ នីតិវិធី របៀបកត់ត្រាការងារអត្រានុកូលដ្ឋានតាមលក្ខណៈធម្មតា</u> :

ការងារកត់ត្រាស្បៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ការថែរក្សាស្បៀវភៅអត្រានុកូលដ្ឋាន ការចម្លងសំបុត្រអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាន ស្មៀនឃុំ សង្កាត់ និង មន្ត្រីរក្សាស្បៀវភៅអត្រានុកូលដ្ឋាន ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ឬត់ចត់ ច្បាស់លាស់តាមបែបបទ នីតិវិធី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ដែលបានកំណត់នៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រា ការងារអត្រានុកូលដ្ឋាន បោះពុម្ពនាខែ កក្កដា ឆ្នាំ ២០០៥ សម្រាប់ការងារអត្រានុកូលដ្ឋានដំណើរការតាមលក្ខណៈធម្មតា ។

រាល់បែបបទ នីតិវិធី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន សម្រាប់យុទ្ធនាការចុះស្បៀវភៅអត្រានុកូលដ្ឋានចល័ត ត្រូវបញ្ឈប់មិនឱ្យយកមកអនុវត្តទៀតឡើយ ។

VII- <u>ចំារម និង ការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីការងារអត្រានុកូលដ្ឋាន</u> :

- រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ។ មន្ត្រីអត្រានុកូលដ្ឋាន អាជ្ញាធរស្រុក ខណ្ឌ ខេត្ត ក្រុង មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងឡើយ ។

- ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួន របស់ជនណាម្នាក់ទៀត។ សំបុត្រអត្រានុកូលដ្ឋានរបស់ជនណាមួយ ជាកម្មសិទ្ធិសម្រាប់តែជននោះប៉ុណ្ណោះ មិនអនុញ្ញាតឱ្យជនដទៃយកទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនឡើយ ។

- ហាមចុះស្បៀវភៅអត្រានុកូលដ្ឋានប្រភេទនីមួយៗ លើសពីមួយដងសម្រាប់មនុស្សតែម្នាក់ នៅច្រើនកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។

- សំបុត្រអត្រានុកូលដ្ឋាន និង សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ដែលមានកោស ឆូត លុប សរសេរជ្រៀតថែម មិនមានតម្លៃប្រើប្រាស់ជាផ្លូវការទេ ។

- ការចុះស្បៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ សាមីខ្លួន អ្នករាយការណ៍ សាក្សីត្រូវសម្តែងនូវការស្មោះត្រង់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ចំពោះការបញ្ជាក់អះអាងរបស់ខ្លួន អំពីព្រឹត្តិការណ៍ដែលកើតមានឡើងហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់ ។

- ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ ក្លែងអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពីមួយដង នៅកន្លែងដដែល ឬ កន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែងបន្លំ ត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

- មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ។ បើមន្ត្រីអត្រានុកូលដ្ឋានណា សមត្ថនិត ឃុបឃិត ក្លែងបន្លំ ចុះស្នៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ឬ បានទារប្រាក់លើសពីការកំណត់ពីប្រជាពលរដ្ឋ សម្រាប់ការងារអត្រានុកូលដ្ឋានត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

VIII- <u>ការបង់ថ្លៃក្រដាស និង ថ្លៃតែមប្រ៊ីលើសំបុត្រអត្រានុកូលដ្ឋាន</u> :

ការសុំសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ច្បាប់ដើមមួយសន្លឹកក្នុងរយៈពេលកំណត់ មិនត្រូវឱ្យបង់ថ្លៃឡើយ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និង តែមប្រ៊ីត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និង ថ្លៃតែមប្រ៊ីសារពើពន្ធ ។

ដោយឡែកចំពោះពាក្យប្តឹងសុំសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ហួសពេលកំណត់ ត្រូវបិទតែមប្រ៊ីចំនួន ១.០០០ រៀល ចំពោះប្រជាពលរដ្ឋដែលមានទីលំនៅនៅខេត្ត រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ និង ចំនួន ៤.០០០ រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

ចំពោះការបិទតែមប្រ៊ីតម្លៃ ១.០០០ រៀល និង ៤.០០០ រៀល លើពាក្យប្តឹងសុំ គឺជំនួសឱ្យការបង់ប្រាក់ផ្ទាល់ ។

ថវិកាដែលបានមកពីការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ត្រូវបង់ចូលថវិកាឃុំ សង្កាត់ ។

ថវិកាដែលបានមកពីការចម្លងអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅសាលាស្រុក ខណ្ឌ ត្រូវបង់ចូលថវិកាខេត្ត ក្រុង ។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង អភិបាលគ្រប់ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ចែងផ្សព្វផ្សាយ និង ចាត់វិធានការអនុវត្តឱ្យទទួលបានសម្រេចល្អប្រសើរ និង មានប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខឹម

ចម្លងជូន :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
"ដើម្បីជូនជ្រាប"
-គ្រប់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ
-គ្រប់សាលាខេត្ត ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

kimra 11.04.07

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០៤៥ សណន

សេចក្តីណែនាំ
ស្តីពី
ការបន្តដំណើរការកែតម្រូវ និងការធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

ក្នុងការអនុវត្តសេចក្តីណែនាំលេខ០៣៥សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ សម្រាប់រយៈពេល០២ ឆ្នាំកន្លងមក គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋឱ្យទទួលបានសេវាកែតម្រូវ និងធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន កាន់តែងាយស្រួល និងខ្លីខ្លាយ។ បច្ចុប្បន្ន ប្រជាពលរដ្ឋកាន់តែច្រើនបានទទួលព័ត៌មានអំពីដំណើរការ និងនីតិវិធីនៃការកែតម្រូវ និងការធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាននៅក្រសួងមហាផ្ទៃនេះ ហើយបន្តគាំទ្រ និងមកស្នើសុំកែតម្រូវ និងធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន តាមរយៈរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងបន្តជួយសម្រួលការផ្តល់សេវានេះ ក្រសួងមហាផ្ទៃសម្រេចដាក់ចេញនូវសេចក្តីណែនាំថ្មីស្តីពីការបន្តដំណើរការកែតម្រូវ និងការធ្វើមោយភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

I. អំពីទិន្នន័យដែលអាចកែតម្រូវបាន

ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានអាចកែតម្រូវបាន គឺជាទិន្នន័យដែលបានសរសេរខុស ឬកាន់ច្រឡំព័ត៌មានដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ មានដូចខាងក្រោម៖

១. ការខុសឆ្គងអក្ខរាវិរុទ្ធលើ នាមត្រកូល និង/ឬនាមខ្លួន "ជាអក្សរខ្មែរ" និង "អក្សរឡាតាំង" របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្តាយ (មានន័យថាសូរសំឡេងដូចគ្នា ឬប្រហាក់ប្រហែលគ្នាប៉ុន្តែការសរសេរខុសគ្នា)។

២. ការសរសេរខុស "ភេទ" នៅពេលចុះបញ្ជីដូចជា ភេទ "ប្រុស" តែសរសេរដាក់ថាភេទ "ស្រី" ឬ ភេទ "ស្រី" តែសរសេរដាក់ថាភេទ "ប្រុស"។

៣. ការចុះបញ្ជីដោយកាន់ច្រឡំលើថ្ងៃខែឆ្នាំកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្តាយ។

៤. ខុសថ្ងៃកំណើតសុរិយគតិ (ដូចជាថ្ងៃទី៣០ ខែកុម្ភៈ ឬថ្ងៃទី៣១ ខែមេសា)។

៥. ខុសថ្ងៃកំណើតច័ន្ទគតិ ដូចជាសរសេរចុះដាក់ថ្ងៃច័ន្ទ ទី១៣ ខែមេសា ឆ្នាំ១៩៧២ ប៉ុន្តែជាក់ស្តែងថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩៧២ ជាថ្ងៃព្រហស្បតិ៍។

៦. ការកាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល ដូចជាសរសេរដាក់ថា ស្រុកកំពង់សៀម ខេត្តកំពង់ស្ពឺ ប៉ុន្តែជាក់ស្តែងស្រុកកំពង់សៀម ស្ថិតក្នុងខេត្តកំពង់ចាម។

K.a

៧. ខ្វះទីកន្លែងកំណើត បានសរសេរខុសពីទីកន្លែងកំណើតដែលសាមីខ្លួនបានកើតជាក់ស្តែង ឬសរសេរខុសទីតាំងភូមិសាស្ត្រដែលនាសម័យដែលបុគ្គលនោះកើត ឧទាហរណ៍ បញ្ជីកំណើតរបស់បុគ្គលម្នាក់បានចុះថា កើតឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែក្នុងអំឡុងឆ្នាំ១៩៨៥ ស្រុកមង្គលបុរី ស្ថិតនៅក្នុងខេត្តបាត់ដំបង ពីព្រោះមិនទាន់បង្កើតខេត្តបន្ទាយមានជ័យនៅឡើយ។

៨. ការខកខានមិនបានចុះព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន លើកលែងតែការបន្ថែមទិន្នន័យព័ត៌មានណាដែលធ្វើឱ្យសាមីខ្លួនរួចផុតពីការទទួលខុសត្រូវខាងផ្លូវច្បាប់។

៩. សម្រេចមោឃភាពលើបញ្ជីអត្រានុកូលដ្ឋាន និងដកហូតសំបុត្រអត្រានុកូលដ្ឋានទាំងឡាយណាដែលបានចុះជាន់គ្នា ឬចុះខុសពីបែបបទនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

១០.កែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ។

II. អំពីសមត្ថកិច្ច

១. ក្នុងឆ្នាំកំពុងអនុវត្ត ការកែតម្រូវទិន្នន័យ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។

២. ក្នុងឆ្នាំកន្លងផុត ការកែតម្រូវទិន្នន័យ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៣. ករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមិនអាចសម្រេចកែតម្រូវទិន្នន័យ ព័ត៌មានដូចមានចែងក្នុងចំណុច I- ខាងលើ ឬការកែតម្រូវទិន្នន័យដែលមិនមែនជាសមត្ថកិច្ចរបស់ខ្លួន ត្រូវផ្ទេរទៅតុលាការជាសមត្ថកិច្ច។

III. អំពីនីតិវិធី

ក. ការកែតម្រូវ

១. សម្រាប់ឆ្នាំកំពុងអនុវត្ត

សាមីជន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យសុំកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅសាលាឃុំ សង្កាត់ ក្នុងករណីពិនិត្យឃើញថាសំបុត្រអត្រានុកូលដ្ឋានរបស់ខ្លួនបានសរសេរទិន្នន័យព័ត៌មានមួយចំនួនខុស។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវកែតម្រូវបញ្ជីអត្រានុកូលដ្ឋានរបស់អ្នកដាក់ពាក្យសុំ ស្របតាមការណែនាំនៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន។

២. សម្រាប់ឆ្នាំកន្លងផុត

២.១.ការដាក់ពាក្យសុំ

សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីសុំកែតម្រូវទិន្នន័យឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន(ឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២)នៅ៖

- នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។
- សាលាក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននឹងកំពុងរក្សាទុក។

បន្ទាប់ពីទទួលពាក្យស្នើសុំ សាលាក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារពាក់ព័ន្ធមករដ្ឋបាលរាជធានី ខេត្ត យ៉ាងយូរ០៣(បី)ថ្ងៃការងារ។ រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារដែលទទួលបានពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ មកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរ ០៣(បី)ថ្ងៃការងារ។

KC

២.២.ឯកសារភ្ជាប់

- បញ្ជី ឬសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានដែលមានកាលបរិច្ឆេទក្នុងឆ្នាំប្រតិទិន ដែលត្រូវកែតម្រូវ ឬត្រូវមោឃភាព
- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម (ករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម សាមីខ្លួន ឬអាណាព្យាបាលត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្តឹងពីប៉ុស្តិ៍នគរបាលរដ្ឋបាល)
- សៀវភៅស្នាក់នៅ និង/ឬសៀវភៅគ្រួសារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អាយុចាប់ពី១៥ឆ្នាំឡើង) ឬ
- លិខិតឆ្លងដែន បើមាន
- ឯកសារពាក់ព័ន្ធផ្សេងៗដូចជា អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ សញ្ញាប័ត្រ ... ។ល។

រាល់ឯកសារភ្ជាប់ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលភាពត្រឹមត្រូវ លើកលែងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់។

២.៣. ការសម្រេចកែតម្រូវរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវធ្វើជាសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យលើទិដ្ឋភាពច្បាប់នៃឯកសារពាក់ព័ន្ធ និងមូលហេតុនៃការស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន ដើម្បីធានាសង្គតិភាពទិន្នន័យអត្តសញ្ញាណបុគ្គលនីមួយៗ។ ក្នុងករណីចាំបាច់ នាយកដ្ឋានអត្រានុកូលដ្ឋានអាចស្រាវជ្រាវបន្ថែមអំពីមូលហេតុនៃការស្នើសុំកែតម្រូវបញ្ជីអត្រានុកូលដ្ឋាននេះបាន។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមថ្មី ០១(មួយ)ច្បាប់ ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែងដែលចេញសំបុត្រអត្រានុកូលដ្ឋាននោះ រួចដកហូត និងមោឃៈនូវសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមចាស់ និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានដែលខុសទាំងអស់។

ការស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋានត្រូវពិនិត្យសម្រេច ៖

- មិនឱ្យលើសរយៈពេល២០(ម្ភៃ)ថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវដែលដាក់នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និង
- មិនឱ្យលើសរយៈពេល៣០(សាមសិប)ថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវដែលដាក់នៅសាលាក្រុង ស្រុក ខណ្ឌ

សេចក្តីសម្រេចកែតម្រូវត្រូវធ្វើឡើងចំនួន០៤(បួន)ច្បាប់ ក្នុងនោះ ៖

- ០១(មួយ)ច្បាប់ សម្រាប់បញ្ជូនទៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ
- ០១(មួយ)ច្បាប់ សម្រាប់ចម្លងជូនសាលារាជធានី ខេត្ត
- ០១(មួយ)ច្បាប់ សម្រាប់បញ្ជូនទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ និង
- ០១(មួយ)ច្បាប់ សម្រាប់សាមីខ្លួន។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ អាចសម្រេចបដិសេធមិនឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមការស្នើសុំបាន ដោយមានបញ្ជាក់អំពីមូលហេតុជាក់លាក់។ ករណីនេះសាមីខ្លួនអាចប្តឹងជំទាស់ទៅតុលាការបាន។

ខ. ការធ្វើអោយតាព

១. *សម្រាប់ឆ្នាំកំពុងអនុវត្ត*

ការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋាននៅក្នុងឆ្នាំកំពុងអនុវត្ត មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ត្រូវអនុវត្តតាមការណែនាំនៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន។

២. *សម្រាប់ឆ្នាំកន្ទងផុត*

នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវធ្វើជាសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យសម្រេចលើការធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋានទាំងឡាយណាដែល៖

- ចុះបញ្ជីផ្ទុយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន
- ចុះបញ្ជីអត្រានុកូលដ្ឋានលើសពី០១ (មួយ)ដង នៅកន្លែងដដែល ឬនៅកន្លែងផ្សេងទៀត។

ករណីរកឃើញបញ្ហាដូចខាងលើនេះ នាយកដ្ឋានត្រូវជូនដំណឹងដល់សាមីខ្លួន ឬអាណាព្យាបាល តាមរយៈអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដើម្បីឱ្យដាក់ពាក្យសុំធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើសពី០១ដង នោះ ដើម្បីធ្វើការជ្រើសរើសយកបញ្ជីណាមួយដែលជាទិន្នន័យត្រឹមត្រូវដើម្បីប្រើប្រាស់ជាផ្លូវការ។

ករណីដែលសាមីខ្លួន ឬអាណាព្យាបាលមិនព្រមដាក់ពាក្យសុំមោយភាពបញ្ជីណាមួយក្នុងអំឡុងពេល ៦០(ហុកសិប)ថ្ងៃ ចាប់ពីទទួលបានលិខិតជូនដំណឹង មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមានសិទ្ធិចេញសេចក្តីសម្រេចធ្វើមោយភាពសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទមុនដោយរក្សាទុកសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទក្រោយ។

សេចក្តីសម្រេចធ្វើមោយភាពត្រូវធ្វើឡើងចំនួន០៤ (បួន)ច្បាប់ ក្នុងនោះ ៖

- ០១(មួយ)ច្បាប់ សម្រាប់បញ្ជូនទៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ
- ០១(មួយ)ច្បាប់ សម្រាប់ចម្លងជូនសាលារាជធានី ខេត្ត
- ០១(មួយ)ច្បាប់ សម្រាប់បញ្ជូនទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុកនៅទីនោះ និង
- ០១(មួយ)ច្បាប់ សម្រាប់សាមីខ្លួន។

សាមីខ្លួនអាចធ្វើការតវ៉ាពីការសម្រេចនេះ មកមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលបានសេចក្តីសម្រេចធ្វើមោយភាពនេះ។

គ. ការអនុវត្តការងាររបស់មន្ត្រីរក្សាសៀវភៅ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- កិបភ្ជាប់សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ នៅគល់បញ្ជីអត្រានុកូលដ្ឋានដែលត្រូវធ្វើការកែតម្រូវទិន្នន័យ ឬមោយភាពបញ្ជីអត្រានុកូលដ្ឋាន
- ធ្វើការកែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកបិចពណ៌ក្រហម និងសរសេរជួសនូវទិន្នន័យដែលត្រឹមត្រូវដោយទឹកបិចពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើគល់បញ្ជីដែលត្រូវធ្វើការកែតម្រូវទិន្នន័យនោះ តាមខ្លឹមសារដូចមាននៅក្នុងឧបសម្ព័ន្ធ៣។
- ធ្វើមោយភាពបញ្ជីអត្រានុកូលដ្ឋាន ដោយសរសេរទឹកបិចពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើគល់បញ្ជីដែលត្រូវមោយភាពនោះ តាមខ្លឹមសារដូចមាននៅក្នុងឧបសម្ព័ន្ធ៤។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឬមន្ត្រីទទួលបន្ទុកអត្រានុកូលដ្ឋាន ក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានតាមការស្នើសុំ ដោយផ្អែកលើសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

ការកែតម្រូវ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានណាមួយដែលមានចេតនាធ្វើឱ្យប្រាសចាកការពិត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

សេចក្តីណែនាំនេះដាក់ឱ្យអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ប្រធានស្ថាប័នពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តសេចក្តីណែនាំនេះតាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៥ រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឆ្នូ ឆ្នាំ២០១៩

ទទួលបាយអនុម័ត្តិ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសុខាភិបាល
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារកាលប្បវត្តិ